សមាសភាគកសាងផែនការបន្សាំ និងភាពធន់នៅតំបន់ឆ្នេរ

# ការបញ្ជ្រាបការបន្សាំនឹងការប្រែប្រួលអាកាសធាតុនៅ ក្នុងផែនការអភិវឌ្ឍន៍នៅថ្នាក់ក្រោមជាតិនៅកម្ពុជា




Cambodia Climate Change Alliance (CCCA)

Implemented by: Supported by:

Ministry of Environment

European Union

Empowered lives Resilient nations

Danida

SWEDEN

UNEP-DHI CENTRE for Water and Environment

UNEP

DHI


២០១៣

# មាតិកាអត្ថបទ

**បុព្វកថា** ........................................................ ៣

**សេចក្តីថ្លែងអំណរគុណ** ........................................................ ៤

**តារាងពាក្យបំព្រួញ** ........................................................ ៥

**សេចក្តីសង្ខេបប្រតិបត្តិ** ........................................................ ៧

**១. សេចក្តីផ្តើម** ........................................................ ១២

១.១ គោលបំណងនៃរបាយការណ៍នេះ ........................................................ ១២

១.១ តំបន់ឆ្នេរ ........................................................ ១៣

១.៣ ការប្រែប្រួលអាកាសធាតុនៅកម្ពុជា ........................................................ ១៤

១.៤ ក្របខ័ណ្ឌស្ថាប័ន ........................................................ ១៦

១.៥ ក្របខ័ណ្ឌគោលនយោបាយ ........................................................ ១៧

១.៦ សហគមន៍គោលដៅ ........................................................ ១៧

**២. ការវាយតម្លៃយុទ្ធសាស្ត្រទប់ទល់នៅក្នុងតំបន់ឆ្នេរ** ........................................................ ២០

២.២ យុទ្ធសាស្ត្រទប់ទល់នៅខេត្តកោះកុងនិងខេត្តព្រះសីហនុ ........................................................ ២០

២.៣ ការវាយតម្លៃយុទ្ធសាស្ត្រទប់ទល់ ........................................................ ២៤

**៣. ភាពងាយរងគ្រោះនៃទម្លាប់ដែលមានស្រាប់ក្នុងកសិកម្ម** ........................................................ ២៨

៣.១ របរចិញ្ចឹមជីវិតដែលផ្អែកលើធនធាន ........................................................ ២៨

៣.២ ការវាយតម្លៃភាពងាយរងគ្រោះ ........................................................ ៣១

៣.៣ ការសម្លឹងទៅអនាគត ........................................................ ៣២

៣.៤ ការពាក់ព័ន្ធខាងសេដ្ឋកិច្ច-សង្គម និងបរិស្ថាន ........................................................ ៣៣

**៤. ការវាយតម្លៃភាពងាយរងគ្រោះនិងហានិភ័យសហគមន៍** ........................................................ ៤០

៤.១ ការវាយតម្លៃភាពងាយរងគ្រោះ និងហានិភ័យ ........................................................ ៤០

៤.២ ភាពងាយរងគ្រោះនិងសមត្ថភាពបន្សាំ ..................... ៤៣

៤.៣ សកម្មភាពអនុវត្តបង្ហាញដែលបានលើកស្នើទាក់ទងនឹងការបន្សាំនៃរបរចិញ្ចឹមជីវិត ......... ៤៤

**៥. ការវិភាគថ្លៃចំណាយនិងផលចំណេញ ..................... ៤៦**

៥.១ ទិដ្ឋភាពរួមនៃសកម្មភាពអនុវត្តបង្ហាញដែលបានលើកស្នើសម្រាប់ការវិភាគសេដ្ឋកិច្ច ....... ៤៦

៥.២ សេចក្តីសង្ខេបថ្លៃចំណាយនិងផលចំណេញនិងការពិចារណាដទៃទៀត..................... ៤៨

**៦. សមត្ថភាពអនុវត្តសម្រាប់សកម្មភាពបង្ហាញ ..................... ៥១**

៦.១ ការប្រឈមខាងអភិបាលកិច្ចដែលទាក់ទងនឹងអាកាសធាតុ ..................... ៥១

៦.២ តម្រូវការសមត្ថភាពជាក់លាក់..................... ៥២

៦.៤ ឱកាសកសាងសមត្ថភាព..................... ៥៦

៦.៥ យោបល់អំពីសកម្មភាពកសាងសមត្ថភាព ..................... ៥៧

៦.៦ ឱកាសសម្រាប់រយៈពេលវែង ..................... ៥៩

**៧. ការគាំទ្រដល់ការអប់រំអំពីការប្រែប្រួលអាកាសធាតុបង្កើតការយល់ដឹង និងពង្រឹងគណៈកម្មការសហគមន៍កសិករប្រើប្រាស់ទឹក ..................... ៦១**

៧.១ ការអប់រំអំពីការប្រែប្រួលអាកាសធាតុ និងបង្កើតការយល់ដឹង..................... ៦១

៧.២ ការពង្រឹងគណៈកម្មការសហគមន៍កសិករប្រើប្រាស់ទឹក ..................... ៦៤

**៨. ផែនការអនុវត្តសម្រាប់សកម្មភាពបង្ហាញ..................... ៦៨**

៨.១ តារាងសកម្មភាពអនុវត្តបង្ហាញ ..................... ៦៨

៨.២ អាទិភាពសម្រាប់សកម្មភាពអនុវត្តបង្ហាញនៅតាមឃុំនានា ..................... ៦៩

**៩. សេចក្តីសន្និដ្ឋាន និងអនុសាសន៍ ..................... ៧១**

# បុព្វកថា

ខ្ញុំមានក្តីសោមនស្សរីករាយសូមបង្ហាញរបាយការណ៍ ស្តីពីការបញ្ជ្រាបការបន្សាំនឹងការប្រែប្រួលអាកាសធាតុទៅក្នុងផែនការអភិវឌ្ឍន៍ថ្នាក់ក្រោមជាតិនៅកម្ពុជា ដែលជាសមិទ្ធផលនៃកិច្ចសហប្រតិបត្តិការប្រកបដោយផ្លែផ្ការវាងស្ថាប័នរដ្ឋគ្រប់កំរិត ដូចជា ថ្នាក់ខេត្ត ស្រុក និងអង្គការមិនមែនរដ្ឋាភិបាលផ្សេងៗ គម្រោង និងកម្មវិធីដែលទាក់ទងជាមួយ ការអភិវឌ្ឍន៍តំបន់ឆ្នេរ និងការប្រែប្រួលអាកាសធាតុ។ របាយការណ៍នេះ នឹងរៀបរាប់សង្ខេបពីសកម្មភាពអនុវត្តគម្រោង និងវិធីសាស្រ្តបញ្ជ្រាការបន្សាំការប្រែប្រួលអាកាសធាតុនៅថ្នាក់ក្រោមជាតិ និងរចនាសម្ព័ន្ធអភិវឌ្ឍន៍ និងសមត្ថភាព ការអនុវត្តវិធានការបន្សាំការប្រែប្រួលអាកាសធាតុ ។

របាយការណ៍នេះ បង្ហាញពីទិដ្ឋភាពទូទៅ និងរៀបរាប់អំពីសកម្មភាពបានអនុវត្តការបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងផែនការអភិវឌ្ឍន៍នៅថ្នាក់ក្រោមជាតិ ដោយយោងតាមសកម្មភាពគម្រោង ដែលបានអនុវត្តនៅតំបន់គោលដៅក្នុងឃុំចំនួន ០៦ ក្នុងស្រុកព្រៃនប់ ខេត្តព្រះសីហនុ និងឃុំចំនួន ០២ នៅស្រុកមណ្ឌលសីមា ខេត្តកោះកុង ។ របាយការណ៍នេះ ជារបាយការណ៍សង្ខេបរួម បានដកស្រង់ពីរបាយការណ៍លម្អិត នៃរបាយការណ៍ដ៏ទៃទៀត ដែលទទួលបានតាមការចុះធ្វើសម្ភាសន៍នៅថ្នាក់ជាតិ ថ្នាក់ខេត្ត និងថ្នាក់ឃុំ ដោយពិនិត្យនិងវិភាគ និងបង្ហាញទស្សនៈទូលំទូលាយលើរចនាសម្ព័ន្ធដែលបានបង្កើត ដើម្បីបន្សាំនឹងការប្រែប្រួលអាកាសធាតុនៅថ្នាក់ក្រោមជាតិ និងសហគមន៍ ដែលអាច បន្សាំនឹងការប្រែប្រួលអាកាសធាតុ ព្រមទាំងការកែលម្អជីវភាពរស់នៅ ។

ភាពសម្បូរណ៍បែប នៃធនធានធម្មជាតិ និងបរិស្ថាននៅតំបន់ឆ្នេរសមុទ្រកម្ពុជា បានរងផលប៉ះពាល់រយៈពេលជាច្រើនឆ្នាំពីសកម្មភាពអភិវឌ្ឍន៍ ។ លើសពីនេះទៀត ការប្រែប្រួលអាកាសធាតុក៏បង្កឲ្យមានផលប៉ះពាល់ដល់ជីវភាពរស់នៅតំបន់ឆ្នេរសមុទ្រ ជាពិសេសតំបន់ទំនាបដូចជា ទឹកជំនន់ ការជ្រាបចូលទឹកសមុទ្រ និងការហូរច្រោះឆ្នេរ ។ សេចក្តីត្រូវការសម្រាប់ការគ្រប់គ្រង ដែលមានការកែលម្អ គឺដើម្បីធានាដល់ការកែលម្អ ដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម នៅក្នុងតំបន់ដោយមិនបង្កឲ្យមានផលប៉ះពាល់ដល់ធនធានធម្មជាតិ និងបរិស្ថាន ជាពិសេស វាជាការបន្ទាន់ទាក់ទងនឹង ផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុចំពោះជីវភាពរស់នៅពេលបច្ចុប្បន្ន ដែលសហគមន៍តំបន់ឆ្នេរកំពុងតែបង្កើតការ បន្សាំ និងបង្កើនភាពធន់ដល់សហគមន៍ ។ នៅពេលជាមួយគ្នា វាអាចប្រើប្រាស់សម្រាប់អនុវត្ត និងពង្រីកទៅផ្នែក ដ៏ទៃទៀតនៅតំបន់ឆ្នេរ និងខេត្តដ៏ទៃទៀត ។

របាយការណ៍នេះ មានសារៈសំខាន់ចំពោះអាជ្ញាធរឃុំ ស្រុក និងខេត្ត ព្រមទាំងមន្ទីរជំនាញនៅក្នុងខេត្តនៅតំបន់ឆ្នេរសមុទ្រកម្ពុជា ដើម្បីដោះស្រាយបញ្ហាស្មុគស្មាញទាក់ទងនឹងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងការប្រែប្រួលអាកាសធាតុ ការគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិប្រកបដោយចីរភាព ។ របាយការណ៍នេះ នឹងបង្ហាញពីតម្លៃដល់អ្នកអាន មានដូចជា អ្នករៀបចំគោលនយោបាយនៅថ្នាក់ជាតិ អ្នកធ្វើផែនការ និងស្ថាប័នរដ្ឋ អង្គការមិនមែនរដ្ឋាភិបាលគម្រោងផ្សេងៗ និងផ្នែកឯកជន ព្រមទាំងជាមូលដ្ឋានផងដែរ ដល់ការអប់រំ ការស្រាវជ្រាវផងដែរ ។

ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា អ្នកអានទាំងអស់នឹងស្វែងយល់ពីរបាយការណ៍នេះ ដែលជាធនធានដ៏មានតម្លៃសម្រាប់ការងារការប្រែប្រួលអាកាសធាតុនៅកម្ពុជា ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៤

**អគ្គនាយកបច្ចេកទេស**

**និងជាប្រធានគណៈកម្មាធិការដឹកនាំគម្រោង**

**វេជ្ជ. ឡុញ ហ៊ាល**

# សេចក្តីថ្លែងអំណរគុណ

របាយការណ៍នេះត្រូវបានរៀបរៀងឡើងនៅក្រោមសមាសភាគកសាងផែនការបន្សាំ និងភាពធន់ក្នុងតំបន់ឆ្នេរសមុទ្រកម្ពុជា ក្រោមកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា។ របកគំហើញ ក្នុងរបាយការណ៍នេះ បានផ្តោតលើមេរៀននានា ដែលទទួលបានពីសកម្មភាពដែលអនុវត្តនៅក្រោមសមាសភាគនេះ។

តាងនាមឲ្យក្រុមការងារតំបន់ឆ្នេរសមុទ្រកម្ពុជា ខ្ញុំបាទសូមសំដែងការដឹងគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះឯកឧត្តម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាអនុប្រធានគណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា ដែលតែងតែជម្រុញ ណែនាំ និងគាំទ្រយ៉ាងខ្លាំងក្លាដល់កិច្ចប្រឹងប្រែងរបស់ក្រុមការងារ ដើម្បីសម្រេចបានរបាយការណ៍នេះ។ ខ្ញុំក៏សូមថ្លែងអំណរគុណដល់ឯកឧត្តម លោក លោកស្រី ជាសមាជិក គណៈកម្មាធិការដឹកនាំគម្រោង ក្រុមការងារជនបង្គោលថ្នាក់ជាតិ ក្រុមការងារបច្ចេកទេសថ្នាក់ខេត្ត ទីប្រឹក្សាជាតិ និងអន្តរជាតិ រួមទាំងភាគីពាក់ព័ន្ធទាំងអស់ ដែលបានរួមចំណែកផ្តល់មតិល្អៗ ចំពោះការចងក្រងរបាយការណ៍នេះ។

ជាចុងក្រោយ សូមថ្លែងអំណរគុណដល់កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា ចំពោះការឧបត្ថម្ភគាំទ្រ ដល់សមាសភាគកសាងផែនការ និងភាពធន់ដល់ប្រែប្រួលអាកាសធាតុនៅតំបន់ឆ្នេរសមុទ្រកម្ពុជា តាមរយៈភ្នាក់ងារ អនុវត្ត DHI សហការល្អជាមួយក្រសួងបរិស្ថាន។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៤

**គណៈកម្មាធិការដឹកនាំគម្រោង**

**អនុប្រធានអចិន្ត្រៃយ៍**

**បណ្ឌិត ម៉ាន់ មុនីនាថ**

# តារាងពាក្យបំព្រួញ

| | | |
|---|---|---|
| AFD | AgenceFrançaise de Développement | ទីភ្នាក់ងារបារាំងដើម្បីអភិវឌ្ឍន៍ |
| CARDI | Cambodian Agricultural Research and Development Institute | វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា |
| CARP | Coastal Adaptation and Resilience Planning Component | សមាសភាគកសាងផែនការបន្សាំនិងធន់នៅក្នុងតំបន់ឆ្នេរ |
| CBNRM | Community Based Natural Resource Management | ការគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍ |
| CC | Climate Change | ប្រែប្រួលអាកាសធាតុ |
| CCCA | Cambodia Climate Change Alliance | សម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា |
| CCD | Climate Change Department | នាយកដ្ឋានប្រែប្រួលអាកាសធាតុ |
| CCU | Coastal Coordination Unit | អង្គភាពសម្របសម្រួលតំបន់ឆ្នេរ |
| CDP | Commune Development Plan | ផែនការអភិវឌ្ឍន៍ឃុំ |
| CSO | Civil Society Organisation | អង្គការសង្គមស៊ីវិល |
| DANIDA | Danish International Development Assistance | ជំនួយអភិវឌ្ឍន៍អន្តរជាតិប្រទេសដាណឺម៉ាក់ |
| DOA | Department of Agriculture | មន្ទីរកសិកម្ម |
| DRR | Disaster Risk Reduction | ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ |
| EIA | Environmental impacts assessment | ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន |
| EU | European Union | សហភាពអឺរ៉ុប |
| FFS | Farmer Field Schools | សាលាស្រែកសិករ |
| FiA | Fisheries Administration | រដ្ឋបាលជលផល |
| FO | Farmer Organisation | អង្គការកសិករ |
| FWUC | Farmers Water Users Community | សហគមន៍កសិករប្រើប្រាស់ទឹក |
| GIS | Geographic information system | ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ |
| HH | Household | គ្រួសារ |
| IDRC | International Development Research Centre | មជ្ឈមណ្ឌលបណ្តាលបណ្តុះបណ្តាលដើម្បីអភិវឌ្ឍន៍កម្ពុជា |
| IPM | Integrated Pest Management | វិធានការចម្រុះការពារដំណាំ |
| KAP-study | Understanding Public Perception of Climate Change in Cambodia study | ការសិក្សាស្វែងយល់អំពីទស្សនៈរបស់សាធារណៈជនអំពីការប្រែប្រួលអាកាសធាតុនៅកម្ពុជា |
| LT | Long Term (rice variety) | (ពូជស្រូវ)ធ្ងន់ |
| MAFF | Ministry of Agriculture, Forestry and Fisheries | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| MoE | Ministry of Environment | ក្រសួងបរិស្ថាន |
| MoI | Ministry of Interior | ក្រសួងមហាផ្ទៃ |
| MoP | Ministry of Planning | ក្រសួងផែនការ |

| | | |
|---|---|---|
| MoU | Memorandum of Understanding | អនុស្សារណៈនៃការយោគយល់ |
| MoWRAM | Ministry of Water Resources and Meteorology | ក្រសួងធនធានទឹក និងឧតុនិយម |
| MT | Medium Term (rice variety) | (ពូជស្រូវ)កណ្តាល |
| NAPA | National Adaptation Programme of Actions to Climate Change | កម្មវិធីសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ |
| NCCC | National Climate Change Committee | គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ |
| NCDD | National Committee for Sub-National Democratic Development | គណៈកម្មាធិការជាតិដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| NGO | Non-Governmental Organisation | អង្គការមិនមែនរដ្ឋាភិបាល |
| PDA | Provincial Directorates of Agriculture | មន្ទីរកសិកម្មខេត្ត |
| PWG | Provincial Working Group | ក្រុមការងារថ្នាក់ខេត្ត |
| RGC | Royal Government of Cambodia | រាជរដ្ឋាភិបាលកម្ពុជា |
| SCW | Save Cambodia's Wildlife | អង្គការសង្គ្រោះសត្វព្រៃ |
| SLR | Sea Level Rise | កំណើនកំពស់ទឹកសមុទ្រ |
| ST | Short Term (rice variety) | រយៈពេលខ្លី (ពូជស្រូវស្រាល) |
| ToT | Training of Trainers | ការបណ្តុះបណ្តាលគ្រូបង្គោល |
| UNDP | United Nations Development Programme | កម្មវិធីអភិវឌ្ឍន៍អភិវឌ្ឍន៍សហប្រជាជាតិ |
| UNEP | United Nations Environment Programme | កម្មវិធីបរិស្ថានសហប្រជាជាតិ |
| VRA | Vulnerability Reduction Assessment | ការវាយតម្លៃការកាត់បន្ថយភាពងាយរងគ្រោះ |

# សេចក្តីសង្ខេបប្រតិបត្តិ

រាជរដ្ឋាភិបាលកម្ពុជា (RGC) បានកំណត់អត្តសញ្ញាណតំបន់ឆ្នេរជាគោលដៅនៅក្នុងការងាររបស់កម្ពុជាសម្រាប់បន្សាំនឹងផលប៉ះពាល់ដែលមានស្រាប់ និងដែលអាចមានទៅអនាគតបណ្តាលពីការប្រែប្រួលអាកាសធាតុ។ តំបន់ឆ្នេរបានរងការគំរាមកំហែងពីផលប៉ះពាល់ធ្ងន់ធ្ងរនៃការប្រែប្រួលអាកាសធាតុ ដូចជា ខ្យល់ព្យុះ ព្យុះសមុទ្រ កំណើនកំពស់ទឹកសមុទ្រ និងការជ្រាបចូលនៃទឹកសមុទ្រ។ ប្រជាជនភាគច្រើនដែលរស់នៅក្នុងតំបន់នេះពឹងផ្អែកជាខ្លាំងលើប្រព័ន្ធអេកូឡូស៊ីនានា ដោយសារពួកគេទ្រទ្រង់ខ្លួនឯង ភាគច្រើនតាមរយៈកសិកម្ម (ភាគច្រើនការធ្វើស្រែ) និងការនេសាទ (ជាទ្រង់ទ្រាយតូច)។

ជាមួយការគាំទ្រហិរញ្ញវត្ថុពីសហគមន៍ម្ចាស់ជំនួយអន្តរជាតិ សម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា (CCCA) អនុវត្តសមាសភាគកសាងផែនការបន្សាំ និងភាពធន់នៃតំបន់ឆ្នេរ (CARP)ក្នុងគោលដៅកសាងសមត្ថភាពបន្សាំនៅក្នុងតំបន់ឆ្នេរ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ខេត្ត។ CARP ត្រូវបានអនុវត្តនៅក្នុងសហគមន៍គោលដៅចំនួនប្រាំបីនៅក្នុងខេត្តកោះកុង និងខេត្តព្រះសីហនុ ដោយមជ្ឈមណ្ឌលដើម្បីទឹកនិងបរិស្ថាននៃ UNEP-DHI ក្រោមកិច្ចសហប្រតិបត្តិការជាមួយក្រសួងបរិស្ថាន។

គោលបំណងរួមនៃរបាយការណ៍នេះគឺផ្តល់ជាសំណើមួយ អំពីថាតើការប្រែប្រួលអាកាសធាតុ អាចនឹងបញ្ជ្រាបបែបណាទៅក្នុងការកសាងផែនការអភិវឌ្ឍន៍នៅថ្នាក់ក្រោមជាតិក្នុងប្រទេសកម្ពុជា។ ដើម្បីបង្ហាញពីសំណើនេះ របាយការណ៍នេះសង្ខេបអំពីការវាយតម្លៃ និងការសិក្សាមួយចំនួន ដែលអាចអនុវត្តនៅក្រោមសមាសភាគ CARP នៅឆ្នាំ២០១២-១៣។ ការសិក្សានេះបានស្រង់យកមេរៀននានាពីការអនុវត្ត CARP និងលើកសំណើអន្តរាគមន៍សមស្រប ដើម្បីពង្រឹងសមត្ថភាពបន្សាំ និងការឆ្លើយតបទៅនឹងផលប៉ះពាល់ដែលបានទស្សន៍ទាយថានឹងកើតចេញពីការប្រែប្រួលអាកាសធាតុនៅក្នុងតំបន់ឆ្នេរ។ របកគំហើញនៅក្នុងរបាយការណ៍នានា និងដំណើរការនានាដែលបានអនុវត្តបន្ត ដើម្បីទទួលបានរបកគំហើញទាំងនោះ អាចផ្តល់ជាឧទាហរណ៍ ឬ អាចពង្រីកទៅអនុវត្តនៅកន្លែងផ្សេងនៅក្នុងប្រទេសកម្ពុជា ក៏ដូចជានៅក្នុងប្រទេសដ៏ទៃផងដែរ។

ការប៉ាន់ស្មានចំបងៗអំពីការប្រែប្រួលអាកាសធាតុសម្រាប់តំបន់ឆ្នេរគឺៈ

- កំណើនកំពស់ទឹកសមុទ្រពី ១៨ ដល់ ៥៦ ស.ម រហូតដល់ទសវត្សរ៍ឆ្នាំ ២០៩០
- កំណើនកំពស់ទឹកភ្លៀងនៅតាមបណ្តោយឆ្នេរសមុទ្រពី ២ ទៅ ៦% រហូតដល់ឆ្នាំ ២០៥០
- កំណើនសីតុណ្ហភាពមធ្យមប្រចាំឆ្នាំពី ០,៣ ដល់ ០,៦ °C រហូតដល់ឆ្នាំ ២០២៥, ពី ០,៧ ដល់ ២,៧ °C រហូតដល់ទសវត្សរ៍ឆ្នាំ ២០៦០និង ពី ១,៤ ដល់ ៤,៣ °C រហូតដល់ទសវត្សរ៍ឆ្នាំ ២០៩០។

សហគមន៍គោលដៅនៃCARPបានជួបប្រទះរួចមកហើយនូវការប្រែប្រួលដែលទាក់ទងនឹងអាកាសធាតុ ដូចជាៈ

- កំណើនខ្យល់ព្យុះនៅក្នុងតំបន់ឆ្នេរ និងខ្យល់ព្យុះកាន់តែខ្លាំងនៅក្នុងរដូវវស្សា
- គ្រោះរាំងស្ងួតនៅរដូវប្រាំង
- ការជ្រាបចូលនៃទឹកប្រៃ
- ការថយចុះសត្វក្នុងសមុទ្រ
- សត្វចិញ្ចឹមមានបញ្ហាខាងសុខភាព ដោយសារកំដៅកាន់តែកើនឡើងខ្លាំង
- ប្រព័ន្ធអេកូឡូស៊ីរួមចំណែកតិចតួចជាងមុននៅក្នុងការធានាសន្តិសុខស្បៀង

- ការថយចុះនៃជីជាតិដី
- ទឹកអណ្តូង/ទឹកក្រោមដីលែងអាចផឹកបានដូចមុន

ការវាយតម្លៃយុទ្ធសាស្ត្រទប់ទល់បច្ចុប្បន្ននៅក្នុងសហគមន៍គោលដៅនៃសមាសភាគ CARP ទាក់ទងនឹងទឹកជំនន់ គ្រោះរាំងស្ងួត និងព្រឹត្តិការណ៍មិនប្រក្រតីផ្សេងទៀត បង្ហាញថាកិច្ចប្រឹងប្រែងរបស់ពួកគេត្រូវបានរារាំងដោយកម្រិតទាបនៃសមត្ថភាពបច្ចេកទេស និងការគាំទ្រស្ថាប័នក្នុងកម្រិតកំណត់ ជាមួយលទ្ធផលដែលគ្មានយុទ្ធសាស្ត្រណាមួយដំណើរការបានពេញលេញតាមសក្តានុពលឡើយ។

កង្វះប្រព័ន្ធដែលមានការចាត់ចែងសម្រាប់ផ្សព្វផ្សាយព័ត៌មានអំពីគ្រោះមហន្តរាយធាតុអាកាសត្រូវបានកំណត់ថាជាបញ្ហាគន្លឹះមួយក្នុងការធានាប្រសិទ្ធភាពនៃយុទ្ធសាស្ត្រទប់ទល់។ អនុសាសន៍ត្រូវបានផ្តល់ទាក់ទងនឹងថាតើប្រព័ន្ធព័ត៌មានបែបនេះអាចនឹងរៀបចំឡើងបែបណា និងតើព័ត៌មានបែបណាដែលគួរតែផ្អែកលើប្រព័ន្ធបែបនោះ។ ទិន្នន័យដែលប្រមូលបាននៅក្នុងឃុំគោលដៅបង្ហាញពីការយល់ឃើញរបស់អ្នកភូមិអំពី (មូលហេតុនៃ)ការប្រែប្រួលអាកាសធាតុ ដែលផ្ទុយពីនិយមន័យបច្ចេកទេសអំពីការប្រែប្រួលអាកាសធាតុ ដែលអាចរារាំងការអនុវត្តគម្រោង។ មានការស្នើឲ្យកែប្រែការយល់ឃើញតាមរយៈសកម្មភាពបង្កើនការយល់ដឹង។

ការវាយតម្លៃអំពីភាពងាយរងគ្រោះនៃទម្លាប់អនុវត្តបច្ចុប្បន្នក្នុងវិស័យកសិកម្មនៅក្នុងសហគមន៍គោលដៅបង្ហាញថា ការគំរាមកំហែងមួយចំនួនទាក់ទងដោយផ្ទាល់ ឬ នឹងមានការទាក់ទងជាមួយការគំរាមកំហែងដែលពាក់ព័ន្ធនឹងអាកាសធាតុ។ ឧទាហរណ៍នានារាប់បញ្ចូលកំណើនកំពស់ទឹកសមុទ្រ (នៅកន្លែងខ្លះដែលមានទំនាក់ទំនងជាមួយការស្រុតដី) ដែលមានឥទ្ធិពលមកលើការដាំដំណាំ ការរងឥទ្ធិពលពីទឹកជំនន់ ការដោះទឹក និងសំណឹកឆ្នេរ, ការជ្រាបចូលនៃទឹកប្រៃ ដែលមានឥទ្ធិពលមកលើវត្តមានទឹកសម្រាប់ដាំដំណាំ និងគោលបំណងផ្សេងទៀត,កំណើនភាពញឹកញាប់នៃខ្យល់ព្យុះដែលមានឥទ្ធិពលមកលើការដំណាំ ការនេសាទ និងសំណឹកឆ្នេរ និងការរេចរឹលគុណភាពដី ដែលមានឥទ្ធិពលមកលើការដាំដំណាំ។ បច្ចុប្បន្ន គ្រោះរាំងស្ងួតគឺជាកង្វល់តូចតាច (មិនដូចនៅតាមកន្លែងដទៃក្នុងប្រទេសឡើយ) ប៉ុន្តែអាចសាយភាយ ប្រសិនបើធាតុអាកាសកាន់តែមានភាពមិនប្រក្រតីខ្លាំងជាមុន ដែលក្នុងករណីនោះ ទីកន្លែងនេះនឹងងាយរងគ្រោះ (ដោយសារតែខ្វះបទពិសោធន៍នៅមូលដ្ឋាន)។ រវាងប្រការទាំងនេះ ការគំរាមកំហែង នឹងមានឥទ្ធិពលអវិជ្ជមានមកលើបុរេសនាសម្រាប់បរចិញ្ចឹមជីវិតដែលមាននិរន្តរភាព។

គម្រោងសាកល្បងដែលមានសក្តានុពលនិងសកម្មភាពបង្ហាញសម្រាប់ការពិចារណាបន្ថែមទៀតគឺ៖

- ការបង្កើត/ការរួមបញ្ចូលគ្នារវាងសហគមន៍កសិករនិងសហគមន៍នេសាទ និងការគាំទ្របច្ចេកទេសដោយផ្ទាល់ដល់គ្រួសារកសិករ។
- ប្រព័ន្ធដាំដើមឈើដើម្បីបាំងខ្យល់ ការវាយតម្លៃលទ្ធភាពនៃការបែងចែកតំបន់ប៉ូលឌែរជាផ្នែកតូចៗ ដើម្បីកំហិតលើការរងឥទ្ធិពលពីការជ្រាបចូលនៃទឹកប្រៃ និងការពិនិត្យតាមដានជាប្រចាំនូវកម្រិតប្រៃនិងការស្រុតដី។
- ការអនុវត្តកម្មវិធីកសិកម្មធំៗ ដែលអាចផ្តល់ជា"មន្ទីរពិសោធន៍" សម្រាប់កំណត់អត្តសញ្ញាណពូជនិងទម្លាប់ដាំដំណាំបានសមស្រប។
- គាំទ្រឲ្យមានការប្រើប្រាស់ជី និងថ្នាំគីមីកសិកម្មបានសមស្រប និងលើកកំពស់ពូជល្អជាងមុន ជាពិសេសពូជស្រូវស្រាលដែលផ្តល់ទិន្នផលខ្ពស់។

- ការគាំទ្រដល់ការផ្សព្វផ្សាយ និងលើកកំពស់បទពិសោធន៍វិជ្ជមានក្នុងពេលថ្មីៗ ជាមួយការដាំដំណាំពីរលើកក្នុងមួយឆ្នាំ និងដើម្បីគ្រប់គ្រងដី និងការប្រើប្រាស់ដីឲ្យបានសមស្រប។
- គាំទ្រដល់របរចិញ្ចឹមជីវិតបន្ថែមខុសៗគ្នា។

ការវាយតម្លៃភាពងាយរងគ្រោះ និងហានិភ័យរបស់សហគមន៍ពីការប៉ះពាល់នៃការប្រែប្រួលអាកាសធាតុនៅក្នុងសហគមន៍គោលដៅ ផ្តល់ភស្តុតាងបន្ថែមអំពីភាពមិនគ្រប់គ្រាន់នៃយុទ្ធសាស្ត្រទប់ទល់ដែលមានស្រាប់។

ឃុំពាមក្រសោប នៃខេត្តកោះកុងៈ សេណារីយ៉ូហានិភ័យ ដែលទាក់ទងនឹងការបាត់បង់ឱកាសធ្វើនេសាទត្រូវបានប៉ាន់ប្រមាណថាមានកម្រិតខ្ពស់នៅពេលឈានទៅជិតដល់ឆ្នាំ ២១០០។ តំបន់ពាមក្រសោបភាគច្រើនផ្សំដោយទឹក និងព្រៃកោងកាង ហើយការនេសាទគឺជាប្រភពសំខាន់នៃប្រាក់ចំណូលសម្រាប់ប្រជាជន។ ការប្រែប្រួលអាកាសធាតុ (និងកំណើនកំពស់ទឹកសមុទ្រ) ទំនងជាបង្កការបាត់បង់យ៉ាងច្រើននៃទីជម្រកនានា (ជាពិសេស ព្រៃកោងកាង) ដែលផ្តល់ជាជម្រក និងអាហារដល់ត្រី។ ការវិវត្តបែបនេះទំនងជាបង្កការប្រែប្រួលអវិជ្ជមានមកលើរបាយ និងផលិតភាពនៃផលនេសាទដូច្នេះក៏មានការប៉ះពាល់មកលើរបរចិញ្ចឹមជីវិតនៅមូលដ្ឋានផងដែរ។ក្រៅពីនេះមានហានិភ័យនៃការជ្រាបចូលទឹកប្រៃ ក្នុងករណីដែលគ្មានទំនប់ការពារទឹកប្រៃ នឹងធ្វើឲ្យសកម្មភាពដាំដំណាំតាមធម្មតាមិនអាចធ្វើទៅបានឡើយ។

ឃុំទួលគគីរ ខេត្តកោះកុងៈ សេណារីយ៉ូហានិភ័យនៃការបាត់បង់ដំណាំនៅក្នុងរដូវវស្សាត្រូវបានប៉ាន់ប្រមាណថាស្ថិតនៅក្នុងដំពូកធ្ងន់ធ្ងរ កាលណាខិតទៅជិតឆ្នាំ ២១០០។ នៅទួលគគីរ ប្រភពយ៉ាងសំខាន់នៃប្រាក់ចំណូលគឺស្រូវ (ប្រាក់ចំណូលច្រើនជាងពាក់កណ្តាលរបស់គ្រួសារនានាបានពីដំណាំ)។ ការប្រែប្រួលអាកាសធាតុទំនងជាបង្កនូវការបាត់បង់ដីដាំដំណាំ ធ្វើឲ្យខូចគុណភាពដី និងគុណភាពទឹក និងបង្កើនលទ្ធភាពនៃទឹកជំនន់។

ព្រៃនប់ នៃខេត្តព្រះសីហនុៈ លទ្ធភាពនៃការបាត់បង់ដំណាំ(ស្រូវ)នៅក្នុងរដូវវស្សាត្រូវបានប៉ាន់ប្រមាណថាស្ថិតក្នុងដំពូកធ្ងន់ធ្ងរកាលណាខិតទៅជិតឆ្នាំ ២១០០។ នៅព្រៃនប់ ដំណាំនៅតែជាប្រភពសំខាន់តែមួយនៃប្រាក់ចំណូលប្រចាំគ្រួសារ។ ដូចនៅទួលគគីរដែរ ការប្រែប្រួលអាកាសធាតុនឹងបង្កឲ្យបាត់បង់ដីដាំដំណាំ និងបង្កឱនភាពដី និងគុណភាពទឹក។ ទឹកជំនន់ក៏នឹងកើតមានកាន់តែញឹកញាប់ជាងមុនផងដែរ។

ទោះបីសហគមន៍គោលដៅបានធ្វើការប្រឹងប្រែងជាច្រើនដើម្បីប្រយុទ្ធប្រឆាំងនឹងឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ និងអថេរអាកាសធាតុក៏ដោយ សមត្ថភាពបន្សាំទៅនឹងការប្រែប្រួលទៅអនាគតនៅពុំទាន់គ្រប់គ្រាន់ឡើយ។ ដូច្នេះជំនួយពីខាងក្រៅ(ពីអ្នកមូលដ្ឋាន ក៏ដូចជា អាជ្ញាធរនៅថ្នាក់ជាតិ) គឺជាប្រការចាំបាច់។

សំណើសកម្មភាពអនុវត្តបង្ហាញ ដែលទាក់ទងនឹងការបន្សាំនៃរបរចិញ្ចឹមជីវិតគឺៈ

- កម្មវិធីបណ្តុះបណ្តាលអំពីកសិកម្មចម្រុះសម្រាប់បុគ្គលិកផ្សព្វផ្សាយកសិកម្ម/ជលផល និងគ្រួសារនានាអំពីយុទ្ធសាស្ត្របន្សាំ និងការដាំដំណាំចម្រុះនៅក្នុងឃុំគោលដៅចំនួន៧-៨ឃុំ
- គម្រោងសហគមន៍ព្រៃឈើ ក្រោមកិច្ចសហប្រតិបត្តិការជាមួយរដ្ឋបាលព្រៃឈើ ដែលលទ្ធភាពបែបនេះមាននៅឃុំទួលគគីរផងដែរ។ សក្តានុពលបែបនេះអាចមានសិទ្ធិឲ្យសត្វស៊ីស្មៅ នៅក្នុងដែនដីព្រៃឈើក៏ដូចជាកន្លែងបណ្តុះកូនឈើផងដែរ។

- គម្រោងសហគមន៍នេសាទនៅឃុំពាមក្រសោប ក្រោមកិច្ចសហប្រតិបត្តិការជាមួយរដ្ឋបាលជលផល ជាពិសេសក្នុងការពង្រឹងវិធានការច្បាប់ និងការពង្រឹងលើការអនុវត្ត
- ការពង្រឹងការងារថែទាំទំនប់ដោយសហគមន៍ប្រព័ន្ធលូដោះទឹកនិងប្រព័ន្ធស្រោចស្រពក្រោមកិច្ចសហការជាមួយ MoWRAM –សម្រាប់ព្រែនប់ និងទួលគគីរ
- ការលើកកំពស់ និងបង្កើនវត្តមានពូជដំណាំដែលឆាប់ផ្តល់ផល ជាពិសេស សម្រាប់ស្រូវវស្សា ដូច្នេះអាចប្រមូលផលនៅមុនមានទឹកជំនន់ធ្ងន់ធ្ងរ និងការជោរឡើងនៃទឹកសមុទ្រនៅក្នុងឃុំទាំងប្រាំ
- ការលើកកំពស់ការចិញ្ចឹមសត្វនៅក្នុងឃុំទាំងប្រាំ ដោយប្រើប្រាស់ទុនបង្វិល ដើមប្បីកែលម្អពូជ ដែលបានសាកល្បងដោយជោគជ័យនៅក្នុងប្រទេសកម្ពុជា ឡាវ និងក្នុងប្រទេសដទៃទៀត។

ការវិភាគខាងសេដ្ឋកិច្ច និងសង្គមនៃថ្លៃចំណាយ និងផលចំណេញសម្រាប់អន្តរាគមន៍មួយចំនួនដែលបានជ្រើសរើសបង្ហាញថា ជម្រើសទាំងអស់សុទ្ធតែផ្តល់ផលចំណេញខាងសេដ្ឋកិច្ចទាំងសម្រាប់CARP និងគ្រួសារដែលចូលរួម។ ជម្រើសទាំងអស់មានលក្ខណៈស្របគ្នាជាមួយអាទិភាពដែលតំណាងសហគមន៍បានលើកឡើង និងជាការពង្រឹងបន្ថែមលើជម្រើសទប់ទល់ទាំងអស់ដែលពួកគាត់កំពុងប្រើប្រាស់។ ដូច្នេះ មានការបង់ខាតខាងសង្គមក្នុងកម្រិតកំណត់ ប៉ុន្តែមានផលចំណេញច្រើនជាងទាក់ទងនឹងជម្រើសទាំងនេះ។

ការពិគ្រោះយោបល់ត្រូវបានធ្វើឡើងនៅក្នុងខែឧសភា-សីហា ឆ្នាំ២០១២ ជាមួយអង្គធរនៅថ្នាក់ក្រោមជាតិនៅខេត្តកោះកុង និងព្រះសីហនុ សហគមន៍អ្នកប្រើប្រាស់ទឹកព្រែនប់ និងអ្នកពាក់ព័ន្ធនានា នៅភ្នំពេញ ដើម្បីប៉ាន់ប្រមាណសមត្ថភាពរបស់ស្ថាប័នរដ្ឋាភិបាល ក្នុងការអនុវត្តសកម្មភាពសាកល្បង និងកំណត់អំពីតម្រូវការបណ្តុះបណ្តាល។ ភាពខ្វះចន្លោះមួយចំនួនខាងសមត្ថភាពត្រូវបានកំណត់ និង"ជម្រើសដែលងាយសម្រេចបាន"ផងដែរសម្រាប់ការកែលម្អដែលអាចសម្រេចបានដោយចំណាយតិច"ប្រសិនបើមាន"។

ផ្អែកលើការពិគ្រោះយោបល់ទាំងនេះ សកម្មភាពកសាងសមត្ថភាពដូចខាងក្រោមនេះត្រូវបានលើកស្នើឡើង ដើម្បីបន្ថែមគុណតម្លៃ និងរួមចំណែកក្នុងការផ្សព្វផ្សាយ និងពង្រឹងកិច្ចផ្តួចផ្តើមនៅក្រោម CARP:

- ការបណ្តុះបណ្តាលពហុជំនាញនៅថ្នាក់ខេត្ត និងស្រុក អំពីការប្រែប្រួលអាកាសធាតុ
- ការគាំទ្រដល់ការផ្សព្វផ្សាយអំពីទិន្នន័យដែលមានស្រាប់ស្តីពីការពិនិត្យតាមដានបានប្រសើរជាងមុន (កំពស់ទឹកភ្លៀង កម្រិតប្រៃ ការស្រុតដី ទម្លាប់ក្នុងការដាំដំណាំ។ល។) ជម្រុញការប្រើប្រាស់ផែនទី និងភាពងាយស្រួលជាងមុនក្នុងការទទួលបានផែនទីដែលមានស្រាប់ ក៏ដូចជា ការណែនាំអំពីការប្រើប្រាស់ទិន្នន័យ និងរូបភាពពីផ្កាយរណបផងដែរ ដែលរួមទាំង ព័ត៌មានពីអ៊ិនធឺណិត
- ការកសាងសមត្ថភាពអំពីការវិភាគគុណភាពដី និងការគ្រប់គ្រងដី
- កម្មវិធីតភ្ជាប់មួយ ដែលអាចពាក់ព័ន្ធជាមួយការផ្លាស់ប្តូរទស្សនកិច្ចសិក្សាសម្រាប់កសិករ និងអ្នកបញ្ជាទ្វារទឹកនៅតាមទំនប់ការពារទឹកប្រៃ នៅតាមសហគមន៍ប្រហែលគ្នានេះនៅដែនដីសណ្តរគួឡុង (មេគង្គ) នៃប្រទេសវៀតណាម ដែលមានបទពិសោធន៍យ៉ាងច្រើនអំពីអំពីការដាំដំណាំនៅក្នុងតំបន់ដែលរងឥទ្ធិពលពីការជ្រាបចូលនៃទឹកប្រៃ
- "អាត្លាស់អំពីការប្រែប្រួលអាកាសធាតុ"សម្រាប់តំបន់ឆ្នេរ ដែលរួមទាំង ការផលិតផែនទីអំពីកំពស់ទឹកភ្លៀង (ធម្មតា និងមិនប្រក្រតី) និងកំពស់ទឹកសមុទ្រ និងហានិភ័យទឹកជំនន់

- ការសិក្សាថ្នាក់អនុបណ្ឌិតនៅកម្រិតជាតិខាងការគ្រប់គ្រងបរិស្ថាន (ដែលរួមទាំងអំពីចក្ខុវិស័យខាងអាកាសធាតុ)
- ការបង្កើតអង្គការជាតិជំនាញដែគាំទ្រដល់ការបង្កើតបណ្ដាញ និងការចែករម្លែកចំណេះដឹងក្នុងចំណោមអ្នកអនុវត្ត
- ការបោះពុម្ពផ្សាយអនុសាសន៍គោលនយោបាយខ្លី/ករណីសិក្សានានាដែលរួមទាំង អំពីជោគជ័យនានា
- ការគាំទ្រដល់បណ្ដាញនៅថ្នាក់ជាតិ អំពីការត្រៀមបង្ការគ្រោះរាំងស្ងួត និងកាត់បន្ថយគ្រោះរាំងស្ងួត។

មានការលើកស្នើផងដែរឲ្យអនុវត្តសកម្មភាពបណ្ដុះបណ្ដាលគ្រូបង្គោល និងការអប់រំសាកល្បង និងវគ្គបង្កើនការយល់ដឹងសម្រាប់សមាជិកក្រុមការងារថ្នាក់ខេត្ត តំណាងពីថ្នាក់ឃុំ/ភូមិ និងសមាជិកគណៈកម្មការសហគមន៍កសិករប្រើប្រាស់ទឹក ក្នុងគោលដៅបង្កើនការយល់ដឹង និងចំណេះដឹងអំពីការប្រឈមដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ និងជម្រើសបន្សុំ និងការកែលម្អជំនាញបច្ចេកទេស។

ជាផ្នែកមួយនៃដំណើរការជ្រើសរើស សកម្មភាពអនុវត្តបង្ហាញត្រូវបានបង្ហាញជូននៅក្នុងខែកញ្ញា-ធ្នូ ឆ្នាំ ២០១២ ដល់ក្រុមការងារបច្ចេកទេសនេះ និងក្រុមប្រឹក្សាឃុំ នៅក្នុងសិក្ខាសាលាជាបន្តបន្ទាប់ក្នុងខេត្តកោះកុង និងព្រះសីហនុ។ យោបល់តបក៏បានទទួលផងដែរតាមរយៈការពិគ្រោះយោបល់ទាំងនេះ ដែលទាក់ទងនឹងការចាត់ជាលំដាប់។ ផ្អែកលើការពិគ្រោះយោបល់នេះ មានការអនុវត្តសកម្មភាពបន្ថែមទៀត ដើម្បីបង្កើតសកម្មភាពសាកល្បងចំនួនប្រាំមួយ ឲ្យទៅជាគម្រោងជាក់លាក់ ដែលរួមទាំង ថវិកា និងផែនការអនុវត្តផងដែរ។

ការអនុវត្តដោយជោគជ័យអាស្រ័យលើកិច្ចសហប្រតិបត្តិការដោយរលូនរវាង CARP, MoE និងគ្រឹះស្ថានផ្សេងៗទៀតនៃរាជរដ្ឋាភិបាលកម្ពុជា ជាពិសេស ស្ថាប័ននានានៅចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) ដែលរួមទាំងមន្ទីរកសិកម្ម និងមន្ទីរធនធានទឹក និងឧតុនិយម។ ស្ថាប័នទាំងនេះអាចមានសមត្ថភាពក្នុងកម្រិតកំណត់។ ដូច្នេះ ការពិគ្រោះយោបល់ និងចរចាឲ្យបានទាន់ពេលវេលាអំពីតួនាទី និងការទទួលខុសត្រូវ ដែលទាក់ទងនឹងការអនុវត្តមានសារៈសំខាន់ណាស់។

សកម្មភាពភាគច្រើនត្រូវបានគ្រោងសម្រាប់អនុវត្តនៅក្នុងឆ្នាំ ២០១៣ ប៉ុន្តែចាំបាច់ត្រូវមានសកម្មភាពអនុវត្តបន្តនៅក្នុងឆ្នាំ ២០១៤-២០១៥។ ទោះជាយ៉ាងណាក៏ដោយ សមាសភាគ CARP គ្រោងនឹងបញ្ចប់នៅចុងត្រីមាសទីមួយឆ្នាំ ២០១៤ ដែលអាចគ្របដណ្ដប់ត្រូវតែមួយរដូវដាំដំណាំ (រដូវវស្សាឆ្នាំ ២០១៣) សម្រាប់ការអនុវត្ត។ នេះមិនមែនជាស្ថានភាពល្អឡើយ ដោយសារសកម្មភាពអនុវត្តសាកល្បងទាំងអស់អាចទទួលផលពីវត្តមាននៃសកម្មភាពក្នុងសមាសភាគនេះ សម្រាប់ការអនុវត្តជាបន្ត និងការពង្រឹងបន្ថែម និងសមិទ្ធផលនានា។

# ១. សេចក្តីផ្តើម

## ១.១ គោលបំណងនៃរបាយការណ៍នេះ

រាជរដ្ឋាភិបាលកម្ពុជា (RGC) បានកំណត់អត្តសញ្ញាណតំបន់ឆ្នេរជាគោលដៅនៅក្នុងការងាររបស់កម្ពុជាសម្រាប់បន្សាំនឹងផលប៉ះពាល់ដែលមានស្រាប់ និងដែលអាចមានទៅអនាគតបណ្តាលពីការប្រែប្រួលអាកាសធាតុ។ តំបន់ឆ្នេរបានរងការគំរាមកំហែងពីផលប៉ះពាល់ធ្ងន់ធ្ងរនៃការប្រែប្រួលអាកាសធាតុ ដូចជា ខ្យល់ព្យុះ ព្យុះសមុទ្រ កំណើនកំពស់ទឹកសមុទ្រ និងការជ្រាបចូលនៃទឹកសមុទ្រ។ កន្លែងជាច្រើននៅក្នុងតំបន់ឆ្នេរស្ថិតនៅតាមទីតាំងដែលមានរយៈកំពស់ទាប ដូច្នេះងាយរងគ្រោះដោយសារផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ។ ប្រជាជនភាគច្រើនដែលរស់នៅក្នុងតំបន់នេះពឹងផ្អែកជាខ្លាំងលើប្រព័ន្ធអេកូឡូស៊ីនានា ដោយសារពួកគេទ្រទ្រង់ខ្លួនឯង ភាគច្រើនតាមរយៈកសិកម្ម (ភាគច្រើនការធ្វើស្រែ) និងការនេសាទ (ជាទ្រង់ទ្រាយតូច)។

ជាមួយការគាំទ្រហិរញ្ញវត្ថុពី DANIDA សហភាពអឺរ៉ុប ស៊ុយអែដ និង UNDP សម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា (CCCA) អនុវត្តសមាសភាគកសាងផែនការបន្សាំ និងភាពធន់នៃតំបន់ឆ្នេរ (CARP)។ គោលដៅនៃសមាសភាគ CARP គឺកសាងសមត្ថភាពបន្សាំនៅក្នុងតំបន់ឆ្នេរ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ខេត្ត និងកសាងផែនការបន្សាំ តាមរយៈការអនុវត្តសកម្មភាពកសាងសមត្ថភាពជាក់ស្តែង តាមរបៀបធ្វើផងរៀនផងដែលមានការចូលរួមនៃអ្នកពាក់ព័ន្ធទាំងអស់។ បន្ទាប់មក ផែនការបន្សាំទាំងនេះនឹងត្រូវប្រែក្លាយជាវិធានការបន្សាំជាក់ស្តែង ដែលត្រូវអនុវត្តនៅក្នុងសហគមន៍ងាយរងគ្រោះនានា នៅក្នុងទីកន្លែងធ្វើកសិកម្ម និងកន្លែងមានព្រៃកោងកាងមួយចំនួន។

CARP ត្រូវបានអនុវត្តដោយមជ្ឈមណ្ឌលដើម្បីទឹក និងបរិស្ថាននៃ UNEP-DHI ក្រោមកិច្ចសហប្រតិបត្តិការជាមួយក្រសួងបរិស្ថាន នៅក្នុងសហគមន៍គោលដៅចំនួនប្រាំបីនៅក្នុងស្រុកមណ្ឌលសីមា និងព្រៃនប់ នៃខេត្តកោះកុង និងខេត្តព្រះសីហនុ។ ការជ្រើសយកខេត្តទាំងពីនេះ បានទទួលការគាំទ្រពីអ្នកពាក់ព័ន្ធទាំងអស់ ដែលមានវត្តមាននៅក្នុងសិក្ខាសាលាពិគ្រោះយោបល់ កាលពីថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១០។

គោលបំណងរួមនៃរបាយការណ៍នេះគឺផ្តល់ជាសំណើមួយ អំពីថាតើការប្រែប្រួលអាកាសធាតុអាចនឹងបញ្ជ្រាបបែបណាទៅក្នុងការកសាងផែនការអភិវឌ្ឍន៍នៅថ្នាក់ក្រោមជាតិក្នុងប្រទេសកម្ពុជា។ ដើម្បីបង្ហាញពីសំណើនេះ របាយការណ៍នេះសង្ខេបអំពីការវាយតម្លៃ និងការសិក្សាមួយចំនួន ដែលអាចអនុវត្តនៅក្រោមសមាសភាគ CARP នៅឆ្នាំ២០១២។

១. *"ការវាយតម្លៃយុទ្ធសាស្ត្រទប់ទល់នៅក្នុងតំបន់ឆ្នេរនៃប្រទេសកម្ពុជា"*។ របាយការណ៍នេះផ្តល់ជាគំនិតសម្រាប់ទិន្នន័យគោលនៃ CARP ដោយធ្វើការប៉ាន់ប្រមាណអំពីការយល់ឃើញរបស់សាធារណជនអំពីការប្រែប្រួលអាកាសធាតុនៅក្នុងតំបន់ឆ្នេរ ព័ត៌មានដែលបានផ្តល់ជូនដល់ប្រជាជននៅក្នុងតំបន់ឆ្នេរអំពីការប្រែប្រួលអាកាសធាតុ និង មុខសញ្ញាគ្រោះមហន្តរាយក៏ដូចជា យុទ្ធសាស្ត្រទប់ទល់ផងដែរដែលប្រជាជនក្នុងឃុំគោលដៅបានប្រើប្រាស់។
២. *"ភាពងាយរងគ្រោះនៃការអនុវត្តបច្ចុប្បន្នក្នុងកសិកម្ម"*៖ របាយការណ៍នេះផ្តល់គំនិតសម្រាប់ដំណើរការកសាងផែនការបន្សាំ ដោយប៉ាន់ប្រមាណពីភាពងាយរងគ្រោះនៃទម្លាប់អនុវត្តបច្ចុប្បន្នក្នុងកសិកម្ម ទល់នឹង

ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុនៅក្នុងខេត្តចំនួនពីរជាគោលដៅនៃCARPពោលគឺ កោះកុង និង ព្រះសីហនុ និងលើកស្នើគម្រោងសាកល្បងមួយចំនួន ដែលអាចអនុវត្តដើម្បីកែលម្អទម្លាប់អនុវត្តទាំងនេះ។

៣. *"ការវាយតម្លៃភាពងាយរងគ្រោះរបស់សហគមន៍ និងហានិភ័យពីការប្រែប្រួលអាកាសធាតុនៅក្នុងតំបន់ឆ្នេរកម្ពុជា"* ៖ របាយការណ៍នេះផ្តល់គំនិតជាបន្ថែមនៅក្នុងដំណើរការកសាងផែនការបន្សាំ ដោយប៉ាន់ប្រមាណភាពងាយរងគ្រោះជារួមចំពោះរបរចិញ្ចឹមជីវិតនៃសហគមន៍គោលដៅនៃCARPធៀបនឹងលក្ខខណ្ឌអាកាសធាតុបច្ចុប្បន្ន និងនិន្នាការដែលបានទស្សន៍ទាយ និងកំណត់អំពីចំនួនអន្តរាគមន៍នានា ដែលអាចអនុវត្តដើម្បីការពាររបរចិញ្ចឹមជីវិតទាំងនោះ។ អន្តរាគមន៍ទាំងនេះខ្លះត្រូវបានលើកស្នើឲ្យមានការវាយតម្លៃ ការពិគ្រោះយោបល់ និងការវិភាគសេដ្ឋកិច្ចជាបន្ថែម។

៤. *"ការវិភាគថ្លៃចំណាយនិងផលចំណេញ នៃការកែលម្អទម្លាប់អនុវត្តក្នុងកសិកម្មសម្រាប់ការប្រែប្រួលអាកាសធាតុនៅតាមឆ្នេរសមុទ្រ"*៖ របាយការណ៍នេះវិភាគថ្លៃចំណាយនិងផលចំណេញខាងសេដ្ឋកិច្ច និងសង្គម នៃអន្តរាគមន៍ដែលជ្រើសយក ដែលមិនងាយរងគ្រោះពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។

៥. *"សមត្ថភាពអនុវត្តកម្មភាពសាកល្បង"៖* របាយការណ៍នេះផ្តល់នូវការប៉ាន់ប្រមាណនូវសមត្ថភាពរបស់ស្ថាប័ននានានៃរដ្ឋាភិបាល ក្នុងការអនុវត្តសកម្មភាពសាកល្បងនៅក្រោមសមាសភាគ CARP រួមជាមួយយោបល់អំពីសកម្មភាពកសាងសមត្ថភាពផងដែរ។

៦. *"ការគាំទ្រដល់ការអប់រំអំពីការប្រែប្រួលអាកាសធាតុ ការបង្កើនការយល់ដឹង និងការពង្រឹងគណៈកម្មការសហគមន៍កសិករប្រើប្រាស់ទឹក"*៖ របាយការណ៍នេះផ្តល់យោបល់អំពីការអប់រំដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ និងសកម្មភាពបង្កើនការយល់ដឹង ដែលអាចអនុវត្តនៅខេត្ត និងនៅថ្នាក់ឃុំ និងនៅក្នុងគណៈកម្មការសហគមន៍កសិករប្រើប្រាស់ទឹក (FWUCs)។

របាយការណ៍នានាទាំងនេះ បានស្រង់យកមេរៀននានាពីការអនុវត្ត CARP និងលើកស្នើអន្តរាគមន៍សមស្រប ដើម្បីពង្រឹងសមត្ថភាពបន្សាំ និងការឆ្លើយតប ដោយផ្អែកលើឯកសារចងក្រងជាច្រើន និងការវិភាគទូលំទូលាយ ដើម្បីពង្រឹងសមត្ថភាពបន្សាំ របស់សហគមន៍គោលដៅ និងវិធានការរបស់ស្ថាប័នរដ្ឋាភិបាលឆ្លើយតប ទៅនឹងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុនៅក្នុងតំបន់ឆ្នេរ។ ការរួមផ្សំរបកគំហើញនៅក្នុងរបាយការណ៍នានា និងដំណើរការនានាដែលបានអនុវត្តបន្ត ដើម្បីទទួលបានរបកគំហើញទាំងនោះ អាចផ្តល់ជាឧទាហរណ៍ ឬ អាចពង្រីកទៅអនុវត្តនៅកន្លែងផ្សេងនៅក្នុងប្រទេសកម្ពុជា ក៏ដូចជានៅក្នុងប្រទេសដទៃផងដែរ។

យោបល់ដែលបានលើកស្នើខាងក្រោមនេះ រួមមានការបង្ហាញជូនអំពីសំណុំលក្ខណៈជាក់លាក់នៃតំបន់ឆ្នេរ លក្ខខណ្ឌអាកាសធាតុបច្ចុប្បន្ន និងនិន្នាការដែលបានទស្សន៍ទាយ ក៏ដូចជា ក្របខ័ណ្ឌស្ថាប័ន និងគោលនយោបាយសម្រាប់CARPផងដែរ។ សេចក្តីអធិប្បាយខ្លីមួយអំពីសហគមន៍គោលដៅទាំងប្រាំបី ក៏មានរួមបញ្ចូលផងដែរ។

## ១.២ តំបន់ឆ្នេរ

តំបន់ឆ្នេរកម្ពុជា បែកចេញជាខេត្តចំនួនបួន (កំពត កោះកុង ព្រះសីហនុ និងកែប)។ ផ្ទៃដីសរុបក្នុងខេត្តទាំងនេះមានប្រមាណ ១៧.២៣៧គ.ម$^{២}$។ ខ្សែឆ្នេរមានប្រវែង ៤៤០គ.ម ស្ថិតនៅក្នុងឈូងសមុទ្រថៃ។ តំបន់នេះមានកំពង់ផែសមុទ្រទឹកជ្រៅមួយស្ថិតនៅក្រុងព្រះសីហនុ និងត្រូវបានចាត់ទុកថាជាមជ្ឈមណ្ឌល

សេដ្ឋកិច្ចចំបងនៅកម្ពុជា។ អាកាសធាតុក្នុងតំបន់ឆ្នេរ ត្រូវបានឲ្យនិយមន័យថាជាអាកាសធាតុមូសុងត្រពិក ដែលមានកំពស់ទឹកភ្លៀងរវាង ២.០០០ និង ៤.០០០ម.ម។

តំបន់ឆ្នេរមានប្រភពទឹកសាបជាច្រើន ដែលបានពីស្ទឹង ទន្លេ និងបឹងនានា ដែលហូរកាត់តំបន់នេះ។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងរដូវវស្សាទន្លេ ស្ទឹង និងបឹងមានទឹកជោរជន់ ដោយសារការធ្លាក់ភ្លៀងខ្លាំង ដែលនាំឲ្យខូចដំណាំនៅតាមទីទំនាប។ នៅរដូវប្រាំង ទឹកក្នុងទន្លេនៅតំបន់ខ្សែទឹកខាងក្រោម ទទួលបានល្បាយទឹកប្រៃ និងទឹកសាប ដែលធ្វើឲ្យទឹកនេះមិនសមស្របសម្រាប់គោលបំណងនៃការស្រោចស្រពឡើយ។ ការសង្កេតនានាបង្ហាញថា ទឹកសមុទ្រអាចចូលមករហូតដល់ចម្ងាយ ១០គ.ម នៅតាមដងទន្លេ និងប្រឡាយនានា។

តំបន់ឆ្នេរភាគច្រើនគ្របដណ្តប់ដោយព្រៃឈើ។ ខេត្តកោះកុង មានអត្រាគម្របព្រៃឈើខ្ពស់ជាងគេ (៨៣% ឬ ១.០០២.៧២១ហិកតា) បន្ទាប់មកគឺខេត្តព្រះសីហនុ (៥៤% ឬ ៨១.៥៣៩ហិកតា) និងខេត្តកំពត (៤៨% ឬ ២២៤.៧៣០ហិកតា)។ ខេត្តកែបមានអត្រាគម្របព្រៃឈើទាបជាងគេ (២១% ឬ ៣.៧៣៣ហិកតា)។ ពីឆ្នាំ ១៩៩៣ ដល់ ២០០៥ អត្រាគម្របព្រៃឈើសរុបនៅក្នុងតំបន់ឆ្នេរបានថយចុះពី ៨៤% មកត្រឹម ៧១% ភាគច្រើនដោយសារផលិតកម្មកសិកម្ម។

នៅឆ្នាំ ២០០៥ នៅក្នុងតំបន់ឆ្នេរមានព្រៃកោងកាងក្នុងវិសាលភាព៥៥.៤១៩ហិកតា។ ព្រៃកោងកាង និងប្រព័ន្ធអេកូឡូស៊ីព្រៃទាំងនេះមានសារៈសំខាន់ណាស់សម្រាប់តំបន់ឆ្នេរដោយសារតែមូលហេតុចំនួនពីរ។ ទីមួយ ព្រៃកោងកាងដើរតួយ៉ាងសំខាន់សម្រាប់ការរស់នៅនៃប្រភេទត្រីជាច្រើន និងសារពាង្គកាយជាច្រើនផ្សេងទៀតនៅក្នុងសមុទ្រ។ ទីពីរ ព្រៃកោងកាងដើរតួជាទ្រនាប់រាំងស្កាត់ខ្យល់ព្យុះត្រូពិក ព្យុះសមុទ្រ និងកំណើនកំពស់ទឹកសមុទ្រ ដូច្នេះវាជួយការពារដីពីការហូរច្រោះ និងការជន់លិច។ ទោះបីមានតួនាទីសំខាន់បែបនេះក៏ដោយការសិក្សានានាបានប៉ាន់ស្មានថា ព្រៃកោងកាងបានបាត់បង់ប្រមាណ ២៥% នៅរវាងឆ្នាំ ១៩៩៣ និង ២០០៥។ ការបាត់បង់នេះភាគច្រើនដោយសារការប្រើប្រាស់ព្រៃកោងកាងសម្រាប់ការធ្វើអុស និងការផលិតធ្យូង ដោយល្មើសច្បាប់។ បញ្ហាដទៃទៀតរួមមាន ការរានឆ្ការព្រៃដើម្បីទន្ទ្រានយកដី និងការបង្កើតស្រែអំបិល និងវារីវប្បកម្មបង្គារ។

តំបន់ឆ្នេរមានវាលស្មៅសមុទ្រលើវិសាលភាពធំធេង។ មានស្មៅសមុទ្រប្រាំបីប្រភេទខុសៗគ្នានៅក្នុងតំបន់ឆ្នេរកម្ពុជា។ ស្មៅសមុទ្រទាំងនេះមាននាទីជាទីជម្រកសម្រាប់កូនត្រីតូចៗ ដូច្នេះវាផ្តល់ជាកន្លែងរកចំណីសម្រាប់ត្រីខុសៗគ្នាជាច្រើនប្រភេទ ដែលរួមទាំង វង្គសត្វ និងសត្វឥតឆ្អឹងកងផងដែរ។ ស្មៅសមុទ្រនៅទីនេះកំពុងស្ថិតក្រោមសម្ពាធដោយសារការធ្លាក់ចុះនៃគុណភាពទឹក បណ្តាលពីការកាប់ឈើ ការបូមខ្សាច់និងសកម្មភាពចាក់ពង្រីកដីនៅក្នុងតំបន់ឆ្នេរ។ ការនេសាទបែបបំផ្លាញក៏រួមចំណែកបង្កការប៉ះពាល់អវិជ្ជមានផងដែរ។

## ១.៣ ការប្រែប្រួលអាកាសធាតុនៅកម្ពុជា

ទោះបីមិនរងឥទ្ធិពលខ្លាំងក្លាពីការប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ដូចក្នុងប្រទេសដទៃនៅក្នុងតំបន់នេះក៏ដោយ ដូចជា វៀតណាម និងហ្វីលីពីន កម្ពុជាត្រូវបានចាត់ទុកក្នុងចំណោមប្រទេសងាយរងគ្រោះបំផុតនៅក្នុងពិភពលោក ដោយសារការប្រែប្រួលអាកាសធាតុ (លំដាប់ទី៩ នៅក្នុងសន្ទស្សន៍ហានិភ័យពិភពលោក ឆ្នាំ ២០១១ ស្តីពីការចាត់ជាលំដាប់ភាពងាយរងគ្រោះពីគ្រោះមហន្តរាយ និងគ្រោះធម្មជាតិ លំដាប់ទី៦ ក្នុង

សន្ទស្សន៍ភាពងាយរងគ្រោះនៃការប្រែប្រួលអាកាសធាតុ Maplecroft ឆ្នាំ ២០១២)។ ភាពងាយរងគ្រោះរបស់កម្ពុជា កើតឡើងដោយសារតែភាពទន់ខ្សោយនៃហេដ្ឋារចនាសម្ព័ន្ធ កម្រិតទាបនៃសមត្ថភាពក្នុងការបន្សាំទៅនឹងឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ ហើយប្រជាពលរដ្ឋជាច្រើនមានរបរកសិកម្ម និងរស់នៅក្នុងតំបន់ដាច់ស្រយាល។

របរចិញ្ចឹមជីវិតនៅកម្ពុជាពឹងផ្អែកជាខ្លាំងលើរដូវវស្សា ពីខែឧសភា ដល់ តុលា និងទឹកជំនន់ប្រចាំឆ្នាំនៃទន្លេមេគង្គ និងបឹងទន្លេសាប ដែលកាន់តែលែងទុកចិត្តបាននៅក្នុងបណ្តាឆ្នាំកន្លងមកនេះទាក់ទងនឹងអំឡុងពេលនៃការមកដល់នៃទឹកជំនន់ និងទំហំនៃទឹកជំនន់។

តំបន់ឆ្នេរគឺជាតំបន់មួយដែលងាយរងគ្រោះបំផុតពីការប្រែប្រួលអាកាសធាតុនៅក្នុងប្រទេស។ ការប្រែប្រួលអាកាសធាតុអាចពាក់ព័ន្ធនឹងអថេរជាច្រើនប្រចាំរដូវ ក៏ដូចជា អថេររវាងឆ្នាំនានាផងដែរ ដែលបង្កឲ្យមានការកើតឡើងនៃលក្ខខណ្ឌធាតុអាកាសមិនប្រក្រតី ដូចជា ខ្យល់ព្យុះ ព្យុះស៊ីក្លូន ទឹកជំនន់ រលកកំដៅ។ល។ ខាងក្រោមនេះមានការគូសបញ្ជាក់ត្រឹមតែអំពីលក្ខខណ្ឌមធ្យមតែប៉ុណ្ណោះ។ លក្ខខណ្ឌនៃការទស្សន៍ទាយចំបងៗ គឺ៖

<u>**កំណើនកំពស់ទឹកសមុទ្រ**</u>

តំបន់ឆ្នេរនឹងមានកំណើនកំពស់ទឹកសមុទ្រពី ០,១៨ ទៅ ០,៥៦ម រហូតដល់ទសវត្សរ៍ឆ្នាំ ២០៩០។ កំណើននេះកាន់តែធ្ងន់ធ្ងរដោយសារការប្រែប្រួលនៃកំពស់ទឹកជោរ ដែលអាចមានរហូតដល់ ០,៧ម ក្នុងមួយថ្ងៃ។ ចំណែករលកមានកំពស់ ៤-៥ម ត្រូវបានកត់សំគាល់ថាកើតមាននៅសមុទ្រក្នុងពេលមានខ្យល់ព្យុះ។

ឥទ្ធិពលទាំងនេះរួមផ្សំជាមួយការថយចុះនៃព្រៃកោងកាង និងខ្យល់ព្យុះ និងព្យុះសមុទ្រដែលកើតមានកាន់តែញឹកញាប់ និងខ្លាំងក្លា ដែលនាំឲ្យមានការជន់លិចតំបន់ឆ្នេរ។ ការជន់លិចតំបន់ឆ្នេរបែបនេះ មានឥទ្ធិពលមហន្តរាយដល់សហគមន៍នៅតាមឆ្នេរសមុទ្រ។ ផលវិបាកមួយគឺកំណើនកម្រិតប្រៃនៃទឹកលើដីនិងក្រោមដី។ ការឡើងប្រៃបែបនេះមានផលប៉ះពាល់ធ្ងន់ធ្ងរមកលើដីជាតិដីដាំដំណាំ និងមកលើប្រព័ន្ធអេកូឡូស៊ីទឹកសាបផងដែរ។ ប្រការនេះបង្កការគំរាមកំហែងមកលើសន្តិសុខស្បៀង និងរបរចិញ្ចឹមជីវិត ដោយសារតែសកម្មភាពកសិកម្មភាគច្រើនប្រមូលផ្តុំនៅក្នុងទីទំនាបនៃតំបន់ឆ្នេរដែលងាយជួបប្រទះបញ្ហាទឹកជំនន់។ ហេដ្ឋារចនាសម្ព័ន្ធក្នុងតំបន់ឆ្នេរក៏ស្ថិតក្រោមសម្ពាធ ដែលអាចនាំឲ្យមានកំនើនភាពងាយរងគ្រោះជាបន្តបន្ទាប់ និងបាត់បង់ផលចំណូលពីទេសចរណ៍ផងដែរ។

<u>**កំណើនកំពស់ទឹកភ្លៀង**</u>

ការធ្លាក់ភ្លៀងនៅតាមឆ្នេរសមុទ្រត្រូវបានរំពឹងថានឹងកើនឡើងពី ២ ទៅ ៦% រហូតដល់ឆ្នាំ ២០៥០ ហើយទីទំនាបនានា ទំនងជាមានកំណើនការធ្លាក់ភ្លៀងច្រើនជាងនៅតំបន់ខ្ពស់ ដែលបង្កជាផលវិបាកនៃព្រឹត្តិការណ៍ទឹកជំនន់កាន់តែញឹកញាប់ និងកាន់តែខ្លាំងឡើងបណ្តាលពីការធ្លាក់ភ្លៀងខ្លាំងផងដែរ។

ទឹកជំនន់ ការធ្លាក់ភ្លៀងខ្លាំង និងខ្យល់ព្យុះ បានបំផ្លាញទ្រព្យសម្បត្តិ និងមូលដ្ឋានផលិតកម្ម ដូចជាដំណាំ និងសត្វចិញ្ចឹម។ ទឹកជំនន់ ច្រើនតែនឹងនាំឲ្យខ្វះទឹកស្អាត និងលក្ខខណ្ឌដែលគ្មានអនាម័យ ដែលបង្កឲ្យមានបញ្ហាសុខភាពធ្ងន់ធ្ងរ និងអាចមានការរាតត្បាតនៃជម្ងឺផងដែរ។ ខ្យល់ព្យុះកាន់តែញឹកញាប់ ក៏នឹងនាំឲ្យមានការប៉ះពាល់មកលើដំណាំ ការនេសាទ និងសំណឹកឆ្នេរសមុទ្រផងដែរ។

**<u>កំណើនសីតុណ្ហភាព</u>**

តំបន់ឆ្នេរនឹងមានកំណើនសីតុណ្ហភាពមធ្យមប្រចាំឆ្នាំពី ០,៣ដល់០,៦ °C រហូតដល់ឆ្នាំ ២០២៥, ០,៧ ដល់ ២,៧°C រហូតដល់ទសវត្សរ៍ឆ្នាំ ២០៦០ និង ១,៤ ដល់ ៤,៣ °C រហូតដល់ទសវត្សរ៍ឆ្នាំ ២០៩០។ ប្រការនេះ ទំនងជានាំឲ្យមានកំណើនរំហួត និងកំណើនហានិភ័យនៃគ្រោះរាំងស្ងួត។ ក្រៅពីនេះ ក៏មានការព្យាករណ៍ថា នឹងមានកំណើនចំនួនថ្ងៃ និងយប់ក្តៅផងដែរ។

គ្រោះរាំងស្ងួត ឬរលកកំដៅនឹងបង្កបញ្ហានានា ដែលទាក់ទងនឹងការផ្តល់ចំណី/ការផ្តល់ទឹកដល់សត្វចិញ្ចឹម ការស្រោចដំណាំ និងភាពខ្សត់ទឹកស្អាតសម្រាប់ផឹក។ បញ្ហាទាំងអស់នេះមានឥទ្ធិពលអវិជ្ជមានមកលើសុខភាពប្រជាជនជាទូទៅ។ កំណើនសីតុណ្ហភាព ឬការលេចឡើងនៃរលកកំដៅ ក៏នឹងកាត់បន្ថយសមត្ថភាពរបស់មនុស្សនៅក្នុងការងារផងដែរ ដោយសារតែកំដៅ។ ទោះបីសព្វថ្ងៃនេះ គ្រោះរាំងស្ងួតអាចជាកង្វល់តិចតួច (មិនដូចនៅតំបន់ដទៃទៀតក្នុងផ្ទៃប្រទេស)ក៏ដោយ សេណារីយ៉ូនេះអាចរីកធំទៅកន្លែងផ្សេងទៀត ប្រសិនបើធាតុអាកាសកាន់តែគ្មានភាពប្រក្រតី ដែលនៅក្នុងករណីនោះ តំបន់នេះពិតជានឹងមានភាពងាយរងគ្រោះ (ដោយសារតែខ្វះបទពិសោធន៍)។

## ១.៤ ក្របខ័ណ្ឌស្ថាប័ន

ដើម្បីអាចបន្សាំនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ សមត្ថភាពជាក់លាក់សម្រាប់ស្ថាប័នមួយចំនួនគឺជាតម្រូវការចាំបាច់។ សមត្ថភាពនេះរួមមាន មិនត្រឹមតែយុទ្ធសាស្ត្រទប់ទល់ដែលអ្នកភូមិនៅក្នុងសហគមន៍មូលដ្ឋានបានប្រកាន់យកប៉ុណ្ណោះទេ ប៉ុន្តែក៏ជាយុទ្ធសាស្ត្របន្សាំដែលបានរួមបញ្ចូលនៅគ្រប់លំដាប់ថ្នាក់នៅក្នុងប្រទេសផងដែរ។

គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ (NCCC) ដែលបានបង្កើតឡើងនៅក្នុងខែមេសា ឆ្នាំ២០០៦ ជាយន្តការអន្តរក្រសួង មានអាណត្តិរៀបចំ សម្របសម្រួល និងពិនិត្យតាមដានការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ បរិធានច្បាប់ និងកម្មវិធីនានា ដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ។ សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** គឺជាប្រធានកិត្តិយសនៃ NCCC ដែលជាសក្ខីភាពបង្ហាញពីការគាំទ្រខាងគោលនយោបាយផងដែរ។ គណៈកម្មាធិការ NCCC មានសមាភាពជាមន្ត្រីជាន់ខ្ពស់មកពីក្រសួងស្ថាប័នចំនួន ១៩ នៃរដ្ឋាភិបាល។

ក្រសួងចំនួនបីខាងក្រោមនេះមានការទទួលខុសត្រូវ ដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ ការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានធម្មជាតិ និងប្រព័ន្ធអេកូឡូស៊ីតំបន់ឆ្នេរ។

- ក្រសួងបរិស្ថាន (MoE) បានបង្កើតឡើងនៅឆ្នាំ ១៩៩៣ និងមានភារៈទទួលខុសត្រូវលើកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិក្នុងប្រទេស។ ក្រសួងបរិស្ថានទទួលខុសត្រូវលើការសម្របសម្រួល ការងារប្រែប្រួលអាកាសធាតុ ហើយនាយកដ្ឋានប្រែប្រួលអាកាសធាតុនៃក្រសួងនេះ មាននាទីជាលេខាធិការដ្ឋានសម្រាប់ NCCC។ ទាក់ទងនឹងតំបន់ឆ្នេរ ក្រសួងនេះមានអាណត្តិសម្របសម្រួលការគ្រប់គ្រងបរិស្ថាន និងសកម្មភាពអភិវឌ្ឍន៍ ស្របតាមសេចក្តីសម្រេចមួយចុះហត្ថលេខាដោយនាយករដ្ឋមន្ត្រី។
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) មានអាណត្តិគ្រប់គ្រងគ្រប់សកម្មភាពដែលទាក់ទងនឹងផលផល ដែលរួមទាំង ការនេសាទសិប្បកម្ម ព្រៃកោងកាង ស្មៅសមុទ្រ ការនេសាទឧស្សាហកម្ម។ ក្នុង

ស្ថានភាពជាក់ស្តែង ក្រសួងនេះមានការទទួលខុសត្រូវលើការគ្រប់គ្រងប្រចាំថ្ងៃលើធនធានក្នុងតំបន់ឆ្នេរ ដោយគ្មានអាណត្តិសម្របសម្រួលជាទូទៅលើការគ្រប់គ្រងបរិស្ថានជារួមឡើយ។

- ក្រសួងធនធានទឹក និងឧតុនិយម (MoWRAM) មានការទទួលខុសត្រូវគ្រប់គ្រងរាល់សកម្មភាពដែលទាក់ទងនឹងការអភិវឌ្ឍន៍ទឹក និងឧតុនិយម និងការទប់ស្កាត់គ្រោះមហន្តរាយធម្មជាតិ។ ក្រសួងនេះបានចុះហត្ថលេខាលើអនុស្សារណៈនៃការយោគយល់ (MoU) ដែលទាក់ទងនឹងការចែករម្លែកការទទួលខុសត្រូវលើការគ្រប់គ្រងប៉ូលឌែរព្រៃនប់ជាមួយអាជ្ញាធរខេត្តព្រះសីហនុ និងសហគមន៍កសិករប្រើប្រាស់ទឹក។

## ១.៥ ក្របខ័ណ្ឌគោលនយោបាយ

កម្មវិធីសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ (NAPA) មាននាទីជាក្របខ័ណ្ឌគោលនយោបាយមួយសម្រាប់ NCCC។ ឯកសារ NAPA ត្រូវបានរៀបចំឡើង ដើម្បីចាត់ជាអាទិភាពនូវតម្រូវការបន្សាំនៅក្នុងប្រទេស និងដើម្បីបង្កើតភាពបំពេញគ្នាជាមួយកម្មវិធីបរិស្ថាន និងការអភិវឌ្ឍនានា។ កម្មវិធីនេះបានកំណត់គោលដៅសំខាន់ៗដូចតទៅ៖

- បង្កើតការយល់ដឹងអំពីសំណុំលក្ខណៈចំបងៗនៃមុខសញ្ញាគ្រោះមហន្តរាយអាកាសធាតុនៅកម្ពុជា
- បង្កើតការយល់ដឹងអំពីយន្តការទប់ទល់នៅកម្រិតក្រោមបំផុតក្នុងសង្គម
- បង្កើតឲ្យមានការពិនិត្យមើលកម្មវិធីដែលមានស្រាប់នានានិងការចាត់ចែងស្ថាប័នសម្រាប់ដោះស្រាយមុខសញ្ញាគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ
- កំណត់អត្តសញ្ញាណ និងចាត់ជាអាទិភាពសកម្មភាពបន្សាំនានា។

ក្រៅពី NAPA ផែនការសកម្មភាពយុទ្ធសាស្ត្រជាតិសម្រាប់ការប្រែប្រួលអាកាសធាតុ ក៏កំពុងស្ថិតក្នុងការរៀបចំដោយ MoE ផងដែរ។ ផែនការគ្រប់គ្រងបរិស្ថានខេត្ត សម្រាប់ឆ្នាំ ២០១១-២០១៥ ដែលកំពុងស្ថិតក្នុងការរៀបចំបង្ហើយ ដូច្នេះនៅពុំទាន់បានអនុម័តនៅឡើយទេ។ ទោះជាយ៉ាងណាក៏ដោយ មានការរំពឹងថា ការប្រែប្រួលអាកាសធាតុនឹងក្លាយជាប្រធានបទចម្រុះ និងមាននាទីជាក្របខ័ណ្ឌគោលនយោបាយមួយសម្រាប់យុទ្ធសាស្ត្របន្សាំនឹងការប្រែប្រួលអាកាសធាតុ។

## ១.៦ សហគមន៍គោលដៅ

ការវាយតម្លៃយុទ្ធសាស្ត្រទប់ទល់នឹងភាពងាយរងគ្រោះ និងហានិភ័យរបស់សហគមន៍ បានធ្វើឡើងនៅក្នុងតំបន់គោលដៅចំនួនពីរ ដែលបានជ្រើសរើសជាមុន៖

- ស្រុកមណ្ឌលសីមា ខេត្តកោះកុង
- ស្រុកព្រៃនប់ ខេត្តព្រះសីហនុ

ដូចមានចែងនៅក្នុង CARP: "ស្រុកព្រៃនប់ និងមណ្ឌលសីមា ត្រូវបានជ្រើសរើសជាស្រុកសាកល្បងនៅក្នុងការពិគ្រោះយោបល់រវាងក្រសួងបរិស្ថាន និងអាជ្ញាធរខេត្ត និងស្រុក នៅក្នុងតំបន់ឆ្នេរ នាយកដ្ឋានប្រែប្រួលអាកាសធាតុ និងទីប្រឹក្សាជាតិ និងអន្តរជាតិ។ ការជ្រើសរើសនេះបានផ្អែកលើប្រការដែលថា ទាំងទីកន្លែងនៅជាប់នឹងឆ្នេរសមុទ្រ ដែលភាគច្រើនផ្សំដោយទីទំនាប គឺជាកន្លែងដែលងាយរងគ្រោះជាខ្លាំងពីកំណើនកំពស់ទឹកសមុទ្រ ព្យុះសមុទ្រ ការជ្រាបចូលនៃទឹកប្រៃ និង ខ្យល់ព្យុះត្រូពិក។"

ឃុំទាំងប្រាំបីដូចខាងក្រោមនេះនៅក្នុងស្រុកចំនួនពីរត្រូវបានជ្រើសរើសជាឃុំគោលដៅ៖

- ឃុំពាមក្រសោប និងទួលគគីរ ស្រុកមណ្ឌលសីមា ខេត្តកោះកុង
- ឃុំទឹកថ្លា ទឹកល្អក់ សាមគ្គី ទួលទទឹង អូរឧកញ៉ាហេង និងព្រៃនប់ នៃស្រុកព្រៃនប់ ខេត្តព្រះសីហនុ

ការជ្រើសយកឃុំទាំងនេះបានផ្អែកលើកត្តាដែលថា ឃុំទាំងនេះស្ថិតនៅជាប់ខ្សែឆ្នេរសមុទ្រ ដែលភាគច្រើនជាទីទំនាប ដូច្នេះងាយរងគ្រោះពីកំណើនកំពស់ទឹកសមុទ្រ ការជ្រាបចូលនៃទឹកប្រៃ និងព្យុះត្រូពិក។ ភាគច្រើនបំផុតនៃប្រភពសម្រាប់ការចិញ្ចឹមជីវិតសម្រាប់សហគមន៍គោលដៅទាំងប្រាំមួយនៅព្រៃនប់ គឺការដាំដំណាំ ភាគច្រើនជាដំណាំស្រូវ។ ប្រភពដទៃទៀតរួមគ្នារួមចំណែកប្រមាណ ២៥% ឬតិចជាងនេះ។ ប្រភពចំបងនៃការចិញ្ចឹមជីវិតនៅឃុំពាមក្រសោប គឺការនេសាទ។ ទោះជាយ៉ាងណាក៏ដោយ ទេសចរណ៍កំពុងតែមានតួនាទីកាន់តែសំខាន់ផងដែរ (រហូតដល់ ២៥% នៃប្រាក់ចំណូលសរុបប្រចាំគ្រួសារ ក្នុងនោះ ១០% បានពីសេវាដឹកភ្ញៀវតាមទូក និង១៥% បានពីការលក់ប្រតិបត្តិការ)។ នៅឃុំទួលគគីរ ប្រភពចំបងនៃប្រាក់ចំណូលគឺការដាំដំណាំ (៥០% នៃប្រាក់ចំណូលប្រចាំគ្រួសារបានពីកសិផល ៣០% បានពីការចិញ្ចឹមសត្វ និងនេសាទ និង ១០% បានពីការលក់ពលកម្ម)។

<u>ស្រុកមណ្ឌលសីមា ខេត្តកោះកុង</u>

យោងតាមព័ត៌មានថ្មីៗបំផុតអំពីសហគមន៍នៅមណ្ឌលសីមា ចំនួនគ្រួសារសរុបគឺ ១.៨៨៣ ដោយមានចំនួនប្រជាជនសរុប ៩.១៥២នាក់។ ជិត ៩៥% នៃអ្នកភូមិទាំងអស់ដែលរស់នៅក្នុងឃុំពាមក្រសោមពឹងផ្អែកលើការនេសាទសម្រាប់ជារបរចិញ្ចឹមជីវិត។ បន្ទាប់ពីមានកិច្ចប្រឹងប្រែងរបស់រដ្ឋាភិបាលដើម្បីបញ្ឈប់ការបំផ្លាញព្រៃកោងកាង ប្រជាជនជាច្រើននៅក្នុងមូលដ្ឋានបានប្តូរមុខរបរ ទៅចិញ្ចឹមមាន់ និងទា រកក្តាម និងខ្យង នេសាទ ជំនួញខ្នាតតូច បរបាញ់ បម្រើសេវាទូកតូចៗ ជួសជុលទូក និងឧបករណ៍នេសាទ ក្រងស្លឹក កែច្នៃផលនេសាទ និងជួសជុលផ្ទះ។

<u>ស្រុកព្រៃនប់ ខេត្តព្រះសីហនុ</u>

ព្រៃនប់មាន ១៨.៤៤៤គ្រួសារ ដែលមានប្រជាជនសរុប ៩៣.១៤១នាក់។ ស្រុកនេះស្ថិតនៅក្នុងទីទំនាបដែលមានផ្ទៃដីសរុប ១០.០០០ហិកតា ប្រើប្រាស់សម្រាប់ការដាំដំណាំ និងមានប្រព័ន្ធទំនប់ទឹកប្រៃមួយ។ ប្រព័ន្ធទំនប់នេះត្រូវបានស្តារឡើងវិញអស់រយៈពេលបួនឆ្នាំ តាមរយៈទីភ្នាក់ងារអភិវឌ្ឍន៍បារាំង នៃមូលនិធិបារាំងដើម្បីអភិវឌ្ឍន៍ (AFD)។

ចំពោះព័ត៌មានពិស្តារ អំពីស្ថានភាពនៃរបរចិញ្ចឹមជីវិត នៃសហគមន៍គោលដៅ សូមអាន "ការវាយតម្លៃភាពងាយរងគ្រោះ និងហានិភ័យរបស់សហគមន៍ពីការប្រែប្រួលអាកាសធាតុ ក្នុតំបន់ឆ្នេរកម្ពុជា" ខែ តុលា ឆ្នាំ ២០១២។

## ផែនទីឃុំគោលដៅនៃគម្រោង CARP




| | | |
|---|---|---|
| ឃុំ | ០៥០២: | ឃុំពាមក្រសោប ស្រុកមណ្ឌលសីមា |
| | ០៥០៣: | ឃុំទទួលគគីរ ស្រុកមណ្ឌលសីមា |
| | ០២០៦: | ឃុំអូរឧកញ៉ាហេង ស្រុកព្រៃនប់ |
| | ០២០៧: | ឃុំព្រៃនប់ ស្រុកព្រៃនប់ |
| | ០២០៩: | ឃុំសាមគ្គី ស្រុកព្រៃនប់ |
| | ០២១១: | ឃុំទឹកល្អក់ ស្រុកព្រៃនប់ |
| | ០២១២: | ឃុំទឹកថ្លា ស្រុកព្រៃនប់ |
| | ០២១៣: | ឃុំទួលទទឹង ស្រុកព្រៃនប់ |

*ផែនទីបានមកពីប្រភពខុសៗគ្នា*

*ព្រំប្រទល់រដ្ឋបាល លេខសំគាល់ឃុំ និងឈ្មោះជាភាសាអង់គ្លេស បានមកពីវិទ្យាស្ថានជាតិស្ថិតិ NIS (March 2012)*

# ៣. ការវាយតម្លៃយុទ្ធសាស្ត្រទប់ទល់នៅក្នុងតំបន់ឆ្នេរ

ជំពូកនេះគឺជាសេចក្តីសង្ខេបអំពីការវាយតម្លៃអំពីយុទ្ធសាស្ត្របច្ចុប្បន្ននៅក្នុងឃុំគោលដៅនៃសមាសភាគកសាងផែនការបន្សុំ និងភាពធន់ក្នុងតំបន់ឆ្នេរ (CARP) ទាក់ទងនឹងទឹកជំនន់ គ្រោះរាំងស្ងួត និងព្រឹត្តិការណ៍មិនប្រក្រតីនានា ដែលបានធ្វើឡើងនៅក្នុងឆ្នាំ ២០១២។

គោលបំណងនៃការវាយតម្លៃនេះត្រូវបានចែកចេញជាគោលបំណង ២.២ នៅក្នុង CARP។ ការវាយតម្លៃនេះភាគច្រើនបានផ្អែកលើការពិនិត្យព័ត៌មានពីឯកសារនានាដែលមានស្រាប់។ ទោះជាយ៉ាងណាក៏ដោយ ការស្រាវជ្រាវនៅតាមមូលដ្ឋានក៏បានអនុវត្តផងដែរ ដើម្បីបង្ហាញពីទិន្នន័យជាក់លាក់អំពីអថេរមួយចំនួន។ ចាប់ពីឆ្នាំ ២០០៩មក ការសិក្សាមួយចំនួនអំពីការប្រែប្រួលអាកាសធាតុបានធ្វើឡើងនៅកម្ពុជា។ ទិន្នន័យ ដែលបានតាមរយៈការសិក្សានេះត្រូវបានប្រើប្រាស់ទូលំទូលាយជាមួយទិន្នន័យដែលប្រមូលបានពីទីតាំងជាក់លាក់។ វេទិកាចំណេះដឹងអំពីការបន្សុំ បានធ្វើការសិក្សាប្រហែលគ្នានេះនៅឆ្នាំ២០១០ ក្នុងសហគមន៍គោលដៅចំនួនពីរ (ព្រៃនប់ និងមណ្ឌលសីមា)។[1]

ការវាយតម្លៃទាំងមូល "ការវាយតម្លៃយុទ្ធសាស្ត្រទប់ទល់នៅក្នុងតំបន់ឆ្នេរកម្ពុជា" ខែតុលា ឆ្នាំ២០១២ អាចចម្លងចេញពីវេបសាយ CARP (www.czmcam.org)។

## ២.១ យុទ្ធសាស្ត្រទប់ទល់នៅខេត្តកោះកុងនិងខេត្តព្រះសីហនុ

### កោះកុង–ឃុំពាមក្រសោប និងទួលគគីរ

សហគមន៍នានានៅពាមក្រសោប និងទួលគគីរ បានឆ្លងកាត់បទពិសោធន៍នៃការប្រែប្រួលបរិស្ថានជាបន្តបន្ទាប់ ដូចជា៖

- កំណើនខ្យល់ព្យុះនៅឆ្នេរសមុទ្រ
- គ្រោះរាំងស្ងួត
- ការជ្រាបចូលនៃទឹកប្រៃ
- ការថយចុះនៃសត្វក្នុងសមុទ្រ
- ទឹកអណ្តូង/ទឹកក្រោមដីលែងអាចផឹកបានទៀតហើយ

ក្នុងចំណោមបញ្ហានានា ការប្រែប្រួលទាំងនេះមានន័យថាត្រូវចំណាយយ៉ាងច្រើនដើម្បីបានទឹកស្អាតសម្រាប់អ្នកភូមិ និងនៅសេសសល់ប្រាក់កាសតិចតួចសម្រាប់ពង្រីកបរចិញ្ចឹមជីវិត។ បរចិញ្ចឹមជីវិតបានប្តូរពីការដាំដំណាំ មកជាការប្រមូលផលពីសមុទ្រ ដែលនាំឲ្យមានកំណើនសម្ពាធមកលើធនធានក្នុងទឹក ដែលនាំមកនូវការចំណាយច្រើនជាងមុនលើឧបករណ៍នេសាទផងដែរ។

នៅពាមក្រសោប ការយល់ឃើញរបស់អ្នកភូមិអំពីការប្រែប្រួលនានានៃប្រព័ន្ធអេកូឡូស៊ីបង្ហាញថា ពួកគេបានជួបប្រទះការថយចុះនៃសត្វសមុទ្រ ហើយច្បាប់ដែលហាមឃាត់ការនេសាទពីសំណាក់"អ្នកខាងក្រៅ" មិនត្រូវបានអនុវត្តឡើយ ដោយបង្កសម្ពាធដែលគ្មាននិរន្តរភាពមកលើសត្វសមុទ្រ។ ការបូមយកខ្សាច់ ក៏ត្រូវ

[1]សូមអានរបាយការណ៍ខែ តុលា ឆ្នាំ ២០១២ ដើម្បីយល់បន្ថែមអំពីវាក្យស័ព្ទ និងវិធីប្រមូលទិន្នន័យ និងសេចក្តីសង្ខេបអំពីការស្រាវជ្រាវពីវេទិកាចំណេះដឹងបន្សុំ។

បានកត់សំគាល់ជាមូលហេតុមួយផងដែរ។ អ្នកភូមិចាប់អារម្មណ៍ថា ការអនុវត្តច្បាប់បានកែលម្អលើកិច្ចការពារព្រៃកោងកាង។ ទោះជាយ៉ាងណាក៏ដោយ ឥទ្ធិពលអវិជ្ជមាននៃបញ្ហាទាំងនេះគឺ ពួកគេមិនអាចបរបាញ់ស្វាដូច្នេះបាត់បង់ប្រភពនៃសន្តិសុខស្បៀង។ ដោយសារអ្នកភូមិពាមក្រសោបបានប្តូរទីតាំងមកដីកោះមកដីគោក ឥឡូវនេះអ្នកភូមិអាចមានដីក្រោយផ្ទះសម្រាប់ដាំដំណាំ ដែលអាចឲ្យពួកគេដាំឈើហូបផ្លែ និង បន្លែបង្ការបាន។ ប៉ុន្តែអវត្តមានទឹកសាប គឺជាកត្តាកំហិតលើផលិតផលរបស់ពួកគេ។

ការប្រែប្រួលជាវិជ្ជមានសម្រាប់អ្នកភូមិគឺការពង្រីកអេកូទេសចរណ៍។ ដោយសារតែកំណើនការយល់ដឹងអំពីលទ្ធភាពខាងទេសចរណ៍ អ្នកភូមិបានចាត់ចែងខ្លួនឯងតាមវិធីមួយ ដែលឥឡូវនេះទេសចរណ៍បានក្លាយជាប្រភពនៃប្រាក់ចំណូល ដែលកាលពីមុនពួកគេត្រូវធ្វើចំណាកស្រុកទៅស្វែងរកប្រភពប្រាក់ចំណូលផ្សេង។ អ្នកភូមិមានយុទ្ធសាស្ត្រទប់ទល់មួយចំនួននៅក្នុងករណីនៃមុខសញ្ញាមហន្តរាយធាតុអាកាសខុសៗគ្នា។ ពួកគេបានចាប់ផ្តើមសង់ផ្ទះទាបៗ ដែលជួយការពារពីការខូចខាតដោយសារខ្យល់ព្យុះ។ ដោយសារហេតុផលដូចគ្នានេះ ពួកគេបានដាំដើមឈើដើម្បីការពារផ្ទះ និងដែលផ្តល់ភាពត្រជាក់ផងដែរនៅក្នុងពេលដែលមានកំណើនចំនួនថ្ងៃក្តៅ។ លើសពីនេះ ទំនប់ត្រូវបានសាងសង់ដើម្បីការពារភូមិទល់នឹងទឹកជំនន់។ ទោះជាយ៉ាងណាក៏ដោយ ទំនប់ទាំងនោះមិនខ្ពស់គ្រប់គ្រាន់ដើម្បីការពារទល់នឹងទឹកជំនន់ដែលកាន់តែធ្ងន់ធ្ងរឡើយ។

គ្រោះរាំងស្ងួតៈ ក្រុមប្រឹក្សាឃុំមានវិស័យជាការយកចិត្តទុកដាក់ដូចតទៅ៖ (១) ដើម្បីធានាឲ្យមានទឹកគ្រប់គ្រាន់សម្រាប់សហគមន៍ ដោយសាងសង់អាងដើម្បីស្តុកទឹកសម្រាប់ផឹក (២) ត្រៀមថ្នាំសង្កូវសម្រាប់សហគមន៍ទាំងសម្រាប់មនុស្ស និងសត្វ (៣) ត្រៀមប្រភពទឹក និង (៤) ធានាការត្រៀមបង្ការករណីមានភ្លើងព្រៃ។ គណៈកម្មការសហគមន៍បានដឹងច្បាស់អំពីហានិភ័យនៃជម្ងឺ ក្នុងចំណោមសត្វនៅក្នុងពេលមានគ្រោះរាំងស្ងួត និងមានវិធីដើម្បីធានាថា ប្រសិនបើសត្វណាមួយឈឺ នៅពេលនោះពួកគេនឹងដុតសាកសពសត្វនោះចោលភ្លាម ដើម្បីទប់ស្កាត់ការរាលដាលនៃជម្ងឺ។ គណៈកម្មការសហគមន៍មានថវិកាដើម្បីប្រើប្រាស់នៅក្នុងករណីមានគ្រោះរាំងស្ងួត ដែលរួមទាំងការទិញថ្នាំ និងកូនឈើសម្រាប់ដាំ។ ចំពោះថវិកានេះ គណៈកម្មការសហគមន៍បានដាក់ពាក្យសុំមូលនិធិគាំទ្រពីអាជ្ញាធរស្រុក។ យោងតាមគណៈកម្មការសហគមន៍ សកម្មភាពទាំងនេះបាននាំមកនូវការដាំដើមឈើលើផ្ទៃដី ១៦០ហិកតា សត្វចិញ្ចឹមតិចជាង ៥០% បានងាប់នៅក្នុងរដូវរាំងស្ងួត និងបានកសាងអណ្តូងទឹកសហគមន៍មួយផងដែរ។

ការជ្រាបចូលនៃទឹកប្រៃ/ជំនន់៖ គណៈកម្មការសហគមន៍បានសង់ទំនប់ការពារទឹកប្រៃ 5គ.ម ដោយប្រើប្រាស់មូលនិធិសហគមន៍ និងវិភាគទានមិនមែនសាច់ប្រាក់ពីអ្នកភូមិ។ លើសពីនេះ គណៈកម្មការសហគមន៍បានផ្តល់ការណែនាំដល់គ្រួសារនានាឲ្យសង់ទួលតូចៗ សម្រាប់ផ្តល់ជាជម្រកសម្រាប់សត្វ។ ពួកគេក៏ត្រៀមទុកសម្រាប់ផ្ទុកទ្រព្យសម្បត្តិរបស់អ្នកភូមិផងដែរ។ គណៈកម្មការសហគមន៍ក៏ណែនាំអ្នកភូមិអំពីសារៈសំខាន់នៃការសំអាតផ្ទះផងដែរនៅក្នុងពេល និងក្រោយពេលទឹកជំនន់កើតឡើង។ គណៈកម្មការនេះផ្តល់ការគាំទ្រហិរញ្ញវត្ថុដល់អ្នកភូមិនានា ដើម្បីជួសជុលផ្ទះដែលខូចខាត។

ខ្យល់ព្យុះ និងរន្ទះ៖ គណៈកម្មាធិការសហគមន៍មានយុទ្ធសាស្ត្រទប់ទល់ក្នុងកម្រិតកំណត់សម្រាប់ព្យុះ និងរន្ទះ។ នៅឆ្នាំ២០១១ ផ្ទះចំនួន ៣៨ខ្នង និងព្រៃកោងកាងទំហំ១៤.០០០ម² ត្រូវបានបំផ្លាញ ទូកនេសាទ ២គ្រឿងលិច និងមានភ្លើងឆេះព្រៃប្រមាណ ៣០លើក។ គណៈកម្មការសហគមន៍ណែនាំអ្នកភូមិឲ្យស្តាប់វិទ្យុ និងទូរទស្សន៍ ដើម្បីទទួលបានព័ត៌មានថ្មីៗអំពីមុខសញ្ញាគ្រោះមហន្តរាយ។ នៅពេលព្យុះបោកបក់មកលើ

សហគមន៍នេះ អ្នកភូមិទទួលការណែនាំឲ្យស្វែងរកកន្លែងជ្រក។ យោងតាមគណៈកម្មការសហគមន៍ គ្មានអ្នកនេសាទណាម្នាក់ចេញទៅសមុទ្រឡើយនៅពេលមានព្យុះ ដោយសារតែការចែករម្លែកព័ត៌មាននេះ។ គ្រួសារចំនួន ៩០% ឥឡូវនេះស្តាប់វិទ្យុ ឬ មើលទូរទស្សន៍ និង គ្រួសារ ១០% បានទិញឧបករណ៍ការពាររន្ទះ។

ឃុំទួលគគីរស្ថិតនៅចូលជ្រៅក្នុងដែនដីគោកជាងពាមក្រសោប ប៉ុន្តែអ្នកភូមិតាចាតបានជួបប្រទះនឹងការថយចុះធ្ងន់ធ្ងរនៃធនធានទឹកសាប ដោយសារតែប្រភពទឹកសាបរីងស្ងួតជារៀងរាល់ឆ្នាំ។ ការថយចុះនេះបង្កផលវិបាកមួយចំនួន។ យោងតាមអ្នកភូមិ សត្វមានជីវិតនៅក្នុងទឹកសាបបានថយចុះជាខ្លាំង។ វដ្តទឹកបានធ្វើឲ្យទឹកសាបមានតែក្នុងរយៈពេលខ្លី ដោយសារតែគ្រោះរាំងស្ងួតកើតមានញឹកញាប់ជាងមុន។ អ្នកភូមិចាប់អារម្មណ៍អំពីការថយចុះនៃទឹកសាប ដែលជាផលវិបាកនៃការបាត់បង់ព្រៃឈើនៅក្នុងតំបន់ជិត បឹង និងស្ទឹងនោះ។ ចំពោះអ្នកភូមិតាចាត ព្រៃកោងកាងបានបាត់បង់ជាច្រើន ដោយសារតែសម្បទានព្រៃឈើដែលត្រូវបានផ្តល់ទៅឲ្យក្រុមហ៊ុននានាជាច្រើន។ ទោះជាយ៉ាងណាក៏ដោយ អ្នកភូមិខ្លួនឯងក៏បានចូលរួមនៅក្នុងការបំផ្លាញព្រៃកោងកាងផងដែរ ដែលជាផ្នែកមួយនៃការផលិតធ្យូង។ លើសពីនេះ អ្នកភូមិប្រើប្រាស់បច្ចេកទេសកសិកម្មពនេចរដើម្បីបង្កើតដីកសិកម្ម។

ដើម្បីទប់ទល់នឹងមុខសញ្ញាគ្រោះមហន្តរាយធាតុអាកាសដែលកើតមានកាន់តែញឹកញាប់ជាងមុន តាមរយៈការគាំទ្រហិរញ្ញវត្ថុពីកម្មវិធីក្រូហិរញ្ញវត្ថុ ភូមិតាចាតបានសង់ស្រះដើម្បីស្តុកទឹកទុកសម្រាប់ស្រោចដំណាំ និងសម្រាប់សត្វផឹកនៅក្នុងពេលរាំងស្ងួត។ ក្នុងករណីសំណឹកដីនៅក្នុងរដូវវស្សា តាមរយៈការបណ្តុះបណ្តាលអំពីបច្ចេកទេសកសិកម្ម អ្នកភូមិបានចាប់ផ្តើមប្រើប្រាស់ជីគីមី និងថ្នាំគីមីកសិកម្មដើម្បីបង្កើនផលដំណាំ។ អ្នកភូមិក៏បានចាប់ផ្តើមនេសាទផងដែរ ដើម្បីរកអាហារបន្ថែមសម្រាប់បំពេញការខ្វះខាត។

គ្រោះរាំងស្ងួត៖ គណៈកម្មការសហគមន៍ស្តារប្រព័ន្ធប្រឡាយដើម្បីការពារប្រភពទឹកផឹក និងធ្វើឲ្យប្រាកដថាមានសង់របងការពារនៅជុំវិញស្រះ។

ការជ្រាបចូលនៃទឹកប្រៃ៖ ក្នុងករណីធ្ងន់ធ្ងរ អ្នកភូមិត្រូវបានជន្លៀសទៅរកជម្រកសុវត្ថិភាព។ គណៈកម្មការចាត់ចែងដើម្បីឲ្យប្រាកដថា ទាំងនៅមុន ក្នុងអំឡុងពេល និងនៅក្រោយពេលជន្លៀស ប្រព័ន្ធទំនប់ការពារទឹកប្រៃនៅតែអាចដំណើរការបាន។ ប្រសិនបើមានការខូចខាត អ្នកភូមិបានចាត់ចែងជួសជុលភ្លាម។

ខ្យល់ព្យុះ និងរន្ទះ៖ អាទិភាពមួយសម្រាប់គណៈកម្មការសហគមន៍គឺត្រូវឲ្យអ្នកភូមិបានទទួលព័ត៌មានថ្មីៗអំពីព្យុះ តាមរយៈទូរទស្សន៍ និងវិទ្យុ និងធ្វើឲ្យប្រាកដថា ពួកគេត្រៀមខ្លួនជាស្រេចដើម្បីជន្លៀសទៅទីជម្រកសុវត្ថិភាព។ គណៈកម្មការបានបង្កើនការយល់ដឹងអំពីសារៈសំខាន់នៃការមិនកាប់ដើមឈើនៅជុំវិញភូមិ ដោយសារវាការពារគ្រួសារនានាទល់នឹងខ្យល់ព្យុះ។ ចំពោះករណីរន្ទះ អ្នកភូមិបានទិញបរិក្ខារការពាររន្ទះ។

ការធ្លាក់ភ្លៀងខ្លាំង៖ គណៈកម្មការសហគមន៍កំណត់និយមន័យការធ្លាក់ភ្លៀងខ្លាំងជាការធ្លាក់ភ្លៀងអំឡុងពេលពីរខែជាប់គ្នា។ ចំពោះអ្នកភូមិ ភ្លៀងបែបនេះធ្វើឲ្យខូចកសិផល ដោយបង្កើនសត្វចង្រៃដែលបំផ្លាញដំណាំ។ គណៈកម្មការសហគមន៍ទាក់ទងមន្ត្រីកសិកម្មស្រុក ភ្លាមៗនៅពេលដែលពួកគេបានរកឃើញបញ្ហានៃការរាតត្បាតនៃសត្វចង្រៃមកលើដំណាំ។ យោងតាមគណៈកម្មការសហគមន៍ ការផ្តោតលើកត្តាចង្រៃដែលបំផ្លាញដំណាំ និងយន្តការនានាដើម្បីប្រឆាំងនឹងកត្តានេះបានធានាថា ដំណាំ ៧០%មិនខូចខាតឡើយ។

**ខេត្តព្រះសីហនុ៖ ឃុំព្រៃនប់ និងឃុំអូរឧកញ៉ាហេង**

ដូចនៅកោះកុងដែរ ឃុំព្រៃនប់ និងអូរឧកញ៉ាហេង បានជួបនឹងការប្រែប្រួលបរិស្ថានមួយចំនួនជាបន្តបន្ទាប់ ដែលបញ្ហាខ្លះៗមានដូចជា៖

- រដូវវស្សាមានរយៈពេលវែងជាមុន
- ព្យុះកាន់តែខ្លាំងនៅក្នុងរដូវវស្សា
- បញ្ហាសុខភាពសត្វចិញ្ចឹម ដោយសារតែកំដៅកាន់តែខ្លាំងជាងមុន
- ប្រព័ន្ធអេកូឡូស៊ីរួមចំណែកកាន់តែតិចជាងមុននៅក្នុងសន្តិសុខស្បៀង
- ការថយចុះនៃជីជាតិដី

ជាផលវិបាកនៃផលប៉ះពាល់ទាំងនេះ កសិករត្រូវបង្ខំចិត្តបង្កើនការប្រើប្រាស់ថ្នាំគីមីកសិកម្ម ថ្នាំកំចាត់ស្មៅ និងជីគីមី។ ការប្រែប្រួលមួយទៀតគឺថា កសិករត្រូវបង្ខំចិត្តប្តូរទៅធ្វើអាជីវកម្មធនធានធម្មជាតិផ្សេងទៀត។

សម្ពាធលើធនធានជលផលសមុទ្របន្តតាមអត្រាដែលគ្មាននិរន្តរភាព។ បឹងក៏ស្ថិតក្រោមសម្ពាធកាន់តែខ្លាំងដោយសារគ្រួសារកាន់តែច្រើនឡើងព្យាយាមបំពេញការខាតបង់របស់ពួកគេតាមរយៈការនេសាទក្នុងបឹង។ ផលវិបាកបន្ថែមទៀតសម្រាប់បច្ចុប្បន្នគឺការថយចុះនៃសាមគ្គីភាពនៅក្នុងឃុំ ដោយសារតែកំណើនភាពប្រកួតប្រជែងដើម្បីធនធាន។ គ្មានអ្នកភូមិណាម្នាក់បានចូលរួមក្នុងសកម្មភាពអភិវឌ្ឍន៍ណាមួយក្នុងតំបន់នេះឡើយ។

នៅភូមិបើកក្រុង នៃឃុំព្រៃនប់ មានយុទ្ធសាស្ត្រទប់ទល់ខុសៗគ្នាមួយចំនួនដែលបានអនុវត្ត។ ក្នុងករណីទឹកជំនន់ ដែលកើតឡើង ២ ទៅ ៣ ដងក្នុងមួយឆ្នាំ អ្នកភូមិបើកទ្វារទឹកទំនប់ ដើម្បីបន្ទាបកំពស់ទឹក។ ទោះជាយ៉ាងណាក៏ដោយ ការធ្វើបែបនេះបង្កផលប៉ះពាល់អវិជ្ជមានមកលើបរិមាណទឹកសម្រាប់កសិកម្ម។ អ្នកភូមិបានដឹងអំពីហានិភ័យសុខភាពដែលពាក់ព័ន្ធនឹងទឹកជំនន់។ ដូច្នេះក្រោយពេលទឹកជំនន់ អ្នកភូមិបានសំអាតទីធ្លាជុំវិញភ្លាម។ អ្នកភូមិមិនបានចាត់ទុកយុទ្ធសាស្ត្រទប់ទល់នេះថាមាននិរន្តរភាពឡើយ ហើយពួកគេនៅតែប្រឈមនឹងការបាត់បង់នៅពេលមានទឹកជំនន់។

ព្យុះ៖ ដូចនៅពាមក្រសោបដែរ អ្នកភូមិបានទទួលការណែនាំឲ្យស្តាប់ស្តាប់វិទ្យុ និងមើលទូរទស្សន៍ដើម្បីបានទទួលព័ត៌មានថ្មីៗ និងមិនទៅនេសាទឡើយនៅពេលមានព្យុះធ្ងន់ធ្ងរ។ មុនពេលមានព្យុះ អ្នកភូមិខ្លះបានផ្តួលស្រូវជាមុនដើម្បីជៀសវាងដាច់ដើមស្រូវដោយសារតែកម្លាំងខ្យល់។

ការជ្រាបចូលនៃទឹកប្រៃ៖ យុទ្ធសាស្ត្រទប់ទល់មានប្រហែលគ្នានឹងយុទ្ធសាស្ត្រនៅពាមក្រសោបដែរ។ ការសង់ទំនប់ដើម្បីការពារការជ្រាបចូលនៃទឹកប្រៃគឺជាយុទ្ធសាស្ត្រស្នូលមួយនៅក្នុងសហគមន៍នានា ប៉ុន្តែក៏មានត្រៀមទុកសម្រាប់ការជន្លៀសអ្នកភូមិ និងទ្រព្យសម្បត្តិផងដែរ។

**ការសន្និដ្ឋានអំពីទិន្នន័យពីខេត្តកោះកុង**

នៅក្នុងសហគមន៍គោលដៅក្នុងខេត្តកោះកុង អ្នកភូមិចាប់អារម្មណ៍អំពីនិន្នាការច្បាស់លាស់នៃការប្រែប្រួលរបបធាតុអាកាស ដែលនឹងនាំឲ្យមានមុខសញ្ញាគ្រោះមហន្តរាយធាតុអាកាសកាន់តែញឹកញាប់ជាងមុន។ គណៈកម្មការសហគមន៍នៅពាមក្រសោបទំនងជាមានការចាប់អារម្មណ៍កាន់តែពិស្តារជាង អំពីការប្រែប្រួលអាកាសធាតុ និងការយល់ដឹងអំពីវិធីដែលគណៈកម្មការសហគមន៍អាចគាំទ្រអ្នកភូមិក្នុងការអនុវត្តយុទ្ធសាស្ត្រទប់ទល់ដែលមានស្រាប់ទាំងនេះ។ គណៈកម្មការសហគមន៍នៅទួលគគីរបានចូលរួមយ៉ាងសកម្មជាមួយមន្ត្រីកសិកម្មខេត្ត ដែលបានផ្តល់ការណែនាំដល់សហគមន៍នៅក្នុងការប្រឆាំងនឹងការផ្ទុះនៃកត្តាចង្រៃមកលើដំណាំ

ដោយផ្តល់លទ្ធផលវិជ្ជមាន។ ជាទូទៅ ចាប់ពីក្រុមប្រឹក្សាឃុំនិងថ្នាក់ក្រោមៗ មានការយល់ដឹងអំពីសារៈសំខាន់នៃការចែករម្លែកព័ត៌មាន។

**ការសន្និដ្ឋានអំពីទិន្នន័យក្នុងខេត្តព្រះសីហនុ**

ធៀបនឹងកោះកុង សហគមន៍គោលដៅនៅខេត្តព្រះសីហនុមានយន្តការបន្សាំរឹងមាំជាង ដោយមានប្រព័ន្ធទ្វារទឹកយ៉ាងធំដែលសង់ដោយទីភ្នាក់ងារអភិវឌ្ឍន៍បារាំង (ADF)។ ទោះជាយ៉ាងណាក៏ដោយ ប្រព័ន្ធទ្វារទឹកនេះនៅត្រូវការកែលម្អជាបន្ថែម។ ទិន្នន័យដែលប្រមូលបានឆ្លុះបញ្ចាំងអំពីការយល់ដឹងទាបជាងអំពីការប្រែប្រួលអាកាសធាតុ ធៀបនឹងទិន្នន័យដែលប្រមូលបានពីកោះកុង និងធៀបជាមួយការសិក្សា KAP នៅទូទាំងប្រទេសផងដែរ (សូមអានរបាយការណ៍វាយតម្លៃទាំងមូល ក្នុងជំពូក ១)។ កម្រិតនៃការចែករម្លែកព័ត៌មាននៅទាប ហើយកម្រិតនេះទំនងជារឹតតែទាបជាងនៅពាមក្រសោប។

## ២.៣ ការវាយតម្លៃយុទ្ធសាស្រ្តទប់ទល់

បញ្ហាទូទៅមួយនៃយុទ្ធសាស្ត្រទប់ទល់នៅទីកន្លែង(ខេត្ត)ទាំងពីរគឺថា ពួកគេទំនងជាខ្វះទស្សនៈវិស័យសម្រាប់រយៈពេលវែង។ ពួកគេទំនងជាផ្តោតលើការរក្សាស្ថានភាពដែលមានស្រាប់ ជាងលើការកែលម្អរបរចិញ្ចឹមជីវិតនៅក្នុងរយៈពេលវែង។ លើសពីនេះ យុទ្ធសាស្ត្រទប់ទល់ខ្លះបានបង្កើនបន្ទុកមកលើប្រព័ន្ធអេកូឡូស៊ី ដោយសារតែទស្សនវិស័យរយៈពេលខ្លី ដូច្នេះធ្វើឲ្យស្ថានភាពកាន់តែអាក្រក់នៅក្នុងរយៈពេលវែង។ ឧទាហរណ៍មួយគឺនៅពេលអ្នកភូមិប្តូរអាជីពពីដាំដំណាំ ទៅធ្វើនេសាទ ដោយសារតែការប្រែប្រួលរបបធាតុអាកាស ពួកគេបង្កើនសម្ពាធមកលើធនធានជលផល ដូចដែលបានកើតឡើងនៅព្រៃនប់។ ដូច្នេះ គួរផ្តោតការយកចិត្តទុកដាក់លើការបង្កើនការយល់ដឹង ដើម្បីបង្ហាញពីទំនាក់ទំនងគ្នារវាងយុទ្ធសាស្ត្រទប់ទល់ នឹងការប្រែប្រួលអាកាសធាតុ និងបញ្ហាអភិវឌ្ឍន៍ដទៃទៀត។

ការកំណត់រកកន្លែងសុវត្ថិភាពជួយធានាសុវត្ថិភាពចំពោះមុខរបស់អ្នកភូមិ។ តាមធម្មតា យុទ្ធសាស្ត្រសមស្របបំផុតគួរតែអ្នកភូមិអាចសង់ផ្ទះតាមវិធី ដែលពួកគេអាចស្នាក់ក្នុងផ្ទះទាំងនោះនៅក្នុងពេលមានព្យុះ និងមុខសញ្ញាគ្រោះមហន្តរាយធាតុអាកាសដទៃទៀត។ យុទ្ធសាស្ត្រទប់ទល់តាមរយៈទីសុវត្ថិភាពគួរតែបានកែលម្អជាបន្ថែម ទាក់ទងនឹងស្ថានភាពរូបវន្តនៃទីជុំវិញ និងការសម្របសម្រួលក្នុងការដឹកជញ្ជូនអ្នកភូមិទៅទីមានសុវត្ថិភាព និងប្រព័ន្ធព័ត៌មានផងដែរ ដែលផ្តល់ដំណឹងដល់អ្នកភូមិដើម្បីត្រៀមខ្លួនសម្រាប់ការជន្លៀស។

ការសាងសង់ និងថែរក្សាប្រព័ន្ធទំនប់ ទោះបីមិនអាចទប់ស្កាត់ទឹកជំនន់ទាំងស្រុងបានក៏ដោយ អ្នកភូមិនៅតែត្រូវបានចាត់ទុកថាជាយុទ្ធសាស្ត្រទប់ទល់មួយដ៏សំខាន់ផងដែរ។ កម្រិតបច្ចេកទេសរបស់ប្រព័ន្ធទំនប់នេះទំនងជាមានមានលក្ខណៈបូរាណ។ ទំនប់មិនទំនងជាត្រូវបានអភិវឌ្ឍន៍ជាបន្ថែមឡើយ។ សហគមន៍ទំនងជាបានជួសជុលមកត្រឹមស្ថានភាពដែលមានមុនពេលខូចខាត។ ដូច្នេះ យុទ្ធសាស្ត្រទប់ទល់នេះគួរតែបានកែលម្អនៅកម្រិតបច្ចេកទេស។ ការកែលម្អបែបនេះមានការទាក់ទងជិតស្និទ្ធជាមួយវត្តមានធនធានហិរញ្ញវត្ថុ។ ដូច្នេះ ចាំបាច់ត្រូវស្វែងរកមូលនិធិសម្រាប់ការកែលម្អ។ លើសពីនេះ សមត្ថភាពបច្ចេកទេស នៃការកសាងប្រព័ន្ធទំនប់ទាំងនេះត្រូវតែបានបង្កើតនៅកម្រិតស្ថាប័ន។

បញ្ហាមួយសម្រាប់កសិករគឺផលដំណាំស្រូវរបស់ពួកគេត្រូវខូចនៅពេលមានព្យុះ។ អ្នកខ្លះប្រើដើមឫស្សីដើម្បីផ្តួលស្រូវជាមុនដើម្បីកុំឲ្យបាក់ពេលខ្យល់បក់មក។ ទោះបីវិធីនេះមានលក្ខណៈបូរាណក៏ដោយ យុទ្ធសាស្ត្រ

ទប់ទល់នេះទំនងជាមានប្រសិទ្ធភាព និងត្រូវបានកសិករប្រើប្រាស់ទូលំទូលាយនៅក្នុងសហគមន៍គោលដៅ។ ការប្រើប្រាស់សារជាតុគីមីដើម្បីប្រឆាំងសត្វចង្រៃនៅលើដំណាំ បណ្តាលពីការធ្លាក់ភ្លៀងខ្លាំង ទំនងជាមានប្រសិទ្ធភាពជាបង្គួរ ដូចជានៅក្នុងភូមិទួលគគីរ ដែលគណៈកម្មការសហគមន៍បានប្រើប្រាស់សារជាតុគីមីដើម្បីសង្គ្រោះដំណាំស្រូវបាន ៧០% ដែលស្ថិតក្រោមការវាយប្រហារពីកត្តាចង្រៃ។ អត្រាគង់វង់នេះអាស្រ័យលើកត្តាចំនួនពីរគឺ៖ ១) ចំណេះដឹងអំពីរបៀបប្រើប្រាស់សារជាតុគីមីឲ្យមានប្រសិទ្ធភាព និង ២) វត្តមានសារជាតុគីមី។

យុទ្ធសាស្ត្រទប់ទល់ ដែលបានអធិប្បាយខាងលើកំពុងប្រើប្រាស់នៅក្នុងសហគមន៍គោលដៅទាំងបី។ ប៉ុន្តែ សហគមន៍នៅពាមក្រសោបទំនងជាបានចាត់ចែងល្អជាងនៅសហគមន៍ដទៃ។

ចំណេះដឹងទូទៅអំពីការប្រែប្រួលអាកាសធាតុនៅពាមក្រសោបទំនងជាច្បាស់លាស់ជាងនៅឃុំដទៃ។ ឃុំសាមគ្គីគឺជាឃុំតែមួយដែលការប្រែប្រួលអាកាសធាតុត្រូវបានរួមបញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍ (CDP) ហើយគណៈកម្មការមួយស្តីពីការត្រៀមបង្ការគ្រោះមហន្តរាយ និងសង្គ្រោះត្រូវបានបង្កើត។ ប៉ុន្តែក្រៅពីការស្វែងកន្លែងដែលមានសុវត្ថិភាព ដែលក៏បានអនុវត្តនៅឃុំដទៃ គណៈកម្មការនេះទំនងជាមានយោបល់ក្នុងកម្រិតកំណត់។

ផ្អែកតាមប្រព័ន្ធទ្វារទឹកដែលបានស្តារ គេអាចសន្និដ្ឋានថា ព្រៃនប់មានសមត្ថភាពបន្សុំ បានរឹងមាំជាងធៀបនឹងមណ្ឌលសីមា។ គេគួរតែគិតផងដែរថា ប្រព័ន្ធទ្វារទឹកពុំអាចទប់ស្កាត់ទាំងស្រុងមិនឲ្យទឹកហូរពីលើខ្នងទំនប់បានឡើយ។ ប៉ុន្តែ នេះក៏នៅតែជាសមត្ថភាពបន្សុំមួយដែលគាំទ្រដល់អ្នកភូមិនៅព្រៃនប់ សូម្បីតែប្រព័ន្ធទ្វារទឹកត្រូវការអភិវឌ្ឍន៍បន្ថែមក៏ដោយ។ ហានិភ័យគឺអភិវឌ្ឍន៍យន្តការបន្សុំ ដែលធ្វើឲ្យសហគមន៍គោលដៅគិតថាពួកគេបានដោះស្រាយរាល់បញ្ហាដែលទាក់ទងនឹងមុខសញ្ញាមហន្តរាយជាតុអាកាស។ បញ្ហានេះអាចនាំឲ្យសហគមន៍គោលដៅលែងសូវសកម្មទាក់ទងនឹងការអភិវឌ្ឍយុទ្ធសាស្ត្រទប់ទល់របស់ខ្លួន។

បញ្ហាមួយផ្សេងទៀតគឺកង្វះសមត្ថភាពស្ថាប័នសម្រាប់ទ្រទ្រង់សហគមន៍។ សមត្ថភាពភាគច្រើនដែលមានអនុវត្តច្រើនតែផ្អែកលើការអភិវឌ្ឍហេដ្ឋារចនសម្ព័ន្ធដូចជា ប្រព័ន្ធទ្វារទឹកនៅព្រៃនប់។ ប៉ុន្តែ គេចាំបាច់ត្រូវបង្កើតនសមត្ថភាពបន្ថែមទៀតលើចំណេះដឹងបច្ចេកទេស ដូចជា ការបណ្តុះបណ្តាលធនធានមនុស្សនៅថ្នាក់ខេត្ត ដែលអាចជួយគាំទ្រសហគមន៍នៅក្នុងករណីមានផលប៉ះពាល់កាន់តែស្មុគស្មាញពីមុខសញ្ញាមហន្តរាយជាតុអាកាស។

កម្រិតនៃការចាត់ចែងដូចពោលខាងលើនៅក្នុងក្រុមប្រឹក្សាឃុំ និងនៅកម្រិតគណៈកម្មការសហគមន៍គឺជាកត្តាសំខាន់មួយ។ ឧទាហរណ៍មួយគឺការអភិវឌ្ឍ និងថែរក្សាប្រព័ន្ធទំនប់នៅក្នុងសហគមន៍គោលដៅ។ ប្រការសំខាន់គឺត្រូវមានការកំណត់ឲ្យបានច្បាស់លាស់ ថាតើអ្នកណាមានភារៈទទួលខុសត្រូវក្នុងការអភិវឌ្ឍន៍ និងថែរក្សាប្រព័ន្ធទំនប់ និងប្រព័ន្ធទ្វារទឹកបែបណា។ នៅពេលដែលធ្វើបែបនេះបានរួចហើយ ជំហានបន្ទាប់ គឺត្រូវធានាថាឲ្យមានចំណេះដឹង និងធនធានសម្រាប់អ្នកពាក់ព័ន្ធ។ នៅក្នុងពេលនេះ ការទទួលខុសត្រូវក្នុងការថែរក្សាទំនប់ត្រូវបានដាក់មកឲ្យគណៈកម្មការសហគមន៍ ប៉ុន្តែពួកគេពុំមានសមត្ថភាពដើម្បីជួសជុលប្រព័ន្ធនេះដើម្បីអាចទប់ទល់នឹងទឹកជំនន់ជារៀងហូតឡើយ។ ប្រការនេះអាចលើកជាសំណួរថាតើគណៈកម្មការសហគមន៍មានសិទ្ធិនៅកម្រិតចាត់ចែងដើម្បីថែរក្សាប្រព័ន្ធទំនប់ឬទេ។

បន្ថែមលើ CARP និងគោលបំណងរបស់ខ្លួន គេនៅពុំទាន់មានរចនាសម្ព័ន្ធរួមមួយសម្រាប់គាំទ្រដល់យុទ្ធសាស្ត្រទប់ទល់នៅឡើយ នៅកម្រិតសហគមន៍នីមួយៗ ដែលប្រការនេះក៏គួរតែចាត់ទុកថាជាបញ្ហាមួយផង

ដែរ។ ដូច្នេះ មុននឹងអភិវឌ្ឍន៍សមត្ថភាពបច្ចេកទេសនៅក្នុងសហគមន៍គោលដៅ ជាការល្អគឺត្រូវផ្តោតការយកចិត្តទុកដាក់លើការបង្កើតសមត្ថភាពចាត់តាំងនៅកម្រិតឃុំផងដែរ។

**ព័ត៌មាន**

បញ្ហាគន្លឹះនៅក្នុងតំបន់ទាំងពីរគឺថា ពួកគេគ្មានប្រព័ន្ធសម្រាប់ការចែករំលែកព័ត៌មានពាក់ព័ន្ធ រវាងអ្នកពាក់ព័ន្ធនានាឡើយ។ យុទ្ធសាស្ត្រទប់ទល់មួយត្រូវតែផ្អែកលើព័ត៌មានច្បាស់លាស់នៅមុន ក្នុងអំឡុងពេល និងក្រោយពេលមានមុខសញ្ញាមហន្តរាយធាតុអាកាស។

ទិន្នន័យពីបញ្ជីសំណួរបង្ហាញច្បាស់លាស់អំពីការយល់ដឹងអំពីប្រភពណា ដែលអ្នកឆ្លើយបានទទួលព័ត៌មានរបស់ពួកគេ ដែលទាក់ទងនឹងមុខសញ្ញាមហន្តរាយធាតុអាកាស។ មកទល់ពេលនេះ វិទ្យុ និងទូរទស្សន៍គឺជាប្រភពចំបងតែពីរ។ លើសពីនេះ អ្នកឆ្លើយបានទទួលព័ត៌មានពីអ្នកជិតខាងខ្លួន និងពីអាជ្ញាធរមូលដ្ឋានប៉ុន្តែក្នុងកម្រិតកំណត់។ មានតែអ្នកឆ្លើយមួយចំនួនតូចបានទទួលព័ត៌មានអំពីមុខសញ្ញាគ្រោះមហន្តរាយធាតុអាកាសពីអាជ្ញាធរថ្នាក់ជាតិ។ ចំពោះក្រុមប្រឹក្សាឃុំ ប្រភពព័ត៌មានគឺដូចជាអ្នកភូមិផងដែរ។ ពួកគេគ្មានប្រព័ន្ធព័ត៌មានសម្របសម្រួលគ្នាមួយជាមួយអាជ្ញាធរជាតិ និងខេត្តឡើយ។ ទោះជាយ៉ាងណា ក្រុមប្រឹក្សាឃុំទឹកថ្លា និងទឹកល្អក់ធ្លាប់បានទទួលព័ត៌មានពីក្រសួងធនធានទឹក និងឧតុនិយម និងអាជ្ញាធរមូលដ្ឋានមុនមុខសញ្ញាមហន្តរាយអាកាសធាតុបានកើតឡើង។ លើសពីនេះ នៅទឹកថ្លា គណៈកម្មការសហគមន៍បានជូនដំណឹងដល់អាជ្ញាធរស្រុកអំពីផលប៉ះពាល់នៃព្យុះផងដែរ។ ប៉ុន្តែ គេមិនបានដឹងច្បាស់ទេថាតើអាជ្ញាធរប្រើប្រាស់ព័ត៌មាននេះបែបណា។

ជាផ្នែកមួយនៃការងារប្រចាំរបស់ខ្លួនលើការអភិវឌ្ឍទិន្នន័យព្យាករណ៍ និងការទស្សន៍ទាយអំពីមហន្តរាយធាតុអាកាសឲ្យកាន់តែប្រសើរថែមទៀត ប្រព័ន្ធព័ត៌មានចំនួនពីរ ពោលគឺ វិទ្យុ និងទូរទស្សន៍គួរតែមានតួនាទីក្នុងការជូនដំណឹងដល់សហគមន៍គោលដៅមុនមានមហន្តរាយធាតុអាកាស។ នៅក្នុងករណីមុខសញ្ញាមហន្តរាយធាតុអាកាស ព័ត៌មាននេះគួរតែបានបានមកដោយផ្ទាល់ពីអាជ្ញាធរពាក់ព័ន្ធ។ កិច្ចការនេះអាចធ្វើបានតាមវិធីមួយចំនួន។ វិធីមួយគួរតែអាជ្ញាធរមូលដ្ឋានមានបុគ្គលណាម្នាក់សម្រាប់ទាក់ទងនៅក្នុងក្រុមប្រឹក្សាឃុំដែលគេអាចទាក់ទងបានតាមទូរទស័ព្ទ និងជូនដំណឹងអំពីមុខសញ្ញាមហន្តរាយធាតុអាកាស។ ជនទំនាក់ទំនងនេះគួរតែមានភារៈទទួលខុសត្រូវក្នុងការចែករំលែកព័ត៌មាននេះជាមួយគណៈកម្មការសហគមន៍ ដែលបន្ទាប់មកអាចផ្តួចផ្តើមឲ្យមានចំណាត់ការពាក់ព័ន្ធ។

នៅក្រោយមុខសញ្ញាមហន្តរាយធាតុអាកាសបានកើតឡើងហើយ ប្រការសំខាន់គឺព័ត៌មានពាក់ព័ន្ធត្រូវតែបានបញ្ជូនពីអ្នកភូមិទៅអាជ្ញាធរ ដែលអាចប្រើប្រាស់សម្រាប់ធ្វើការប៉ាន់ប្រមាណអំពីទំហំនៃការខូចខាត និងការបាត់បង់ចំពោះសេដ្ឋកិច្ច។ ទិន្នន័យនេះអាចមាននាទីជាតួលេខគោលសម្រាប់សូចនាករមួយចំនួន ដែលទាក់ទងនឹងមុខសញ្ញាមហន្តរាយធាតុអាកាស ដូចជា កម្រិតញឹកញាប់ ផលប៉ះពាល់ និងកម្រិតជោគជ័យនៃសមត្ថភាពបន្សាំ និងយុទ្ធសាស្ត្រទប់ទល់ជាក់លាក់នានា និងផ្តល់ជាគំនិតយោបល់យ៉ាងសំខាន់សម្រាប់ការស្រាវជ្រាវទៅអនាគត។

## ការយល់ឃើញ

អ្នកភូមិយល់ឃើញថា ការប្រែប្រួលអាកាសធាតុនិងផលប៉ះពាល់របស់វាមានការទាក់ទងនឹងបរិស្ថាននៅមូលដ្ឋាន។ ពួកគេពុំមានការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុនៅក្នុងបរិបទពិភពលោកឡើយ។ ប្រការនេះបង្កជាហានិភ័យមួយសម្រាប់ការអនុវត្តមិនត្រឹមតែគម្រោងប្រែប្រួលអាកាសធាតុប៉ុណ្ណោះទេ ប៉ុន្តែគម្រោងអភិវឌ្ឍន៍ផ្សេងទៀតផងដែរ។ ប្រការនេះត្រូវតែអាចដោះស្រាយបានដោយធានាថា អ្នកទទួលផលមានការយល់ដឹងបានច្បាស់អំពីគោលបំណងនៃគម្រោងមុនមានការអនុវត្ត។ ឧទាហរណ៍មួយអំពីបញ្ហានេះគឺការបូមខ្សាច់ដែលអ្នកភូមិជាច្រើននៅកោះកុង បានកត់សំគាល់ថា ជាបញ្ហានៃផលប៉ះពាល់ពីប្រែប្រួលអាកាសធាតុ ដែលជាតុពិតគឺមិនមែនទេ។ ដូច្នេះគួររៀបចំជាសម្ភារៈបង្កើនការយល់ដឹងទៅតាមទម្រង់ពីរបែប៖ (១) ឯកសារអំពីយុទ្ធសាស្ត្រទប់ទល់ ដែលមានចែងអំពីគ្រប់យុទ្ធសាស្ត្រទប់ទល់ដែលមានស្រាប់នៅក្នុងសហគមន៍គោលដៅ (២) ផ្ទាំងអត្ថបទ និងរូបភាពដែលបង្ហាញពីយុទ្ធសាស្ត្រទប់ទល់ទាំងនេះ។ សម្ភារៈទាំងនេះគួរតែចែកចេញតាមជំពូកសម្រាប់មុន ក្នុងពេល និងក្រោយពេលមានគ្រោះមហន្តរាយ។

# ៣. ភាពងាយរងគ្រោះនៃទម្លាប់ដែលមានស្រាប់ក្នុងកសិកម្ម

ជំពូកនេះសង្ខេបអំពីការប៉ាន់ប្រមាណភាពងាយរងគ្រោះនៃទម្លាប់ដែលមានស្រាប់នៅក្នុងកសិកម្មក្នុងសហគមន៍គោលដៅ CARP ដែលបានធ្វើឡើងនៅក្នុងខែឧសភា និងមិថុនា ឆ្នាំ២០១២។

ការវាយតម្លៃនេះទាក់ទងនឹងលទ្ធផល២ នៃCARP: "ភាពរបស់សហគមន៍តំបន់ឆ្នេរ និងតំបន់ទ្រនាប់នៃប្រព័ន្ធអេកូឡូស៊ីតំបន់ឆ្នេរទល់នឹងការប្រែប្រួលអាកាសធាតុបានកើនឡើងហើយរបរចិញ្ចឹមជីវិតបានកែលម្អ"។ ចំណុចនេះមានការទាក់ទងជាក់លាក់នឹងធាតុចេញ២.៤៖ "ការវិភាគលើភាពងាយរងគ្រោះនៃទម្លាប់ដែលមានស្រាប់ក្នុងកសិកម្មទល់នឹងផលប៉ះពាល់នៃអថេរធាតុអាកាស និងការប្រែប្រួលអាកាសធាតុ"។

ការងារនេះបានរួមបញ្ចូលការពិគ្រោះយោបល់ជាមួយស្ថាប័នរដ្ឋាភិបាល កសិករ អ្នកនេសាទ និងអ្នកដទៃទៀតនៅក្នុងខេត្តកោះកុង និងព្រះសីហនុ។

ការវាយតម្លៃពេញលេញ–"ភាពងាយរងគ្រោះនៃទម្លាប់ដែលមានស្រាប់ក្នុងកសិកម្ម", ខែកក្កដា ឆ្នាំ ២០១២– អាចចម្លងចេញពីវេបសាយ CARP (www.czmcam.org)។

## ៣.១ របរចិញ្ចឹមជីវិតដែលផ្អែកលើធនធាន

### *សហគមន៍គោលដៅនៅកោះកុង*

ការដាំដំណាំ៖ នៅពាមក្រសោប កសិករភាគច្រើនដាំដំណាំដែលទទួលផលក្នុងរយៈពេលមធ្យម ប៉ុន្តែមាននិន្នាការទៅរកការដាំដំណាំដែលឆាប់ទទួលផល។ ទិន្នផលមាន ២តោន/ហ.ត (មួយដងក្នុងមួយឆ្នាំ) ដែលសម្រេចបានដោយពុំចាំបាច់ប្រើប្រាស់ជីគីមី។ ពូជត្រូវបានរក្សាទុកបន្តពីមួយឆ្នាំទៅមួយឆ្នាំ។ នៅទួលគគីរ ផ្ទៃដីកសិកម្មត្រូវបានបែងចែកដាច់គ្នាសម្រាប់ពូជស្រូវធ្ងន់ និងស្រូវកណ្តាល។ ពូជស្រូវស្រាលត្រូវបានសាកល្បង (លើផ្ទៃដី ០,២ហ.ត នៅឆ្នាំ២០១២ ដែលធ្វើជាស្រូវពង្រោះ នៅពាក់កណ្តាលខែមេសា/ចុងខែឧសភា)។ មានពូជស្រូវច្រើនជាង ១០មុខ ដែលប្រើប្រាស់នៅក្នុងឃុំនេះ ប៉ុន្តែចំណេះដឹងអំពីគុណភាពដីពុំមានគ្រប់គ្រាន់សម្រាប់ការជ្រើសរើសឲ្យបានសមស្របសម្រាប់ករណីនីមួយៗដាច់ដោយឡែកពីគ្នាបាននៅឡើយ។ ការដាំដំណាំបានចាប់ផ្តើមពីដើមរដូវនៅឆ្នាំ ២០១២ ដោយសារមានធ្លាក់ភ្លៀងពីដើមរដូវ។ ទិន្នផលគឺ ១,៥ត/ហ.ត ជាមធ្យម ដោយអនុវត្តម្តងក្នុងមួយឆ្នាំ។ ពូជស្រូវត្រូវបានរក្សាទុកបន្តពីមួយឆ្នាំទៅមួយឆ្នាំ លើកលែងតែពូជស្រូវស្រាលដែលបានទិញពីសាច់ញាតិ នៅក្នុងស្រុក ឬខេត្តផ្សេង។

ការនេសាទ៖ អ្នកភូមិភាគច្រើននៅពាមក្រសោប ធ្វើនេសាទ និងពុំសូវមានអ្នកធ្វើស្រែឡើយ។ នៅទួលគគីរ អ្នកភូមិធ្វើនេសាទ និងដាំដំណាំ។ ភាគច្រើននៃការនេសាទប្រើប្រាស់ទូកតូចៗ (ដែលអាចប្រើការបានតែក្នុងករណីធាតុអាកាសល្អតែប៉ុណ្ណោះ) ដោយប្រើប្រាស់បច្ចេកទេសប្រពៃណី (និងមាននិរន្តរភាព)។ ទូកធំៗដែលប្រតិបត្តិការនៅក្នុងតំបន់នោះ គឺទូកមកពីប្រទេសថៃ។ ពួកគេប្រើប្រាស់បច្ចេកវិទ្យាទំនើប។ ទិន្នន័យមានស្ថិរភាព ទោះបីចំនួនថ្ងៃចេញនេសាទបានរងឥទ្ធិពលពីខ្យល់ព្យុះកាន់តែញឹកញាប់ក៏ដោយ។ នៅក្នុងភូមិបណ្តែតទឹក ការនេសាទគឺជាមុខរបរដែលមានច្រើនជាងគេ។ ចំណុចខ្លាំងនៃការរស់នៅក្នុងភូមិបណ្តែតទឹកគឺត្រូវការដេន្ទនៈតិច។ គ្រួសារខ្លះមានផ្ទះពីរកន្លែង មួយនៅក្នុងភូមិបណ្តែតទឹក និងមួយទៀតលើដីគោក។

<u>បញ្ហា</u>

- *ការជ្រាបចូលនៃទឹកប្រៃ* គឺជាកង្វល់ចំបងមួយ ដែលមានឥទ្ធិពលធ្ងន់ធ្ងរមកលើការដាំដំណាំ ការចិញ្ចឹមសត្វ និង ការផ្គត់ផ្គង់នៅក្នុងគ្រួសារ។
- *សំណល់បញ្ចេញពីដីកសិកម្ម* (ទឹកបំពុលដោយសារជីគីមី និងថ្នាំគីមីកសិកម្ម) អាចធ្វើឲ្យខូចទីជម្រកនិងប្រព័ន្ធអេកូឡូស៊ីកោងកាង។ នេះជាហានិភ័យដែលអាចកើតឡើង ទាក់ទងនឹងការអភិវឌ្ឍដែលចង់ឲ្យមានដូចជា ការប្រើប្រាស់ពូជស្រូវដែលផ្តល់ទិន្នផលខ្ពស់ និងពិពិធកម្មពូជស្រូវ។
- *ឱនភាពដីធ្លី* នៅតាមកន្លែងនានាពីខាងក្រោយព្រៃកោងកាង ដែលទំនងជាកាន់តែរីកដាលធំឡើងៗ។ ការរេចរឹលនេះបង្កដោយការជ្រាបចូលនៃទឹកប្រៃ ដែលប្រហែលជារួមបញ្ចូលផងដែរ ជាមួយការដក់ទឹក ដោយសារតែគ្មានប្រកហូរទឹកចេញ។ ប្រតិបត្តិការមិនបានពេញលេញ និងគ្មានការថែទាំគ្រប់គ្រាន់ ទំនប់ និងទ្វារទឹកអាចជាផ្នែកមួយនៃទំនាក់ទំនងនៃមូលហេតុ និងផលដែលកើតឡើងផងដែរ។

### *សហគមន៍គោលដៅក្នុងខេត្តព្រះសីហនុ*

ការដាំដំណាំ៖ មានការធ្វើស្រែវស្សាម្តងក្នុងមួយឆ្នាំ។ ទិន្នផលមានទាបជាងតួលេខមធ្យមនៅក្នុងស្រុក ពោលគឺ ១,៨ត/ហ.ត និងទាបជាខ្លាំងធៀបនឹងទិន្នផលមធ្យមនៅក្នុងខេត្ត ២,២ត/ហ.ត (ដែលនៅតែទាបជាងទិន្នផលមធ្យមនៃស្រូវវស្សានៅកម្រិតជាតិ ២,៣ត/ហ.ត)។ ទិន្នផលនេះបានប្រសើរឡើងបន្តិចនៅតាមកន្លែងខ្លះនៃប៉ូលខៃរ និងនៅឃុំសាមគ្គី ដែលមិនសូវរងឥទ្ធិពលពីទឹកប្រៃ។ ពូជត្រូវបានរក្សាទុកជាបន្តពីមួយឆ្នាំទៅមួយឆ្នាំ។ មានការញែកភាពខុសគ្នាជាបីបែប ពោលគឺ ទៅតាមពណ៌នៃគ្រាប់អង្ករ៖ ក្រហម និងស (សម្រាប់បរិភោគ) និងពណ៌ត្នោត(សម្រាប់ធ្វើបង្អែម)។ មានការប្តូរពូជនៅតាមកន្លែងទាំងនោះរវាងឆ្នាំនានា។ កសិករជាច្រើនធ្វើស្រូវពង្រោះ។ ធៀបនឹងការស្ទូង ការធ្វើស្រូវពង្រោះអាចកាត់បន្ថយរយៈពេលលូតលាស់ ប្រមាណ ១សប្តាហ៍ (ដែលជាអាទិភាពនៅក្នុងតំបន់នេះ) ប៉ុន្តែភាពផុយស្រួយដោយសារតែគ្រោះរាំងស្ងួត (ប្រសិនបើមាន) នៅដើមរដូវបង្កបង្កើនផល មានកម្រិតខ្ពស់ជាងមុន(មិនសូវជាកង្វល់ឡើយនៅក្នុងតំបន់នេះ)។ ទិន្នផលក៏បានទាបជាងបន្តិចផងដែរ។ ដំណាំបន្លែមខ្លះត្រូវបានដាំសម្រាប់បរិភោគក្នុងគ្រួសារ និង (ជួនកាល) សម្រាប់លក់ ដូចជាឪឡឹក និងត្រសក់។ ពោត និងសណ្តែកក្បូរ អាចដាំបាន ប្រសិនបើមានទឹកច្រើន។ ការចិញ្ចឹមសត្វរួមមាន ក្របី គោ ជ្រូក មាន់ និងទា។

វារីវប្បកម្ម៖ វារីវប្បកម្មត្រូវបានអនុវត្តតិចតួចជាង (ត្រឹមតែ២០២គ្រួសារ ប៉ុណ្ណោះនៅក្នុងស្រុកទាំងមូល)។ មូលហេតុគឺជាទូទៅគឺ ដើមទុន និងថ្លៃចំណាយចរន្ត មានដែលកម្រិតខ្ពស់ ធៀបនឹងប្រាក់ចំណូល។ ជំនាញបច្ចេកទេសក៏មានកម្រិតកំណត់ផងដែរ។

<u>បញ្ហា៖</u>

- *ទិន្នផលទាប* និងកសិករមានដីតិចតួច
- *ការជ្រាបចូលនៃទឹកប្រៃ* មានការថយចុះជាបណ្តើរៗពីខាងត្បូង មកខាងជើង
- *ដំណាំខូចខាតដោយសារព្យុះ* (ជាពិសេស ស្រូវកណ្តាល ចំណែកស្រូវស្រាលបានប្រមូលផលផុតទៅហើយ ពេលព្យុះមកដល់ ហើយស្រូវធ្ងន់មានលក្ខណៈល្អជាង)។ ព្យុះបែបនេះកើតឡើងស្ទើរតែរាល់ឆ្នាំពីពាក់កណ្តាលខែតុលា រហូតដល់ខែធ្នូ។

- *ឱនភាពដីធ្លី* ដោយសារការប្រើជីគីមី។
- *ការប្រើប្រាស់ថ្នាំគីមីកសិកម្មមិនសមស្រប* (មួយផ្នែកដោយសារគ្មានការណែនាំពីអ្នកផលិត) ដែលបង្កឲ្យត្រីងាប់ និង(ជួនកាល) មនុស្សឈឺ ផងដែរ និងប្រហែលបង្កជាការបំពុលបរិស្ថានផងដែរ។

*ប៉ូលឌែរនៅព្រៃនប់*

លក្ខណៈទូទៅ៖ ប៉ូលឌែរលាតសន្ធឹងនៅក្នុងឃុំអូរឧកញ៉ាហេង ព្រៃនប់ និងទួលទទឹង ក៏ដូចជា ផ្នែកនានានៃឃុំដទៃទៀតមួយចំនួនក្នុងស្រុកព្រៃនប់ផងដែរ។ នេះជាកន្លែងតែមួយដែលមានប្រព័ន្ធស្រោចស្រពនៅក្នុងខេត្តព្រះសីហនុ(និងនៅតែពឹងលើការស្រោចស្រពភាគច្រើនពីទឹកភ្លៀង)។ បរិមាណទឹកក្នុងកម្រិតកំណត់ អាចរក្សាទុកនៅក្នុងស្រះតូចៗមួយចំនួន និងនៅក្នុងប្រឡាយក្នុងតំបន់នេះ។ ប្រព័ន្ធនេះផ្សំដោយ ប៉ូលឌែរចំនួន៦ និងមានទំនប់មួយខ្សែប្រវែង ៩០គ.ម ប្រឡាយប្រវែង ១២៥គ.ម និងទ្វារទឹកស្វ័យប្រវត្តិចំនួន ៣៦។ ប៉ូលឌែរគ្របដណ្តប់ផ្ទៃដីទំហំ ១០.៥០០ហ.ត។ ប្រព័ន្ធនេះរងការគំរាមកំហែងពីការជ្រាបចូលនៃទឹកសមុទ្រ ដោយសារស្ថិតក្នុងកន្លែងដែលមានរយៈកំពស់ទាប។ ប៉ូលឌែរនៅចុងខាងជើង (លេខ ៥ និង៦) រងការខូចខាតធ្ងន់ធ្ងរដោយសារជំនន់ទឹកភ្លៀង ដោយសារតែសមត្ថភាពទាបក្នុងការដោះទឹកចេញ។ រយៈកំពស់នៃតំបន់នេះមានត្រឹមប្រហាក់ប្រហែលកំពស់ទឹកសមុទ្រមធ្យមប្រចាំឆ្នាំ។ ការគ្រប់គ្រងទឹកផ្តោតលើការធ្វើឲ្យមានតុល្យភាពរវាងការរក្សាកំពស់ទឹកសមុទ្រមិនឲ្យជ្រាបចូល (នៅពេលទឹកជោរ) និងការដោះទឹកសាបដែលហូរពីភាគខាងលើ (នៅពេលទឹកនាច)។

ទេសចរណ៍៖ ប៉ូលឌែរ ត្រូវបានចុះនៅក្នុងអាត្លាស់ផ្លូវថ្នល់ និងទេសចរ (Gascuel, September 2009)។ ទីនេះស្ថិតនៅចំទីតាំងល្អ ជាប់នឹងផ្លូវជាតិលេខ ៤ និងមិនឆ្ងាយពីក្រុងព្រះសីហនុ។

ការដាំដំណាំ៖ ប៉ូលឌែរ ផ្តល់ដីស្រែទំហំ ១០.៥០០ហ.ត។ មានការធ្វើស្រែវស្សាម្តងក្នុងមួយឆ្នាំ ភាគច្រើនជាស្រូវកណ្តាល ប៉ុន្តែក៏មានស្រូវស្រាលខ្លះផងដែរ។ ទិន្នផលអាចមានដល់ ៣ត/ហ.ត សម្រាប់កន្លែងនៅឆ្ងាយពីសមុទ្រ។ ពូជស្រូវត្រូវបានរក្សាទុកជាបន្តពីមួយឆ្នាំទៅមួយឆ្នាំ។ កម្មសិទ្ធិដីមានតូច ពោលគឺ តិចជាង ១ហ.ត ក្នុងមួយគ្រួសារ។ កសិករភាគច្រើនមានដីផ្ទាល់ខ្លួន។

ការគ្រប់គ្រង៖ ទំនប់ខាងក្រៅ (និងប្រព័ន្ធការពារទល់នឹងការជ្រាបចូលនៃទឹកសមុទ្រ) ស្ថិតក្រោមការគ្រប់គ្រងដោយក្រសួងធនធានទឹក និងឧតុនិយម (MOWRAM)។ រចនាសម្ព័ន្ធផ្សេងទៀត (ប្រឡាយ និងទ្វារទឹក) គ្រប់គ្រងដោយសហគមន៍កសិករប្រើប្រាស់ទឹកនៅក្នុងប៉ូលឌែរនេះ (FWUC)។ FWUC នេះ ផ្តល់សេវាដល់ច្រើនជាង ៦.០០០គ្រួសារ (ប្រមាណ ១៥.៦០០នាក់) នៅក្នុង ៤៣ភូមិ ក្នុង ១១ឃុំ។ គណៈកម្មការនេះប្រើប្រាស់កម្លាំង ៦នាក់នៅថ្នាក់កណ្តាល និង ៤៣នាក់នៅតាមភូមិ។ កសិករបង់ប្រាក់ ១២,៥០ដុល្លាអាមេរិក ក្នុងមួយហិកតា ទៅសហគមន៍កសិករប្រើប្រាស់ទឹក (FWUC) សម្រាប់ប្រតិបត្តិការ និងការថែទាំ។

<u>បញ្ហា</u>

- *ការស្រុតដី* គឺជាកង្វល់ចំបងមួយ ដោយសារតែរយៈកំពស់ទាប ធៀបនឹងសមុទ្រ។ ផ្នែកខ្លះៗនៅក្នុងតំបន់នេះបានស្រុតចុះ ៥-៧ ស.ម/ឆ្នាំ នៅរវាងឆ្នាំ ២០០១ និង ២០០៧។ ទំនប់មេបានស្រុតចុះ០,៨ម ដោយកន្លែង ហើយខ្នងទំនប់ឥឡូវនេះស្ថិតនៅត្រឹមកំពស់ទឹកជោរប្រចាំឆ្នាំ។

- *ប្រព័ន្ធដោះទឹកជំនន់* គឺជាតម្រូវការចាំបាច់សម្រាប់ការដាំដំណាំ ឧទាហរណ៍ នៅពេលប្រមូលផលស្រូវ។ នៅពេលដែលកន្លែងនេះស្រុតចុះបន្តិចទៀតធៀបនឹងបច្ចុប្បន្ន ប្រព័ន្ធដោះទឹកនឹងទាមទារឲ្យមានការបូមទឹកយ៉ាងច្រើន (ទោះបីក្នុងកំពស់មិនខុសគ្នាច្រើនក៏ដោយ)។ នេះជារឿងធម្មតា ប៉ុន្តែថ្លៃសាងសង់ និងប្រតិបត្តិការគឺជាកង្វល់មួយធៀបនឹងអត្ថប្រយោជន៍សេដ្ឋកិច្ចដែលទទួលបាន។
- *ការបញ្ចេញទឹកជំនន់ពីទឹកភ្លៀង* កំពុងមានឥទ្ធិពលមកលើដីនៅជិតខាង (ភាគខាងជើង និងខាងកើតប៉ូលឌែរ) នៅក្នុងអំឡុងពេលមានភ្លៀងធ្លាក់ខ្លាំង នៅពេលដែលទ្វារទឹកជំនន់បើកចំហ។ ឥទ្ធិពលនេះនឹងអាចកាន់តែធ្ងន់ធ្ងរដោយសារតែប៉ូលឌែរឯកជនតូចៗនៅក្រៅតំបន់នេះ ប៉ុន្តែពុំមានព័ត៌មានច្បាស់នៅឡើយទេ។
- *ធាតុអាកាសមិនប្រក្រតី* បង្កជាជំនន់ ឬ ការជ្រាបចូលនៃទឹកប្រៃ។ នៅចុងខែកញ្ញា ២០១១ មានភ្លៀងធ្លាក់ច្រើនដល់ ១៤០ម.ម ក្នុងរយៈពេល ១២ម៉។ ព្យុះសមុទ្រកើតមានម្តងម្កាល ជាពិសេស នៅខែ កញ្ញា/ដើមខែតុលា។
- *កម្មសិទ្ធិដីតូចៗ និងទិន្នផលទាប* ធ្វើឲ្យគ្រួសារនានាលំបាកបំពេញតាមតម្រូវការបរិភោគក្នុងគ្រួសារ។
- *ខ្វះទិន្នន័យ និងព័ត៌មាន និងការទទួលបានព័ត៌មាននិងទិន្នន័យ* គឺជាឧបសគ្គធ្ងន់ធ្ងរ។ គេត្រូវការចំណេះដឹង (អំពី ដូចជា កំពស់ទឹកភ្លៀងធម្មតា និងក្នុងករណីមិនប្រក្រតី កំពស់ទឹកសមុទ្រធម្មតា និងក្នុងករណីមិនប្រក្រតី ចំណាំងកាំពន្លឺព្រះអាទិត្យ និងរបាយតាមពេលវេលា និងទីកន្លែងនៃការជ្រាបចូលនៃទឹកប្រៃ) ដើម្បីធ្វើការជ្រើសរើសបានសមស្របទាក់ទងនឹងពូជស្រូវ និងរបៀបធ្វើស្រែ។ បើគ្មានចំណេះដឹងបែបនេះទេ ការផ្តួចផ្តើមថ្មីនឹងក្លាយជាការស្វែងរកក្នុងទីងងឹតសម្រាប់កសិករខ្នាតតូច ដែលគ្មានសមត្ថភាពសម្រាប់ភាពមិនប្រាកដប្រជា និងហានិភ័យ។ កសិករខ្លះព្យាយាមរៀនសូត្រ (និងនាំចូលពូជស្រូវ) ពីគ្រួសារដទៃ និងមិត្តភក្តិនៅក្នុងខេត្តដទៃនៃផ្ទៃប្រទេស ដែលលក្ខខណ្ឌមានភាពខុសគ្នាជាច្រើន។

## ៣.២ ការវាយតម្លៃភាពងាយរងគ្រោះ

គ្រួសារភាគច្រើននៅក្នុងតំបន់គោលដៅបានដាំដំណាំ និង/ធ្វើនេសាទ ដែលជាអាជីពភាគច្រើន។ ដូចដែលមានបង្ហាញខាងក្រោម គ្រួសារទាំងឡាយស្ថិតក្នុងស្ថានភាពងាយរងគ្រោះសព្វថ្ងៃនេះ និងកាន់តែងាយរងគ្រោះនៅក្រោមការប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។

### ភាពងាយរងគ្រោះបច្ចុប្បន្ន និងនៅពេលខាងមុខ

ការធ្វើស្រែ៖ នៅទូទាំងទីតាំងសិក្សា ទាំងក្នុងខេត្តព្រះសីហនុ និងខេត្តកោះកុង ទិន្នផលស្រូវមានកម្រិតទាប (២តោន/ហ.ត ឬតិចជាងនេះ) ហើយគ្រួសារនីមួយៗមានដីទំហំតូច (ភាគច្រើន១ ហ.ត ឬតិចជាងនេះ ក្នុងគ្រួសារនីមួយៗ)។

ក្រៅពីការគំរាមកំហែងជាក់លាក់នានា ការធ្វើស្រែបានរងឥទ្ធិពលពីគ្រាប់ពូជស្រូវស្រាល និងស្រូវកណ្តាលដែលមានគុណភាពទាប និងកង្វះដី ឬការប្រើប្រាស់ដីមិនសមស្រប។

ប៉ូលឌែរនៅព្រៃនប់៖ កង្វល់ចំបងមួយគឺការថយចុះនៃកំពស់ដី (នៅក្នុងប៉ូលឌែរ ដោយសារតែការស្រុតចុះ) ធៀបនឹងកំពស់ទឹកសមុទ្រ (នៅក្រៅប៉ូលឌែរ ដោយសារតែកំពស់ទឹកសមុទ្រ)។ ភាពខុសគ្នានេះនៃកំពស់

ដី ធៀបនឹងទឹកសមុទ្រ មានឥទ្ធិពលមកលើលទ្ធភាពដែលអាចឲ្យទឹកហូរចេញពីប៉ូលឌែរដោយពុំចាំបាច់បូម ដូចក្នុងករណីបច្ចុប្បន្ននេះ។ កំពស់ទឹកសមុទ្រជាមធ្យមប្រចាំខែមានភាពខុសគ្នាមួយចំនួន ដោយមានអំព្លីទុត ប្រមាណ ៣០ស.ម ដោយមានកំពស់ទាបបំផុតនៅខែមិថុនា-សីហា និងខ្ពស់បំផុតនៅខែ វិច្ឆិកា-កុម្ភៈ។ សព្វថ្ងៃ ការបង្ហូរទឹកចេញធ្វើឡើងដោយកម្លាំងទន្លាក់សេរី នៅក្នុងពេលខ្លះ ប៉ុន្តែមិនមែនគ្រប់ពេលនោះឡើយ ដែល បង្ហាញអំពីកម្រិតកំពស់ដីធៀបនឹងកំពស់ទឹកសមុទ្រ។ នៅពេលដែលកំពស់ទឹកសមុទ្រកើនឡើង និងកំពស់ដី ថ្លាក់ចុះ ភាពខុសគ្នានៃកំពស់នេះនឹងថយចុះ និងនៅទីបំផុតវានឹងមានកំពស់ស្មើគ្នា។ ភស្តុតាងទាំងអស់បង្ហាញ ថា ស្ថានភាពនេះនឹងកើតឡើង ប៉ុន្តែនៅពុំច្បាស់ថាវានឹងកើតឡើងឆាប់រហ័សប៉ុណ្ណា។ នៅក្នុងដំណាក់កាល ដែលគេលែងអាចបង្ហូរទឹកចេញពីប៉ូលឌែរបានដូចមុន គេអាចមានជម្រើសមួយចំនួន៖

- ការប្តូរទៅប្រព័ន្ធផលិតកម្មដែលធន់នឹងទឹកប្រៃ៖ ការចិញ្ចឹមបង្គារ និង/ឬ ការបង្កើតជាវាលស្មៅនៅលើវាល ភក់ដីប្រៃ។
- ការស្តារ/បង្កើនកំពស់ទំនប់ និងបូមទឹកចេញពីប៉ូលឌែរ។
- បង្កើនកំពស់ដីដោយចាក់ដីបន្ថែម។

ជម្រើសទាំងអស់នេះអាចធ្វើបាន បើផ្អែកលើលក្ខណៈបច្ចេកទេស។ ឧទាហរណ៍ ការចាក់បំពេញដី សម្រាប់អភិវឌ្ឍន៍ឧស្សាហកម្មបានធ្វើរួចមកហើយ និងកំពុងស្ថិតក្នុងការគ្រោងនៅតាមកន្លែងជាច្រើនតាម បណ្តោយឆ្នេរសមុទ្រ។ ទោះបីយ៉ាងណាក៏ដោយ តាមគោលការណ៍សេដ្ឋកិច្ច ការប្រើប្រាស់ទីនេះសម្រាប់ផលិត កម្មកសិកម្មពុំអាចធ្វើបានទេ ដោយសារផលចំណេញខាងសេដ្ឋកិច្ច និងមានទំហំតូចជាងការចំណាយ។

## ៣.៣ ការសម្លឹងទៅអនាគត

### ការធ្វើស្រែ

នៅក្នុងអត្ថបទស្តីពី "ការធ្វើស្រែ - ២០ឆ្នាំទៅមុខ" លោកស្រី Van Ngo (April 2010) បានគិតគូរអំពី អនាគតនៃរបរចិញ្ចឹមជីវិតចំបងៗតាមប្រពៃណី។ លោកស្រីសង្កេតឃើញថា ប្រទេសជាច្រើនបានឃើញវិស័យ កសិកម្មរបស់ខ្លួនមិនរីកចម្រើនឡើយ ធៀបនឹងឧស្សាហកម្ម និងសេវាកម្ម បើគិតអំពីបច្ចេកវិទ្យា និងផល ចំណូល។ នេះមានន័យថា ភាគរយនៃផលចំណូលកាន់តែតិចជាងមុន ធៀបនឹងផលចំណូលពីវិស័យឧស្សា- ហកម្ម និងសេវាកម្ម។ ជាក់ស្តែង គេមិនអាចនិយាយថា វិស័យនីមួយៗគួរតែបង្កើតផលចំណូលឲ្យស្មើគ្នានោះ ឡើយ បើគិតជាសាច់ប្រាក់ ក្នុងនិយោជិតម្នាក់ៗ។ (ប៉ុន្តែ ក្នុងន័យសេដ្ឋកិច្ច វិស័យនានាគួរតែរួមចំណែកក្នុង កម្រិតខ្ពស់បំផុតតាមសក្តានុពលដែលមាន ហើយនៅក្នុងទស្សនទានសង្គម ស្បៀងអាហារ មានសារៈសំខាន់ ណាស់)។ ម៉្យាងវិញទៀត អតុល្យភាពទំនងជាមានសង្គតិភាពជាមួយប្រការដែលថា ការដាំដំណាំអាចជាវិធី លំបាកដើម្បីអាចរកប្រាក់ចំណូលសម្រាប់ការចិញ្ចឹមជីវិត។ ក្នុងន័យទូទៅបំផុត គេអាចបង្ហាញភាពខុសគ្នារវាង បីដំណាក់កាល នៃវិស័យធ្វើស្រែ ដូចមានអធិប្បាយខាងក្រោម៖

*បច្ចុប្បន្ន*

ឯកត្តាផលិតកម្មបច្ចុប្បន្នផ្អែកលើគ្រួសារ និងមានទ្រង់ទ្រាយតូច។ សមាជិកគ្រួសារខ្លះអាចស្វែងរករបរ ចិញ្ចឹមជីវិតនៅក្រៅកសិដ្ឋាន និងនាំមកវិញនូវប្រាក់ចំណូល។ គោ និងក្របីមួយចំនួនតូចអាចធ្វើឲ្យមានភាព ខុសគ្នាគួរឲ្យកត់សំគាល់នៅក្នុងសេដ្ឋកិច្ចគ្រួសារ ហើយដូចគ្នានេះដែរសម្រាប់ការនេសាទតាមវដ្ត។ ការធ្វើស្រែ

ទាមទារកម្លាំងកាយច្រើន ប៉ុន្តែតាមធម្មតា តម្រូវការពលកម្មខ្ពស់បំផុត សម្រាប់ស្ទូង និងការប្រមូលផល មានកម្រិតខ្ពស់ និងក្នុងរយៈពេលខ្លី និងកើតឡើងព្រមៗគ្នា។ ប្រសិនបើគេធ្វើស្រែពឹងលើទឹកភ្លៀង ដោយគ្មានលទ្ធភាពក្នុងការពឹងផ្អែកលើប្រព័ន្ធស្រោចស្រព ក្នុងករណីនោះ ពួកគេងាយរងគ្រោះដោយសារតែធាតុអាកាសមិនប្រក្រតី។ នៅកន្លែងខ្លះ ទិន្នផលមានកម្រិតទាប (ប៉ុន្តែអាចមានគុណភាពខ្ពស់)។ ការប្រើប្រាស់ទីផ្សារអាចជួបឧបសគ្គដោយសារកត្តារូបវន្ត និងរចនាសម្ព័ន្ធ(ដែលទាក់ទងនឹងទីផ្សារ)ខុសៗគ្នាជាច្រើន។ ការធ្វើស្រែដែលពឹងផ្អែកលើប្រព័ន្ធស្រោចស្រព(បច្ចុប្បន្ន និងទៅអនាគត) នៅតែជាវិស័យដែលត្រូវបូមទឹកចេញពីប្រភពដើមសម្រាប់ប្រើប្រាស់។

**<u>ដំណើរការអន្តរកាល</u>**

ដំណើរការប្រែប្រួលរចនាសម្ព័ន្ធមានសារៈសំខាន់ណាស់ ដោយសារវាមានឥទ្ធិពលមកលើគ្រួសារជាច្រើននៅក្នុងរយៈពេលជាច្រើនទសវត្សរ៍។ វិស័យកសិកម្មនឹងបង្កើនពិពិធកម្ម ហើយកម្លាំងជម្រុញក្នុងការអភិវឌ្ឍវិស័យនេះអាចកើតឡើងសម្រាប់ប្រព័ន្ធផលិតកម្ម ក្រៅពីស្រូវ។ ផលិតកម្មស្បៀងនឹងកើនឡើង ប៉ុន្តែដំណើរការនេះនឹងជួបប្រទះការបាត់បង់ការងារនៅក្នុងការដាំដំណាំតាមប្រពៃណី។ ឯកត្តាផលិត ពោលគឺទំហំកសិដ្ឋាន នឹងកើនឡើង ដោយសារតែបច្ចេកវិទ្យាថ្មីៗ ដែលត្រូវការកម្លាំងពលកម្មតិចជាងមុន ប៉ុន្តែដើមទុនច្រើន រួមផ្សំជាមួយតម្រូវការឲ្យមានប្រសិទ្ធភាពខ្ពស់ក្នុងផលិតកម្ម ពោលគឺ ទទួលផលច្រើន និងផ្តល់តម្លៃខ្ពស់ក្នុងមួយឯកត្តាធាតុចូល។ ប្រព័ន្ធផលិតកម្មដែលត្រូវការកម្លាំងពលកម្មច្រើន ដូចជា ប្រព័ន្ធប្រពលវប្បកម្មស្រូវ (SRI) - នឹងមានត្រឹមតិចតួច ។

ការប្រែប្រួលកើតឡើងនៅក្រោមឥទ្ធិពលនៃកាលៈទេសជាច្រើនរួមគ្នា។ ឧបសគ្គតិចជាងមុនក្នុងពាណិជ្ជកម្មនឹងបង្កើនការរងឥទ្ធិពលពីសម្ពាធនៃការប្រកួតប្រជែង ដែលឆ្លុះបញ្ចាំងពីភាពខ្លាំង និងភាពទន់ខ្សោយ ក៏ដូចជា ការរងឥទ្ធិពលនៃការប្រែប្រួលថ្លៃលើពិភពលោកផងដែរ ពោលគឺនិន្នាការមួយដែលនឹងមានទំនាក់ទំនងជាមួយគ្នាតាមទម្រង់ដែលមិនអាចព្យាករណ៍បាន ដែលនាំមកនូវកំណើនភាពមិនប្រក្រតីនៃធាតុអាកាស ដែលបង្កដោយការប្រែប្រួលអាកាសធាតុពិភពលោក។ របៀបរស់នៅតាមបែបថ្មីនឹងមានឥទ្ធិពលមកលើតម្រូវការផលិតផលជាច្រើន ដែលរួមទាំង ស្បៀងអាហារ(និងថាមពលផងដែរ) ដូចជាពលរដ្ឋអាចបរិភោគសាច់កាន់តែច្រើន។តម្រូវការថ្មីមួយខាងជីវៈឥន្ធនៈគឺជាលទ្ធភាពដោយឡែកមួយផងដែរ។

និន្នាការថ្មីៗនេះនៃការស្វែងរកដីកសិកម្ម(និងទឹក)លើទីផ្សារអន្តរជាតិ នឹងមានឥទ្ធិពលមកលើវត្តមាននៃកត្តាផលិតកម្ម និងមានគោលបំណងច្បាស់លាស់ក្នុងការបង្កើនការផ្គត់ផ្គង់ស្បៀង និងកសិផលផងដែរ ទោះបីថាអាចកើតមាននៅក្នុងប្រទេសដែលស្ថិតនៅឆ្ងាយក៏ដោយ។ ការប្រើប្រាស់ថ្នាំគីមីកសិកម្ម (និងជីគីមី) នឹងកើនឡើង មួយផ្នែកគឺជាតម្រូវការដោយសារតែពិពិធកម្ម។ ថ្នាំគីមីកសិកម្មអាចហូរចូលទៅក្នុងបរិស្ថាន និងអាចធ្វើឲ្យសាច់ត្រី និងទឹកដែលប្រើប្រាស់សម្រាប់ផឹក លែងសមស្របសម្រាប់ការបរិភោគបាន។

ផលចំណូលខ្ពស់ជាងមុនក្នុងមួយឯកត្តាហិកតា នឹងធ្វើឲ្យដីកសិកម្មក្លាយជាកម្មវត្ថុនៃការវិនិយោគ ដូចដែលកើតមាននៅក្នុងអំឡុងពេលបដិវត្តបៃតង ហើយប្រការនេះនឹងបង្ហាញច្បាស់នៅពេលដែលតំបន់ណាមួយបានពឹងផ្អែកលើហេដ្ឋារចនាសម្ព័ន្ធស្រោចស្រព។ លើសពីនេះ ម្ចាស់ដីតូចតាចអាចប្រថុយនឹងការបាត់បង់ដីរបស់ខ្លួន ទាក់ទងនឹងភាពមិនប្រក្រតីនៃធាតុអាកាស ឬក្នុងករណីការប៉ះទង្គិចខាងសង្គម ដូចជា ជម្ងឺនៅក្នុងគ្រួសារ។

**<u>អនាគត</u>**

ស្រូវនឹងនៅតែជាអាហារមិនអាចខ្វះបាន។ ផលចំណូលនៃវិស័យកសិកម្មនឹងកើនឡើង ប៉ុន្តែមួយផ្នែកធំនៃតម្លៃនេះនឹងបានមកពីដំណាំក្រៅពីស្រូវ ក៏ដូចជា ពីសាច់ និងទំនងជាជីវៈឥន្ធនៈផងដែរ។ ប្រព័ន្ធផលិតកម្មដែលត្រូវការកម្លាំងពលកម្មតិចក្លាយជាករណីទូទៅ។ ការអភិវឌ្ឍបច្ចេកវិទ្យានឹងបន្តតាមទិសដៅនៃការធ្វើពិពិធកម្មបន្ថែមទៀត និងបន្តជាមួយការបង្កើនប្រសិទ្ធភាព ដែលរួមទាំងអំពីផលិតកម្មបឋម ការចិញ្ចឹមសត្វ និងការកែច្នៃផងដែរ។

កម្រិតទាបជាងមុននៃឧបសគ្គក្នុងពាណិជ្ជកម្មនឹងបង្កើនការរងឥទ្ធិពលនៃការប្រែប្រួលថ្លៃ។ ការប្រកួតប្រជែងខ្ពស់ជាងមុនក៏មានឥទ្ធិពលផងដែរ ដែលនឹងនាំមកនូវអត្ថប្រយោជន៍ដល់ប្រព័ន្ធផលិតកម្មដែលកាន់តែមានប្រសិទ្ធភាព ដោយធ្វើឲ្យប្រព័ន្ធផលិតកម្មដែលគ្មានប្រសិទ្ធភាពត្រូវបង់ខាត។

## ការពាក់ព័ន្ធខាងនយោបាយ

រវាងប្រព័ន្ធទាំងនេះ ការប្រឈមនានាបង្ហាញយ៉ាងច្បាស់អំពីការចាំបាច់ឲ្យមានការកែប្រែ។ ខាងក្រោមនេះបង្ហាញពីការពាក់ព័ន្ធខ្លះៗខាងនយោបាយ៖

- *ការបង្កើនប្រសិទ្ធភាព* គឺជាគោលដៅរួម ដោយគិតគូរផងដែរអំពីភាពចាំបាច់ដើម្បីបង្កើនផលចំណូលរបស់កសិករ នៅក្នុងបរិស្ថានដែលមានភាពប្រកួតប្រជែងកាន់តែខ្លាំង ទន្ទឹមនឹង ការផលិតស្បៀងកាន់តែច្រើនដោយប្រើប្រាស់ទឹកកាន់តែតិច។ នេះជាផលិតកម្មដែលមានប្រសិទ្ធភាពលើការប្រើប្រាស់ទឹក ពោលគឺតោន ក្នុងមួយម៉ែត្រគូបទឹកដែលប្រើប្រាស់ ក៏ដូចជា ប្រសិទ្ធភាពសេដ្ឋកិច្ចផងដែរ ដែលជាតម្លៃកើតចេញពីទឹកមួយម៉ែត្រគូប។
- គោលដៅសំខាន់មួយផ្សេងទៀតគឺ*ការបង្កើតរបរចិញ្ចឹមជីវិត* ត្រូវបានរំពឹងថាភាគច្រើនកើតឡើងនៅក្រៅកសិដ្ឋាន ប៉ុន្តែអាចរាប់បញ្ចូលរបរចិញ្ចឹមជីវិតនៅជនបទផងដែរ ដើម្បីកាត់បន្ថយអត្រានៃចំណាកស្រុកមកទីក្រុង (ដែលមិនអាចជៀសវាងបាន និងអាចផ្តល់ជាផលចំណេញផងដែរ)។ ទីក្រុងត្រូវតែរីកធំឡើង តាមអត្រាដែលអនុញ្ញាតឲ្យសម្បទា ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មនានាលូតលាស់ស្របគ្នានេះដែរ។
- *បុរេសនានៃខ្សែចង្វាក់តម្លៃ* អាចគាំទ្រដល់ការបង្កើនផលចំណូល និងរបរចិញ្ចឹមជីវិត ដូចជា តាមរយៈការលើកទឹកចិត្តឲ្យមានការកែច្នៃកសិផល ដែលរួមទាំង ផលិតផលបង្កើតថ្មី និងមួយផ្នែកធ្វើឡើងតាមបែបវិមជ្ឈការពីសំណាក់សហគ្រាសខ្នាតតូច និងមធ្យមផងដែរ។
- *ការដាក់យីហោ* នៃផលិតផល និងការដាក់លក់ក្នុងទីផ្សារ ជួនកាលអាចបន្ថែមតម្លៃប្រកបដោយការទាក់ទាញដោយត្រូវចំណាយក្នុងកម្រិតសមស្រប។
- *បទប្បញ្ញត្តិទីផ្សារ*ដែលគាំទ្រដល់អ្នកក្រីក្រ ស្លូតបូត អាចយកមកប្រើប្រាស់សម្រាប់គាំទ្រឲ្យមានការប្តូរទៅរកផលិតផលថ្មីៗ (អាចជា ជីវៈឥន្ធនៈ) និងដែលគាំទ្រដល់គោលដៅជាតិជារួមនៃការផ្តល់ស្បៀងអាហារក្នុងតម្លៃដែលអាចជាវបាន ទន្ទឹមនឹងរក្សាបាននូវប្រាក់ចំណូលសម្រាប់កសិករដែលយ៉ាងហោចណាស់ខ្ពស់ជាថ្លៃផលិត។ ភាពព្យាករណ៍បានកម្រិតខ្ពស់នឹងទ្រទ្រង់ដល់ផលចំណូលដែលជាការគ្រោងទុក និងកាត់បន្ថយហានិភ័យនៃឥទ្ធិពលអវិជ្ជមាន។

- *ឥណទាន* ដែលរួមទាំង (ប៉ុន្តែមិនកំហិតត្រឹម) មីក្រូឥណទាន គឺជាលក្ខខណ្ឌដំបូងទូទៅមួយសម្រាប់ការវិនិយោគ និងការច្នៃប្រឌិតបែបថ្មី។ ការធានារ៉ាប់រងលើហានិភ័យខ្លះៗ អាចជួយឲ្យកសិកររក្សាទុកដីធ្លីសម្រាប់បង្ការករណីគ្រោះបន្ទាន់។
- *ត្រូវកំហិតលើការប្រើប្រាស់ទឹក៖* ការកំហិតលើការប្រើប្រាស់ទឹកអាចធ្វើបានសម្រាប់ឧស្សាហកម្មថ្មីៗដែលពឹងផ្អែកលើការប្រើប្រាស់ទឹក ដោយសារឧស្សាហកម្មទាំងនេះអាចបន្សាំបានយ៉ាងងាយស្រួលជាងឧស្សាហកម្មដែលមានស្រាប់ដែលប្រើប្រាស់បច្ចេកវិទ្យាចាស់ៗហើយជួនកាលអាចសំចៃរហូតដល់ទឹក ថាមពល និងប្រាក់ក្នុងពេលជាមួយគ្នាផងដែរ។ ការកំហិតត្រូវតែធ្វើឡើងសម្រាប់ទាំងទឹកលើដី និងទឹកក្រោមដីផងដែរ។
- *ការបង្ការគ្រោះមហន្តរាយ* (សម្រាប់ទឹកជំនន់ គ្រោះរាំងស្ងួត និងកត្តាចង្រៃ) ត្រូវតែដាក់ឲ្យអនុវត្ត។
- *អង្គការកសិករ* (ដូចជា ក្រុមកសិករប្រើប្រាស់ទឹក) អាចសម្រួលឲ្យមានការកែលម្អយ៉ាងមានប្រសិទ្ធភាពការអភិវឌ្ឍបច្ចេកវិទ្យាបែបផ្សេង និងការប្រើប្រាស់ទីផ្សារផងដែរ។
- *ការគ្រប់គ្រងដី* នឹងកាន់តែមានសារៈសំខាន់ (ហើយផលចំណេញកាន់តែអាចសង្កេតឃើញច្បាស់) នៅពេលដែលទឹកកាន់តែខ្សត់ និងទាក់ទងជាមួយការធ្វើពិពិធកម្មដំណាំនៅលើដី ដែលមិនសមស្របសម្រាប់ដំណាំក្រៅពីស្រូវ។
- *ការប្រើប្រាស់ថ្នាំគីមីកសិកម្ម* ត្រូវតែកំហិតត្រឹមកម្រិតដែលអាចទទួលយកបាន ដែលគាំទ្រដោយយុទ្ធនាការអប់រំ និងការយល់ដឹង និងការផ្សព្វផ្សាយ និងសេវាព្យាករណ៍ធាតុអាកាស។
- *ការស្រាវជ្រាវបន្ត* គឺជាតម្រូវការចាំបាច់ ដែលរួមទាំង បណ្តាញការបង្កើតអន្តរជាតិ ការចែករំលែកចំណេះដឹង និងកិច្ចសហការសកម្ម។ លទ្ធផលត្រូវតែផ្សព្វផ្សាយដល់អ្នកប្រើប្រាស់ផ្ទាល់ តាមរយៈសកម្មភាពសាកល្បង និងការអនុវត្តបង្ហាញ សេវាកម្មផ្សព្វផ្សាយដែលមានដំណើរការល្អ និងបណ្តាញការងារក្នុងចំណោមកសិករ ដែលអាចឆ្លងដែនអន្តរជាតិផងដែរ។

ការអភិវឌ្ឍកសិកម្មត្រូវតែមានការប្រុងប្រយ័ត្ន និងអនុវត្តជាលក្ខណៈបណ្តើរៗ។ គេតែងតែមានហានិភ័យដែលមិនអាចដឹងជាមុនអំពីឥទ្ធិពលអវិជ្ជមានដែលអាចកើតឡើង នៅពេលអនុវត្តបច្ចេកវិទ្យាថ្មីៗ និងសូម្បីនៅពេលអនុវត្តបច្ចេកវិទ្យាដែលមានស្រាប់និងដែលមានការអះអាងច្បាស់លាស់រួចហើយក៏ដោយ នៅក្នុងកន្លែងថ្មី។ ប្រសិនបើមនុស្សគ្រប់រូបដាំឪឡឹក យន្តការទីផ្សារនឹងបរាជ័យ។

## អនាគតនៃប៉ូលខែរនៅព្រៃនប់

ការអភិវឌ្ឍដោយចីរភាពនៅក្នុងតំបន់នេះគឺជាការប្រឈមមួយ។ ទិដ្ឋភាពខ្លះៗមានសង្ខេបដូចខាងក្រោម៖

| សំណុំលក្ខណៈអភិវឌ្ឍន៍ប៉ូលខែរព្រៃនប់ | |
|---|---|
| ភាពខ្លាំង | អ្នកភូមិ/ម្ចាស់ដីមានការចាត់ចែងបានល្អ<br>ការគ្រប់គ្រងបានល្អពីសំណាក់ FWUC<br>រងឥទ្ធិពលកម្រិតទាបពីគ្រោះរាំងស្ងួតធៀបនឹងដែនដីគោក (បន្ថែមគុណតម្លៃខាងសន្តិសុខស្បៀងនៃតំបន់នេះ) |

| | |
|---|---|
| ភាពទន់ខ្សោយ | ទិន្នផលទាប<br>កម្មសិទ្ធិដីតិចតួច<br>រយៈកំពស់ទាប(ជិតស្មើកំពស់ទឹកសមុទ្រ) ឧបសគ្គក្នុងការដោះទឹក<br>កំពស់មិនសមស្របសម្រាប់ទំនប់ខាងក្រៅ |
| ឱកាស | សក្តានុពលសម្រាប់ប្រព័ន្ធផលិតកម្មដែលធន់នឹងកម្រិតប្រៃ (តម្លៃទាប-មធ្យម) និងការប្រើប្រាស់ដីសម្រាប់គោលបំណង(តម្លៃខ្ពស់) ក្រៅពីការដាំដំណាំ<br>ទីតាំងល្អ (ជាប់នឹងផ្លូវជាតិលេខ៤) |
| ការគំរាមកំហែង | កំពស់ទឹកសមុទ្រ និងការបន្តស្រុតដី, ការបន្ថែមហានិភ័យនៃទឹកជំនន់ និងការជ្រាបចូលនៃទឹកប្រៃ, និងឧបសគ្គដែលអាចនាំឲ្យទឹកលែងហូរចេញទៅអនាគតដោយសារដីស្រុតចុះ<br>កំណើនធាតុអាកាសមិនប្រក្រតី កម្រិតខ្ពស់នៃការរងឥទ្ធិពលពីខ្យល់ព្យុះ អាចជា គ្រោះថ្នាក់ពីគ្រោះរាំងស្ងួត<br>ហានិភ័យនៃឱនភាពដីផ្លូវដោយសារការដាំទឹក |

## ៣.៤ ការពាក់ព័ន្ធខាងសេដ្ឋកិច្ច-សង្គម និងបរិស្ថាន

### ការប្រឈម និងឱកាស

ការគំរាមកំហែងទូទៅដែលទាក់ទងនឹងអាកាសធាតុ នៅក្នុងតំបន់សិក្សានេះ រាប់បញ្ចូលះ

- សំណឹកឆ្នេរ កាន់តែកើនឡើងដោយសារខ្យល់ព្យុះ និងកំណើនកំពស់ទឹកសមុទ្រ
- ការបាត់បង់របេចិញ្ចឹមជីវិត (ក្នុងកសិកម្ម នេសាទ និងទេចរណ៍)
- ការខូចខាតព្រៃកោងកាង និងផ្កាថ្ម
- ហានិភ័យចំពោះសុខភាពមនុស្ស

ការទទួលបានទឹកស្អាត និងសេវាអនាម័យគឺជាកង្វល់ទូទៅដ៏សំខាន់មួយ។

<u>**ការជ្រើស្រែ**</u>

យុទ្ធសាស្ត្រជាទីទុកចិត្តមួយ (និងដែលមានការទទួលស្គាល់ជាទូទៅ) គឺការប្តូរពីពូជស្រូវធ្ងន់(តាមប្រពៃណី) មកពូជស្រូវកណ្តាលនិងស្រាល(ថ្មី)។ នៅក្នុងតំបន់ឆ្នេរការធ្វើបែបនេះនឹងកាត់បន្ថយហានិភ័យនៃការរងឥទ្ធិពលពីការជ្រាបចូលនៃទឹកប្រៃព្យុះសមុទ្រនិងខ្យល់ខ្លាំង។ នៅក្នុងដែនដីគោកដែលគ្រោះរាំងស្ងួតគឺជាកង្វល់ចំបងពូជស្រូវស្រាលអាចធន់នឹងភាពខ្វះទឹកតាមរដូវ។ មានអ្នកជំនាញការជាតិពូជជាច្រើនដែលបានធ្វើការសាកល្បងនៅក្នុងមូលដ្ឋាន ប៉ុន្តែការអនុវត្តបានសមស្របអាស្រ័យលើបរិបទជាក់លាក់នៅតាមទីកន្លែង និងត្រូវការចំណេះដឹងអំពីលក្ខខណ្ឌធាតុអាកាសនៅមូលដ្ឋាន។ នៅកន្លែងខ្លះក្នុងផ្ទៃប្រទេស ព័ត៌មានបែបនេះអាចទទួលបានពីបណ្តាញនៃស្ថានីយ៍ពិសោធន៍កសិកម្ម ប៉ុន្តែបណ្តាញនេះមានដោយដុំ (និងមិនគ្របដណ្តប់តំបន់ទាំងមូលឡើយនៅក្នុងការសិក្សានេះ)។

គ្រោះរាំងស្ងួតមិនមែនជាបញ្ហាឡើយនៅក្នុងតំបន់សិក្សានេះ (ទោះបីមានភស្តុតាងខ្លះៗអំពីគ្រោះរាំងស្ងួតក៏ដោយនៅទឹកល្អក់នៅដើមរដូវដាំដំណាំក៏ដោយ)។ ការប្រែប្រួលអាកាសធាតុត្រូវបានរំពឹងថានឹងបង្កឲ្យធាតុអាកាសកាន់តែមានភាពមិនប្រក្រតី ដែលអាចរួមបញ្ចូលកូនរដូវប្រាំងកាន់តែញឹកញាប់នៅដើមរដូវវស្សា (នេះគឺជាករណីទូទៅនៅកម្ពុជា)។ ប្រសិនបើកើតមានបែបនេះតំបន់នេះអាចងាយរងគ្រោះដោយសារកសិករ (និងអាជ្ញាធរ)មិនដឹងអំពីការប្រឈមនេះ។ បទពិសោធន៍មាននៅតាមបណ្តាខេត្តតាមតំបន់ទឹកសាបនឹងអាចចែករម្លែកជាមួយតំបន់ឆ្នេរ។

__ការចិញ្ចឹមសត្វ__

ការចិញ្ចឹមសត្វមិនគួរមើលរម្លងឡើយដោយសារវាផ្តល់ជាប្រភពប្រាក់ចំណូល និងយ៉ាងហោចណាស់ (នៅក្នុងករណីក្របី និងគោ) ជាហិរញ្ញវត្ថុបម្រុងសម្រាប់គ្រួសារនានា ដែលប្រសិនបើគ្មានទេនោះធ្វើឲ្យពួកគេងាយរងគ្រោះ។ គេឃើញមានភាពខុសគ្នានៅក្នុងតំបន់សិក្សាដែលទាក់ទងនឹងស្ថានភាពនៃការចិញ្ចឹមសត្វសូម្បីនៅក្នុងអនាគតខ្លីខាងមុខក៏ដោយភាគច្រើន (ជាក់ស្តែង) ដោយសារតែពូជសត្វខុសៗគ្នា។ សម្រាប់ពូជសត្វខុសៗគ្នាការចំណាយលើចំណីត្រូវបានចាត់ទុកថាមានកម្រិតខ្ពស់ធៀបនឹងប្រាក់ចំណូល ដែលអាចទទួលបាន។ នេះក៏ជាករណីសម្រាប់ការចិញ្ចឹមត្រីផងដែរ។ ផលចំណេញមាន "តិចតួចណាស់" ឬគ្មានផលចំណេញផងក៏សឹងមាន។ ការចាក់ថ្នាំបង្ការត្រូវបានសាកល្បងនៅតាមតំបន់ខ្លះៗ ចំណែកនៅតំបន់ដទៃទៀតកសិករមិនសូវមានការជឿជាក់ឡើយ។

**យោបល់អំពីសកម្មភាពអនុវត្តបង្ហាញ**

សកម្មភាពអនុវត្តបង្ហាញដែលសមស្របមានលក្ខណៈដូចតទៅ៖

- ការគាំទ្រពីអ្នកទទួលផល និងស្ថាប័នពាក់ព័ន្ធ
- ផលចំណេញច្បាស់លាស់ខាងសង្គមបរិស្ថាន និង/ឬសេដ្ឋកិច្ច ដែលសម្រេចបាននៅក្នុងរយៈពេលសមស្របជាពិសេសដែលរួមទាំងរបរចិញ្ចឹមជីវិតផងដែរ
- ហានិភ័យកម្រិតទាបជាទូទៅ និងត្រូវឲ្យគ្រួសារនានាចូលរួមពាក់ព័ន្ធ និង
- តម្រូវការធនធានជាក់ស្តែង ដែលរួមទាំងសមត្ថភាពរបស់ស្ថាប័នអនុវត្ត និងដៃគូផងដែរ

សកម្មភាពខ្លះៗ ដែលគួរអនុវត្តត្រូវបានកំណត់អត្តសញ្ញាណសម្រាប់ការពិចារណាបន្ថែម ដូចមានបង្ហាញខាងក្រោម៖

__លក្ខណៈទូទៅ__

*ការគាំទ្រដល់ការបង្កើត/ពង្រឹងសហគមន៍កសិករ និងសហគមន៍នេសាទ* (ដើម្បីបង្កើតជាបណ្តាញ និងរៀនសូត្រពីគ្នាទៅវិញទៅមក, ព័ត៌មានអំពីបច្ចេកវិទ្យាផលិតកម្ម និងបច្ចេកវិទ្យាត្រួតពិនិត្យការខូចខាត, ការលក់ផលិតផលដោយឡែកការអភិរក្សធនធាន និងអាចការសន្សំ/មីក្រូឥណទាន/ការធានារ៉ាប់រងផងដែរ)។ កិច្ចការទាំងនេះ អាចធ្វើឡើងទៅតាមផ្នែក/ប្រធានបទជាងទៅតាមតំបន់ភូមិសាស្ត្រ។

*គាំទ្រដោយផ្ទាល់ដល់គ្រួសារកសិករ*ដែលមានឧទាហរណ៍អំពីការប្រើប្រាស់ពូជដែលមានគុណភាពខ្ពស់ (ដែលរួមទាំងពូជស្រូវស្រាល) ការប្រើប្រាស់ជីអសរីរាង្គ ការត្រួតពិនិត្យកត្តាចង្រៃ ការបង្កាត់ពូជសត្វចិញ្ចឹម និងការចាក់ថ្នាំបង្ការដល់សត្វចិញ្ចឹម និងការដាំដំណាំបន្ថែមជាទ្រង់ទ្រាយតូចនៅរដូវប្រាំង។

<u>**ឃុំពាមក្រសោប និងទួលគគីរខេត្តកោះកុង**</u>

តំបន់ទួលគគីរទទួលរងឥទ្ធិពលពីការជ្រាបចូលនៃទឹកប្រៃពីកម្រិតធ្ងន់ធ្ងរដល់តិចតួច ហើយទិន្នផលមានភាពខុសគ្នាពីប្រមាណ១ដល់ប្រមាណ៣ត/ហ.ត/ឆ្នាំ។ កសិករមានលក្ខណៈច្នៃប្រឌិត (ប្រើប្រាស់ពូជប្រមាណ ១០មុខខុសៗគ្នា) ហើយមន្ទីរកសិកម្មចូលរួមយ៉ាងសកម្មនៅក្នុងការផ្តល់ការណែនាំ ដែលទាក់ទងនឹងពូជស្រូវ និងការដាំដំណាំខុសៗគ្នា និងបច្ចេកទេសគ្រប់គ្រងការខូចខាត។ តំបន់នេះអាចផ្តល់ជា *"មន្ទីរពិសោធន៍មួយ" សម្រាប់កំណត់អត្តសញ្ញាណពូជសមស្រប និងទម្លាប់នៃការអនុវត្ត* ដែលសាកល្បងជម្រើសខុសៗគ្នាក្នុងពេលស្របគ្នា និងមានការចងក្រងជាឯកសារសមស្របអំពីបរិស្ថាន (កំពស់ទឹកភ្លៀងចំណាំងកាំរស្មីព្រះអាទិត្យការរង ឥទ្ធិពលពីទឹកសមុទ្រព្រឹត្តិការណ៍ធាតុអាកាសអវិជ្ជមានការវាយប្រហារពីកត្តាចង្រៃ។ល។)។ ការប្រើប្រាស់ដីគីមីមិនសមស្របក៏អាចស្ថិតក្នុងការចងក្រងផងដែរ។ កសិករដែលជាអ្នកចូលរួមត្រូវតែមានកិច្ចការពារពីហានិភ័យខាងសេដ្ឋកិច្ច។ សកម្មភាពបែបនេះអាចផ្តល់ចំណេះដឹងដែលមានប្រយោជន៍ដល់តំបន់ឆ្នេរនៅកន្លែងផ្សេងទៀតនៅក្នុង និងនៅក្រៅប្រទេសកម្ពុជាក្នុងករណីដែលមានការផ្សព្វផ្សាយលទ្ធផល៖

- *ការគាំទ្រដល់ការផ្សព្វផ្សាយ និងការលើកកំពស់បទពិសោធន៍ដែលមានថ្មីៗ និងច្បាស់លាស់ដែលអាចផ្តល់ផលពីរដងក្នុងមួយឆ្នាំ* ដោយប្រើប្រាស់ពូជ និងបច្ចេកទេសដាំដំណាំសមស្រប។ កាលពីឆ្នាំទៅមានការសាកល្បងដំណាំបែបនេះលើផ្ទៃដី២ហិកតា ដោយប្រើប្រាស់ពូជពី CARDI ហើយកន្លែងនោះត្រូវបានពង្រីកនៅក្នុងឆ្នាំនេះ។

  *ការគាំទ្រចំពោះការប្រើប្រាស់ដីសមស្រប និងការគ្រប់គ្រងដី*នៅក្នុងតំបន់ជាប់នឹងព្រៃកោងកាង (ដែលមួយផ្នែកកំពុងស្ថិតក្នុងស្ថានភាពនៃការខូចខាតយ៉ាងឆាប់រហ័ស)។
- *ការគាំទ្រដល់ការកំណត់ដែននេសាទសហគមន៍* (ដូចដែលបានលើកស្នើនៅក្នុងពេលពិគ្រោះយោបល់ជាមួយតំណាងស្រុក និងឃុំនៅខែឧសភា ឆ្នាំ២០១២)។ កិច្ចប្រឹងប្រែងបានធ្វើឡើងអស់រយៈពេលមួយទសវត្សរ៍រួចមកហើយនៅក្រោម CBNRM និង IDRC ប៉ុន្តែសកម្មភាពនេះទំនងជានៅត្រូវការឲ្យអនុវត្តនៅឡើយ។

<u>**ឃុំអូរឧកញ៉ាហេងព្រៃនប់ និងទួលទទឹងនៃខេត្តព្រះសីហនុ**</u>

- *ប្រព័ន្ធដាំដើមឈើ*ដើម្បីប្រើប្រាស់ជារបាំងខ្យល់ដោយប្រើប្រាស់ប្រភេទឈើសមស្រប ដែលអាចផ្តល់អត្ថប្រយោជន៍ថែមទៀត។ ប្រភេទឈើដែលអាចដាំបានរួមមានដើមសង្កែ និងដើមរាំងបឹង ដែលពូជទាំងពីរនេះមាននៅក្នុងមូលដ្ឋានស្រាប់។ បេក្ខភាពមួយផ្សេងទៀតគឺដើម theteaptues ។ ការចងក្រងបានសមស្របជាឯកសារអំពីសកម្មភាពអនុវត្តបង្ហាញបែបនេះអាចផ្តល់ជាឧទាហរណ៍ ដែលមានប្រយោជន៍សម្រាប់ការពង្រីកទៅអនុវត្តនៅកន្លែងផ្សេង។
- *ការបែងចែងប៉ុលឌែរជាផ្នែកតូចៗ* (ដើម្បីកាត់បន្ថយឥទ្ធិពលពីការជ្រាបចូលនៃទឹកប្រៃ)។ កង្វល់មួយក្នុងបញ្ហានេះគឺការពាក់ព័ន្ធនៃការដោះទឹកដែលត្រូវពិចារណាអំពីការបង្កើនលទ្ធភាពបន្ថែមទៀត។
- *ការតាមដានជាលក្ខណៈប្រព័ន្ធអំពីការជ្រាបចូលនៃទឹកប្រៃ និងការស្រុកចុះនៃកំពស់ដី*។

**<u>ឃុំសាមគ្គីទឹកល្អក់ និងទឹកថ្លាខេត្តព្រះសីហនុ</u>**

- *ការគាំទ្រដល់ការប្រើប្រាស់ជីគីមី និងថ្នាំគីមីកសិកម្មឲ្យបានសមស្រប*
- *លើកកំពស់របរចិញ្ចឹមជីវិតជាបន្ថែម*ដែលរួមទាំងដំណាំបន្លែមជាទ្រង់ទ្រាយតូច និងការចិញ្ចឹមសត្វ
- *លើកកំពស់ពូជល្អជាងមុន* ជាពិសេសពូជស្រូវស្រាលដែលផ្តល់ទិន្នផលផលខ្ពស់
- *ការគាំទ្រដល់របរចិញ្ចឹមជីវិតជាបន្ថែម*ដែលរួមទាំង និងការចិញ្ចឹមសត្វ។ កិច្ចការនេះអាចពាក់ព័ន្ធជាមួយការបង្កើតបណ្តាញក្នុងចំណោមកសិករនៅក្នុងនិងក្រៅតំបន់នេះដើម្បីរៀនសូត្រពីគ្នាទៅវិញទៅមក។

<u>ការកត់សំគាល់</u>

ទម្លាប់អនុវត្តភាគច្រើននៅក្នុងកសិកម្មសព្វថ្ងៃនេះតាមទីតាំងសិក្សាពុំបង្ហាញពីនិរន្តរភាពឡើយ។ សូម្បីមានទិន្នផលស្រូវដែលខ្ពស់ជាងមុន និងអាចលក់នៅតាមកសិដ្ឋានដោយថ្លៃខ្ពស់ជាងមុនក៏ដោយគ្រួសារជាច្រើននៅតែជាប់ក្នុងអន្ទាក់នៃភាពក្រីក្រ ប្រសិនបើពួកគេពឹងផ្អែកតែលើការដាំដំណាំដែលមានស្រាប់ជារបរចិញ្ចឹមជីវិតចំបងៗរបស់ខ្លួន។

អន្តរកាលរវាងសព្វថ្ងៃ និងអនាគតគឺជាការប្រឈមចំបងមួយ។ ប្រសិនបើអនុវត្តដោយរលូនវិស័យនេះនឹងមានវិបុលភាព និងភាពប្រកួតប្រជែងមានលទ្ធភាពរឹងមាំក្នុងការផ្តល់ប្រាក់ចំណូលដល់កសិករ និងផ្តល់ជាស្បៀងសម្រាប់ប្រជាជន។ ប្រសិនបើអនុវត្តមិនសូវរលូនទេនោះ វាអាចនឹងបង្កហានិភ័យនៃភាពគ្មានការងារធ្វើ ហើយប្រាក់ចំណូលពីកសិដ្ឋានអាចនឹងមានទាបជាងសព្វថ្ងៃទៅទៀត។ ប្រការនេះអាចកើតឡើងប្រសិនបើការប្រែប្រួលកើតឡើងឆាប់ហ័សពេក ឬដោយគ្មានការគាំទ្របានសមស្រប។

# ៤. ការវាយតម្លៃភាពងាយរងគ្រោះ និងហានិភ័យសហគមន៍

ជំពូកនេះគឺជាសេចក្តីសង្ខេបអំពីការវាយតម្លៃភាពងាយរងគ្រោះ និងហានិភ័យចំពោះរបរចិញ្ចឹមជីវិតនៅក្នុងសហគមន៍គោលដៅរបស់ CARP ដែលទាក់ទងនឹងលក្ខខណ្ឌបច្ចុប្បន្ននៃអាកាសធាតុ និងនិន្នាការដែលបានទស្សន៍ទាយក្នុងគោលដៅណែនាំអំពីរបរចិញ្ចឹមជីវិតជំនួសឬកែប្រែ។

ការវាយតម្លៃនេះត្រូវបានចាត់ទុកជាធាតុចេញ២.៤ នៃ CARP។ កិច្ចការនេះបានផ្អែកលើការពិគ្រោះយោបល់ជាមួយ CCCA និងអ្នកពាក់ព័ន្ធនានានៅថ្នាក់ខេត្ត និងថ្នាក់ឃុំពីខែមេសា-មិថុនា ឆ្នាំ២០១២។

ការវាយតម្លៃពេញលេញ - "ការវាយតម្លៃភាពងាយរងគ្រោះនិងហានិភ័យរបស់សហគមន៍ដោយសារការប្រែប្រួលអាកាសធាតុនៅក្នុងតំបន់ឆ្នេរនៃប្រទេសកម្ពុជា" ខែតុលាឆ្នាំ២០១២ -អាចចម្លងចេញពីវេបសាយរបស់ CARP (www.czmcam.org).

## ៤.១ ការវាយតម្លៃភាពងាយរងគ្រោះ និងហានិភ័យ

ការវាយតម្លៃភាពងាយរងគ្រោះនិងហានិភ័យនៅឃុំព្រៃនប់ពាមក្រសោប និងទួលគគីរ បានផ្តោតលើសេណារីយ៉ូហានិភ័យ ដែលអាចកើតមានចំនួនបួន ពោលគឺការបាត់បង់ដំណាំនៅក្នុងរដូវវស្សា ការបាត់បង់ដំណាំនៅរដូវប្រាំង ការបាត់បង់សត្វចិញ្ចឹម និងការបាត់បង់ឱកាសធ្វើនេសាទ។ លើសពីនេះគួរកត់សំគាល់ថាការវាយតម្លៃនេះផ្តោតលើប្រភពនៃប្រាក់ចំណូលបច្ចុប្បន្ន។ លទ្ធផលនៃការវាយតម្លៃមានសង្ខេបដូចខាងក្រោម៖[2]

### ឃុំពាមក្រសោប

ដំណាំនៅរដូវវស្សា៖សេណារីយ៉ូហានិភ័យដែលទាក់ទងនឹងការបាត់បង់ផលដំណាំនៅក្នុងរដូវវស្សាត្រូវបានវាយតម្លៃថាមានហានិភ័យកម្រិតមធ្យមរហូតដល់ឆ្នាំ២១០០។ ទោះបីកំណើនកំពស់ទឹកសមុទ្រ និងកំណើន ការធ្លាក់ភ្លៀងនឹងមានឥទ្ធិពលមកលើដីដាំដំណាំ និងទឹកជំនន់ក៏ដោយដំណាំ (ស្រូវ) មានតួនាទីតិចតួចប៉ុណ្ណោះ ជាប្រភពប្រាក់ចំណូលសម្រាប់សមាជិកសហគមន៍។ ជាក់ស្តែងនៅពាមក្រសោបមានតែផ្ទៃដីត្រឹមប៉ុន្មានហិកតាប៉ុណ្ណោះដែលអាចដាំដំណាំបាន។ ដូច្នេះបើទោះជាមានភវនីយភាពកម្រិតខ្ពស់ដែលដំណាំ (នៅក្នុងរដូវវស្សា) នឹងត្រូវបាត់បង់ដោយសារតែការប្រែប្រួលអាកាសធាតុក៏ដោយ ផលវិបាកពីបញ្ហានេះអាចធ្ងន់ធ្ងរខ្លាំងណាស់។

ដំណាំនៅរដូវប្រាំង៖សេណារីយ៉ូហានិភ័យនៃការបាត់បង់ដំណាំនៅក្នុងរដូវប្រាំង ត្រូវបានវាយតម្លៃថាមានហានិភ័យកម្រិតទាប។ ដូចដែលមានចែងនៅក្នុងផ្នែកខាងលើ មានតែផ្ទៃដីតិចតួចប៉ុណ្ណោះដែលអាចដាំដំណាំបាន។ ដូច្នេះវាអាចនឹងមានការប៉ះទង្គិចមិនសូវធ្ងន់ធ្ងរឡើយសម្រាប់គ្រួសារនានានៅពាមក្រសោប។

ការចិញ្ចឹមសត្វ៖សេណារីយ៉ូហានិភ័យនៃការបាត់បង់សត្វចិញ្ចឹមត្រូវបានវាយតម្លៃថា មានហានិភ័យកម្រិតទាប។ នៅពាមក្រសោបសត្វចិញ្ចឹមមិនមានតួនាទីសំខាន់ជាប្រភពប្រាក់ចំណូលឡើយ។ ដោយពិចារណាអំពីចំណុចនេះទាំងភវនីយភាព និងផលវិបាកនៃការបាត់បង់សត្វចិញ្ចឹមមិនមានកម្រិតធ្ងន់ធ្ងរឡើយ។

---

[2] តារាងម៉ាទ្រិកលទ្ធផល វិធីសាស្ត្រដែលប្រើប្រាស់សម្រាប់ការវាយតម្លៃក៏ដូចជា ស្ថានភាពនៃរបរចិញ្ចឹមជីវិតនៅក្នុងឃុំគោលដៅ អាចចម្លងចេញពី "ការវាយតម្លៃភាពងាយរងគ្រោះរបស់សហគមន៍ និងហានិភ័យនៃការប្រែប្រួលអាកាសធាតុនៅក្នុងតំបន់ឆ្នេរកម្ពុជា", ខែតុលា ឆ្នាំ ២០១២។

ការនេសាទ៖ សេណារីយ៉ូហានិភ័យនៃការបាត់បង់ឱកាសធ្វើនេសាទត្រូវបានវាយតម្លៃថា មានកម្រិតខ្ពស់នៅក្នុងរយៈពេលវែង។ កំណើនសីតុណ្ហភាព (សមុទ្រនិងខ្យល់) ការឡើងជូរនៃទឹកសមុទ្រ កំណើនកំពស់ទឹកសមុទ្រ និងបរិមាណច្រើននៃទឹកភ្លៀងត្រូវបានប៉ាន់ប្រមាណថានឹងបង្កការបាត់បង់យ៉ាងច្រើនសម្រាប់ព្រៃកោងកាង ស្មៅសមុទ្រ និងទីជម្រកដទៃទៀតដែលផ្តល់ជាកន្លែងជ្រកកោន និងអាហារសម្រាប់ត្រីក្នុងតំបន់ឆ្នេរ។ ការវិវត្តទាំងនេះនឹងធ្វើឲ្យមានការប្រែប្រួលអវិជ្ជមានមកលើរបាយ និងផលិតភាពមច្ឆជាតិក៏ដូចជាមកលើបរបចិញ្ចឹមជីវិតរបស់ប្រជាជននៅពាមក្រសោបផងដែរ ដោយហេតុថាអ្នកភូមិជិត៩៥% ធ្វើនេសាទ ចំណែកគ្រួសារ ៦៤% មានការនេសាទជាមុខរបរចំបង។

សេណារីយ៉ូហានិភ័យទាក់ទងនឹងការបាត់បង់ឱកាសធ្វើនេសាទ ត្រូវបានវាយតម្លៃថាមានកម្រិតខ្ពស់នៅពេលជិតដល់ឆ្នាំ២១០០។ ពាមក្រសោបផ្សំភាគច្រើនដោយទឹក និងព្រៃកោងកាង ហើយការនេសាទគឺជាប្រភពសំខាន់នៃប្រាក់ចំណូលសម្រាប់ប្រជាជន។ ការប្រែប្រួលអាកាសធាតុ (និងជាពិសេសកំណើនកំពស់ទឹកសមុទ្រ) ទំនងជាបង្កការបាត់បង់យ៉ាងធំធេងចំពោះទីជម្រកនានា (ជាពិសេសព្រៃកោងកាង) ដែលផ្តល់ទីជម្រក និងចំណីសម្រាប់ត្រី។ ការវិវត្តបែបនេះទំនងជាធ្វើឲ្យមានការប្រែប្រួលអវិជ្ជមានមកលើរបាយ និងផលិត-ភាពនៃការនេសាទ ដូច្នេះមកលើបរបចិញ្ចឹមជីវិតរបស់ប្រជាជន។ ទោះជាយ៉ាងណាក៏ដោយក៏នៅមានលទ្ធភាពដែលព្រៃកោងកាងអាចនៅបន្តលូតលាស់នៅក្នុងស្ថានភាពបែបនេះ ឬត្រូវឡើងគោក។ ស្ថានភាពនេះអាស្រ័យលើអត្រានៃកំណើនកំពស់ទឹកសមុទ្រ និងថាតើមានកំណកល្បាប់គ្រប់គ្រាន់ដែរឬទេ។ ទោះជាយ៉ាងណាក៏ដោយមានភាពមិនប្រាកដប្រជាខ្លះៗអំពីថាតើសេណារីយ៉ូនេះនឹងកើតឡើង ឬយ៉ាងណា។ ក្នុងន័យនេះភាវនីយភាពនៃការបាត់បង់ឱកាសនេសាទមិនសូវមានទំហំធំធេងដូចផលវិបាកឡើយ។ ដូច្នេះពាមក្រសោបត្រូវបានចាត់ទុកក្នុងជំពូកហានិភ័យកម្រិតខ្ពស់។

លក្ខណៈទូទៅ៖ បច្ចុប្បនេះមានសម្ពាធដែលគ្មាននិរន្តរភាពមកលើភាវៈរស់ក្នុងសមុទ្រនៅពាមក្រសោម។ មិនត្រឹមតែអ្នករស់នៅទីនេះប៉ុណ្ណោះទេដែលរងការគំរាមកំហែងពីការប្រែប្រួលរបបអាកាសធាតុ ប៉ុន្តែប្រភពប្រាក់ចំណូលរបស់ពួកគេ ការនេសាទក៏ស្ថិតក្នុងគ្រោះថ្នាក់ផងដែរ មួយផ្នែកគឺដោយសារការនេសាទហួសកម្រិត (និងការប្រែប្រួលអាកាសធាតុ)។ ទោះជាយ៉ាងណាក៏ដោយការប្តូរភូមិពាមក្រសោបមកក្នុងដែនដីគោកអាចផ្តល់ឱកាសសម្រាប់បង្កើនលទ្ធភាពរកប្រាក់ចំណូលពីការដាំដំណាំលើដីនៅក្រោយផ្ទះផងដែរ។ គួរកត់សំគាល់ថាអ្នកភូមិបានចាត់ចែងខ្លួនឯងដើម្បីធ្វើអេកូទេសចរណ៍ ដែលបានក្លាយជាប្រភពចំណូលមួយបែបដែលមានការទាក់ទាញ។ ទោះជាយ៉ាងណាក៏ដោយដោយសារការប្រែប្រួលអាកាសធាតុដែលគំរាមកំហែងមកលើតំបន់ដែលមានសក្តានុពលខាងទេសចរណ៍ផងដែរនោះ (ភាគច្រើនគឺព្រៃកោងកាង) និរន្តរភាពរយៈពេលវែងនៃសកម្មភាពនេះក៏ងាយរងគ្រោះផងដែរ។ ក្រៅពីនេះមានហានិភ័យនៃការជន់លិចដោយសារទឹកប្រៃលើកលែងតែសាងសង់ទំនប់ការពារទឹកប្រៃនឹងធ្វើឲ្យសកម្មភាពដាំដំណាំតាមធម្មតាមិនអាចប្រព្រឹត្តទៅបានឡើយ ចំណែកផ្ទះសំបែងក៏អាចត្រូវប្តូរទៅក្នុងឃុំជិតខាងផងដែរ។

## ឃុំទួលគគីរ

ដំណាំនៅក្នុងរដូវវស្សា៖ សេណារីយ៉ូហានិភ័យនៃការបាត់បង់ដំណាំនៅរដូវវស្សា ត្រូវបានវាយតម្លៃថាមានកម្រិតធ្ងន់ធ្ងរនៅក្នុងរយៈពេលវែង។ នៅទួលគគីរប្រភពសំខាន់បំផុតនៃប្រាក់ចំណូលគឺស្រូវ (ច្រើនជាងពាក់កណ្តាលនៃប្រាក់ចំណូលប្រចាំគ្រួសារគឺបានមកពីដំណាំ)។ កំណើនកំពស់ទឹកសមុទ្រអាចបង្កជាការជន់

លិចដីដាំដំណាំ។ កំណើនកំពស់ទឹកសមុទ្រក៏មានឥទ្ធិពលមកលើគុណភាពដី និងទឹកក្រោមដីផងដែរ ដោយសារតែការឡើងប្រៃ។ ទឹកភ្លៀងក៏ត្រូវបានទស្សន៍ទាយថានឹងកើនឡើងផងដែរទៅអនាគត។ ការធ្លាក់ភ្លៀងកាន់តែញឹកញាប់ និងខ្លាំងជាងមុននឹងបង្កើនលទ្ធភាពនៃការជន់លិចផងដែរ ដែលនឹងធ្វើឲ្យខូចខាតផលដំណាំ។ ដូច្នេះការបាត់បង់ដំណាំ(ស្រូវ) នឹងបង្កផលវិបាកធ្ងន់ធ្ងរសម្រាប់ទួលគគីរ។

ដំណាំនៅរដូវប្រាំង៖ សេណារីយ៉ូហានិភ័យនៃការបាត់បង់ផលដំណាំនៅរដូវប្រាំង ត្រូវបានប៉ាន់ប្រមាណថាមានកម្រិតមធ្យមនៅក្នុងរយៈពេលវែង។ នៅក្នុងសេណារីយ៉ូហានិភ័យ កំណើនកំពស់ទឹកសមុទ្រក៏ធ្វើឲ្យខូចដីដាំដំណាំផងដែរ។ កំណើនសីតុណ្ហភាពនិ ងកំណើនលទ្ធភាពនៃគ្រោះរាំងស្ងួតអាចបង្កើនតម្រូវការឲ្យមានការស្រោចស្រព។ ទោះជាយ៉ាងណាក៏ដោយ ដោយហេតុថាវាគ្រាន់តែជាដំណាំបំពេញបន្ថែមដែលដាំនៅក្នុងរដូវប្រាំង (ពោលគឺបន្លែ) ផលវិបាកនៃការបាត់បង់ផលដំណាំទាំងនេះនឹងមិនធ្ងន់ធ្ងរឡើយ បើទោះជាភវនីយភាពនៃសេណារីយ៉ូនេះមានហានិភ័យកម្រិតខ្ពស់ក៏ដោយ។

ការចិញ្ចឹមសត្វ៖ សេណារីយ៉ូហានិភ័យនៃការបាត់បង់សត្វចិញ្ចឹមត្រូវបានប៉ាន់ប្រមាណថា ស្ថិតក្នុងជំពូកហានិភ័យកម្រិតមធ្យមនៅក្នុងរយៈពេលវែង។ ការធ្លាក់ភ្លៀងកាន់តែញឹកញាប់ និងខ្លាំងជាងមុន នឹងបង្កើនភវនីយភាពនៃទឹកជំនន់។ កំណើនកំពស់ទឹកជំនន់នឹងធ្វើឲ្យខូចគុណភាពដី និងទឹកដែលនឹងមានឥទ្ធិពលអវិជ្ជមានមកលើសុខភាពសត្វចិញ្ចឹមជារួម។ កំណើនសីតុណ្ហភាព និងរលកកំដៅនាំឲ្យមានកំណើននៃការគំរាមកំហែងមកលើសត្វចិញ្ចឹមដែលរងគ្រោះពីសម្ពាធនៃកំដៅ។ ផលវិបាកនៃការបាត់បង់សត្វចិញ្ចឹមអាចមានកម្រិតធ្ងន់ធ្ងរមកលើរបរចិញ្ចឹមជីវិតនៅទួលគគីរ ដោយសារសត្វចិញ្ចឹមមិនត្រឹមតែជាប្រភពចំបងនៃប្រាក់ចំណូលប៉ុណ្ណោះទេ (សត្វចិញ្ចឹមផ្តល់ជាប្រភពចំណូលមួយភាគប្រាំ) ប៉ុន្តែក៏សំខាន់ផងដែរនៅក្នុងវដ្តនៃកម្លាំងពលកម្មជារួមនៅក្នុងកសិកម្ម។ ប៉ុន្តែភវនីយភាពនៃការកើនឡើងនៃសេណារីយ៉ូហានិភ័យនេះ មិនមានទំហំធំឡើយ ដូច្នេះមានហានិភ័យកម្រិតមធ្យម។

ការនេសាទ៖ សេណារីយ៉ូហានិភ័យនៃការនេសាទ ត្រូវបានប៉ាន់ប្រមាណមានកម្រិតមធ្យមនៅក្នុងរយៈពេលវែង។ កំណើនសីតុណ្ហភាព (ទឹកសមុទ្រ និងខ្យល់) ការឡើងជួរនៃទឹកសមុទ្រ កំណើនកំពស់ទឹកសមុទ្រ និងបរិមាណច្រើននៃទឹកភ្លៀង ត្រូវបានទស្សន៍ទាយថានឹងបង្កការបាត់បង់យ៉ាងច្រើនចំពោះព្រៃកោងកាង ស្មៅសមុទ្រ និងទីជម្រកនានាដែលផ្តល់ជាកន្លែងជ្រកកោន និងចំណីសម្រាប់មច្ឆជាតិក្នុងតំបន់ឆ្នេរ។ ទោះជាយ៉ាងណាក៏ដោយ ដោយហេតុថាការនេសាទនៅទួលគគីរគ្រាន់តែជាប្រភពប្រាក់ចំណូលបន្ថែម ពោលគឺដំណាំបន្ទាប់បន្សំផលវិបាកមិនទំនងជាធ្ងន់ធ្ងរឡើយ។

## ឃុំព្រៃនប់

ដំណាំនៅក្នុងរដូវវស្សា៖ លទ្ធភាពក្នុងការបាត់បង់ដំណាំ (ស្រូវ)នៅក្នុងរដូវវស្សាត្រូវបានប៉ាន់ប្រមាណថាមានហានិភ័យធ្ងន់ធ្ងរនៅពេលខិតទៅជិតឆ្នាំ២១០០។ សេណារីយ៉ូចំនួនពីរនៃការប្រែប្រួលអាកាសធាតុត្រូវបានទស្សន៍ទាយថាមានឥទ្ធិពលដោយផ្ទាល់មកលើប្រការនេះ។ ជាបឋមកំណើនកំពស់ទឹកសមុទ្រអាចបង្កឲ្យជន់លិចដីដាំដំណាំ។ កំណើនកំពស់ទឹកសមុទ្រ ក៏មានឥទ្ធិពលមកលើគុណភាពដី និងទឹកក្រោមដីផងដែរទាក់ទងនឹងការធ្វើឲ្យឡើងប្រៃទាំងដី និងទឹកក្រោមដី។ ទោះតាមទម្រង់ណាមួយក៏ដោយ កំណើនកំពស់ទឹកសមុទ្រនឹងធ្វើឲ្យខូចដីដាំដំណាំនៅព្រៃនប់។ លើសពីនេះការស្រុតដីអាចបង្កជាការគំរាមកំហែងរឹងតែធ្ងន់ធ្ងរ។ ការធ្លាក់ភ្លៀងក៏ត្រូវបានទស្សន៍ទាយថាកើនឡើងផងដែរទៅអនាគត។ ភ្លៀងធ្លាក់កាន់តែញឹកញាប់ និងកាន់តែ

ខ្លាំងនឹងបង្កើនលទ្ធភាពនៃការជន់លិចដែលធ្វើឲ្យខូចដំណាំ។ នៅព្រៃនប់ដំណាំនៅតែជាប្រភពប្រាក់ចំណូលសំខាន់តែមួយសម្រាប់គ្រួសារនានា (បីភាគបួននៃប្រាក់ចំណូលរបស់គ្រួសារនានា គឺបានពីដំណាំ)។ ដូច្នេះការបាត់បង់ដំណាំ(ស្រូវ) នឹងបង្កផលវិបាកធ្ងន់ធ្ងរសម្រាប់ព្រៃនប់ ដូចកម្រិតភវនីយភាពខ្ពស់ ដែលអាចកើតឡើងក្នុងសេណារីយ៉ូហានិភ័យនេះផងដែរ។

ដំណាំនៅក្នុងរដូវប្រាំង៖ សេណារីយ៉ូហានិភ័យនៃការបាត់បង់ដំណាំនៅក្នុងរដូវប្រាំង ត្រូវបានប៉ាន់ស្មានថាមានហានិភ័យកម្រិតមធ្យមនៅពេលឈានជិតដល់ឆ្នាំ២១០០។ នៅក្នុងសេណារីយ៉ូហានិភ័យនេះកំណើនកំពស់ទឹកសមុទ្រក៏អាចធ្វើឲ្យខូចដីដាំដំណាំផងដែរ។ កំណើនសីតុណ្ហភាព និងកំណើនលទ្ធភាពនៃគ្រោះរាំងស្ងួតនឹងបង្កើនតម្រូវការឲ្យមានការស្រោចស្រព។ ទោះជាយ៉ាងណាក៏ដោយ ដោយហេតុថាវាគ្រាន់តែជាដំណាំបន្ថែមដែលដាំនៅក្នុងរដូវប្រាំង (ពោលគឺបន្លែ) ផលវិបាកនៃការបាត់បង់ផលដំណាំទាំងនេះនឹងពុំមានកម្រិតធ្ងន់ធ្ងរឡើយទោះបីភវនីយភាពនៃសេណារីយ៉ូហានិភ័យនេះមានកម្រិតខ្ពស់ក៏ដោយ។ ដូច្នេះវាមានហានិភ័យកម្រិតមធ្យម។

ការចិញ្ចឹមសត្វ៖ សេណារីយ៉ូហានិភ័យនៃសត្វចិញ្ចឹម ត្រូវបានប៉ាន់ប្រមាណថាស្ថិតក្នុងជំពូកហានិភ័យមធ្យមកាលណាខិតកាន់តែជិតឆ្នាំ២១០០។ ការធ្លាក់ទឹកភ្លៀងកាន់តែញឹកញាប់ និងកាន់តែខ្លាំងនឹងបង្កើនភវនីយភាពនៃទឹកជំនន់។ ចំណែកគ្រោះរាំងស្ងួតកាន់តែខ្លាំងនៅរដូវប្រាំងអាចបង្កើនសម្ពាធមកលើវត្ថុមានចំណីសម្រាប់សត្វទំពារអៀង។ ប្រការនេះអាចគ្រប់គ្រងបានតាមរយៈវិធានការអភិរក្សចំណីសត្វឲ្យបានសមស្រប។ កំណើនកំពស់ទឹកសមុទ្រនឹងធ្វើឲ្យខូចគុណភាពដីនិងទឹក ដែលនឹងមានឥទ្ធិពលមកលើសុខភាពសត្វជារួមផងដែរ។ កំណើនសីតុណ្ហភាព និងរលកកំដៅនាំឲ្យមានកំណើននៃការគំរាមកំហែងមកលើសត្វចិញ្ចឹម និងធ្វើឲ្យសត្វទាំងនេះរងគ្រោះពីកំដៅ។ ផលវិបាកនៃការបាត់បង់សត្វចិញ្ចឹមនឹងមានកម្រិតធ្ងន់ធ្ងរជារួម មកលើរបរចិញ្ចឹមជីវិតនានារបស់ឃុំនានានៅស្រុកព្រៃនប់ ដោយសារសត្វចិញ្ចឹមមិនត្រឹមតែត្រូវបានប្រើប្រាស់សម្រាប់ការបរិភោគក្នុងគ្រួសារប៉ុណ្ណោះទេ ប៉ុន្តែជាកម្លាំងអូសទាញនៅក្នុងកសិកម្មផងដែរ។ ប៉ុន្តែភវនីយភាពនៃសេណារីយ៉ូដែលនឹងអាចកើតឡើងមិនធំឡើយ ដូច្នេះវាមានហានិភ័យកម្រិតមធ្យម។

ការនេសាទ៖ សេណារីយ៉ូនេះមានហានិភ័យកម្រិតមធ្យមកាលណាឈានទៅជិតឆ្នាំ២១០០។ កំណើនសីតុណ្ហភាព (សមុទ្រ និងខ្យល់) កំណើនជាតិជូរនៃទឹកសមុទ្រ កំណើនកំពស់ទឹកសមុទ្រ និងការធ្លាក់ភ្លៀងកាន់តែខ្លាំងត្រូវបានទស្សន៍ទាយថា នឹងបង្កការបាត់បង់យ៉ាងច្រើនចំពោះព្រៃកោងកាង ស្មៅសមុទ្រ និងទីជម្រកនានាដែលផ្តល់ជាកន្លែងជ្រកកោនសម្រាប់មច្ឆជាតិក្នុងតំបន់ឆ្នេរ។ ប៉ុន្តែដោយហេតុថាការនេសាទនៅព្រៃនប់គ្រាន់តែផ្តល់ជាប្រភពប្រាក់ចំណូលបន្ថែមលើផលដំណាំដែលជារបរចំបង ដូច្នេះផលប៉ះពាល់នេះមិនទំនងជាធ្ងន់ធ្ងរឡើយ។

## ៤.២ ភាពងាយរងគ្រោះ និងសមត្ថភាពបន្សាំ

មានយន្តការទប់ទល់មួយចំនួនដែលកំពុងអនុវត្តនៅតាមតំបន់គោលដៅទាំងអស់ ដូចជាការដាំដើមឈើដើម្បីការពារទល់នឹងខ្យល់ព្យុះ និងស្រះ/អាងទឹកសម្រាប់ស្តុកទឹកទុកផឹក។ អ្វីដែលគួរកត់សំគាល់ផងដែរនោះគឺការផ្សព្វផ្សាយព័ត៌មានអំពីសារៈសំខាន់នៃការសំអាតផ្ទះ និងទីជុំវិញនៅក្រោយទឹកជំនន់ និងព័ត៌មានតាមទូរទស្សន៍ និងវិទ្យុ ដែលទាក់ទងនឹងខ្យល់ព្យុះ។ បញ្ហាទូទៅមួយនៃយន្តការទប់ទល់នៅក្នុងសហគមន៍ គឺថាពួកគេខ្វះទស្សនវិស័យសម្រាប់រយៈពេលវែង។ យុទ្ធសាស្ត្រនានាផ្តោតច្រើនពេកលើការរក្សាស្ថានភាពបច្ចុប្បន្ន

និងមិនបានសង្កត់ធ្ងន់គ្រប់គ្រាន់លើការកែលម្អរបរចិញ្ចឹមជីវិតសម្រាប់រយៈពេលវែងឡើយ។ យន្តការទប់ទល់មិនទំនងជាផ្សារភ្ជាប់ជាមួយដំណោះស្រាយ អំពីថាតើសហគមន៍អាចចូលរួមបែបណាឲ្យមាននិរន្តរភាពដើម្បីរស់នៅក្នុងប្រព័ន្ធអេកូឡូស៊ីជុំវិញពួកគេសម្រាប់រយៈពេលវែងនោះឡើយ។

សមត្ថភាពបន្សាំសំដៅលើសមត្ថភាពនៃប្រព័ន្ធណាមួយក្នុងការកែប្រែវិធីនៃដំណើរការសមត្ថភាពដើម្បីគ្រប់គ្រង(និងកាត់បន្ថយ)ការរងឥទ្ធិពលនិង/ឬភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ។ ដូច្នេះមានន័យថាប្រព័ន្ធនោះមិនត្រឹមតែទប់ទល់នឹងផលវិបាកនានានៃការប្រែប្រួលអាកាសធាតុប៉ុណ្ណោះទេ ប៉ុន្តែក៏ទាញយកផលប្រយោជន៍ពីឱកាសដែលការប្រែប្រួលអាកាសធាតុផ្ដល់ឲ្យផងដែរ។ ទោះបីសហគមន៍គោលដៅបានប្រឹងប្រែងយ៉ាងច្រើនដើម្បីប្រឆាំងនឹងឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុក៏ដោយ សមត្ថភាពបច្ចុប្បន្នដើម្បីបន្សាំនឹងការប្រែប្រួលអាកាសធាតុទៅអនាគតនៅក្នុងតំបន់ឆ្នេរនៅតែមានកម្រិតទាបនៅឡើយ។

ការយល់ដឹងជាក់លាក់អំពីការប្រែប្រួលអាកាសធាតុ ដែលពាក់ព័ន្ធនឹងកិច្ចប្រឹងប្រែងក្នុងរបរចិញ្ចឹមជីវិតនិងថាតើគួររួមបញ្ចូលបែបណាទៅក្នុងយុទ្ធសាស្ត្របន្សាំច្រើនតែមានក្នុងកម្រិតកំណត់។ ប្រការនេះអាចដោយសារតែភាពមិនប្រាកដប្រជាអំពីថាតើការប្រែប្រួលអាកាសធាតុនឹងកើតឡើងបែបណានៅថ្នាក់មូលដ្ឋាន។ ការទស្សន៍ទាយអំពីថាតើអាកាសធាតុនឹងវិវត្តបែបណា នៅពុំមានភាពជាក់លាក់នៅឡើយទេ ហើយការផ្សារភ្ជាប់ជាមួយសេណារីយ៉ូខុសៗគ្នានៃការប្រែប្រួលអាកាសធាតុគឺជាការលំបាក។ ការទស្សន៍ទាយកាន់តែច្បាស់លាស់និងនៅថ្នាក់មូលដ្ឋាននឹងអាចជួយកែលម្អ និងធ្វើឲ្យសហគមន៍កាន់តែអាចប្រកាន់យកវិធានការពាក់ព័ន្ធនានានៅក្នុងបរិបទនេះ។ ដូច្នេះជាការច្បាស់ណាស់ថាសម្រាប់រយៈពេលមធ្យម និងវែង សមត្ថភាពបន្សាំរបស់សហគមន៍គោលនៅពុំទាន់គ្រប់គ្រាន់នៅឡើយទេ។ ជំនួយពីខាងក្រៅពីអាជ្ញាធរមូលដ្ឋានក៏ដូចជាអាជ្ញាធរថ្នាក់ជាតិ គឺជាតម្រូវការចាំបាច់ ដើម្បីអាចឲ្យសហគមន៍ទប់ទល់បានកាន់តែប្រសើរទៅនឹងការប្រែប្រួលអាកាសធាតុដែលបានទស្សន៍ទាយ។

## ៤.៣ សកម្មភាពអនុវត្តបង្ហាញដែលបានលើកស្នើ ទាក់ទងនឹងការបន្សាំនៃរបរចិញ្ចឹមជីវិត

តាមតែអាចធ្វើបាន រាល់ការប្រែប្រួលដែលអាចកើតឡើងត្រូវតែចាត់បញ្ចូលនៅក្នុងលក្ខណៈវិនិច្ឆ័យ "មិនស្ដាយក្រោយ" ដូចមានចែងក្នុងឯកសារសមាសភាគ CARP ពោលគឺការប្រែប្រួលទាំងនេះនឹងមានប្រសិទ្ធភាព និងផ្ដល់ផលសូម្បីតែការប្រែប្រួលអាកាសធាតុ ដែលបានទស្សន៍ទាយមិនកើតឡើងពេញលេញក៏ដោយ។ នេះក៏ដោយសារការទស្សន៍ទាយ អំពីការប្រែប្រួលអាកាសធាតុមានការពាក់ព័ន្ធជាមួយកម្រិតនៃភាព មិនប្រាកដប្រជា។

ការប្រែប្រួលដែលអាចកើតឡើងមានភាពជាក់លាក់សម្រាប់សហគមន៍គោលដៅ ពោលគឺឃុំចំនួនប្រាំមួយៈទឹកថ្លា ទឹកល្អក់ សាមគ្គី ទួលទទឹង អូរឧកញ៉ាហេង និងព្រៃនប់ នៅក្នុងស្រុកព្រៃនប់ ខេត្តព្រះសីហនុ និងឃុំចំនួនពីរគឺពាមក្រសោប និងទួលគគីរនៃស្រុកមណ្ឌលសីមាខេត្តកោះកុង។ ទឹកប្រាក់ចំនួន ៧០០.០០០ ដុល្លាអាមេរិកសម្រាប់ការបន្សាំជារួម ត្រូវបានគ្រោងសម្រាប់សកម្មភាពបែបនេះនៅក្រោម CARP ។ ហេតុផលខាងសេដ្ឋកិច្ចនៃសកម្មភាពទាំងនេះត្រូវបានលើកឡើង ដែលទាក់ទងនឹងការវិភាគថ្លៃចំណាយ និងផលចំណេញដូចមានអធិប្បាយនៅក្នុងជំពូកបន្ទាប់។

សកម្មភាពអនុវត្តបង្ហាញដែលបានលើកស្នើមានសង្ខេបខាងក្រោម (ចំពោះការពិភាក្សាពិស្ដារអំពីសកម្មភាពនានាសូមយោងទៅរបាយការណ៍វាយតម្លៃទាំងមូលខែតុលាឆ្នាំ២០១២)៖

- កម្មវិធីបណ្តុះបណ្តាលកសិកម្មចម្រុះសម្រាប់ (ក) បុគ្គលិកផ្សព្វផ្សាយកសិកម្ម/ជលផលនិង (ខ) គ្រួសារនានាអំពីយុទ្ធសាស្ត្របន្សុំនឹងការប្រែប្រួលអាកាសធាតុនៅកម្រិតខុសៗគ្នា និងកសិកម្មចម្រុះ (ការរួមបញ្ចូលដំណាំការចិញ្ចឹមសត្វត្រីទឹក) នៅសហគមន៍គោលដៅចំនួន៧។ សកម្មភាពទាំងនេះអាចអនុវត្តបន្តពីការវិភាគប្រព័ន្ធក្សេត្របរិស្ថាន (វិធីសាស្ត្រវាយតម្លៃជនបទដោយមានការចូលរួមដែល MAFF ប្រើប្រាស់) ប្រសិនបើចាំបាច់។
- គម្រោងសហគមន៍ព្រៃឈើក្រោមកិច្ចសហការជាមួយរដ្ឋបាលព្រៃឈើ ក្នុងករណីដែលមានលទ្ធភាពអនុវត្តនៅទទួលគគីរ។ ប្រការនេះ អាចរាប់បញ្ចូលសិទ្ធិលែងសត្វឲ្យស៊ីស្មៅ សម្រាប់សត្វចិញ្ចឹមនៅក្នុងទីព្រៃក៏ដូចជាក្នុងថ្នាលបណ្តុះកូនឈើផងដែរ។ ទំនាក់ទំនងនៃសហគមន៍ព្រៃឈើទៅនឹងការបន្សុំនៃការប្រែប្រួលអាកាសធាតុគឺថា ការដាំដើមឈើអាចជាវិធានការមួយសម្រាប់ការពារផ្ទះ ការពារទំនប់ មិនឲ្យហូរច្រោះ ផ្តល់អុស និងផ្លែឈើក៏ដូចជាប្រភពប្រាក់ចំណូលផងដែរ ក្នុងករណីមានដីសមស្រប (ដូចនៅទួលគគីរ)។
- គម្រោងសហគមន៍នេសាទនៅពាមក្រសោបក្រោមកិច្ចសហការជាមួយរដ្ឋបាលជលផល ជាពិសេសទាក់ទងនឹងការពង្រឹងវិធានការខាងផ្លូវច្បាប់និងការពង្រឹងការអនុវត្ត។ ការពាក់ព័ន្ធនៃសហគមន៍នេសាទជាមួយការប្រែប្រួលអាកាសធាតុគឺថាគេទំនងជាត្រូវការឲ្យមានការអភិវឌ្ឍវិស័យនេសាទរួមជាមួយវិធានការកំហិតលើការនេសាទដើម្បីកែតម្រូវរបរចិញ្ចឹមជីវិតរបស់សហគមន៍ដែលជាអ្នកនេសាទ។
- ការពង្រឹងការងារអនុវត្តក្នុងការគ្រប់គ្រង និងថែទាំទំនប់ប្រព័ន្ធដោះទឹក និងប្រព័ន្ធស្រោចស្រពក្រោមកិច្ចសហការជាមួយក្រសួងធនធានទឹក និងឧតុនិយមសម្រាប់ព្រៃនប់ និងទួលគគីរ។[3]
- ការលើកកំពស់និងការបង្កើនវត្តមានពូជដំណាំដែលឆាប់ឲ្យផលជាពិសេសស្រូវស្រាលនៅរដូវវស្សាអាចនាំឲ្យមានការប្រមូលផលមុនពេលចាប់ផ្តើមនៃជំនន់ធ្ងន់ធ្ងរ និងការឡើងខ្ពស់នៃទឹកសមុទ្រនៅក្នុងឃុំទាំងប្រាំ។ ភាពខុសគ្នាបែបនេះត្រូវតែយកមកសាកល្បង (ដោយមិនមែនកសិករជាអ្នកបង់ថ្លៃឡើយ) នៅក្នុងទីតាំងជាក់លាក់ដើម្បីឲ្យដឹងថាតើវាមានប្រសិទ្ធភាពដែរឬទេ។
- ការជម្រុញឲ្យមានការចិញ្ចឹមសត្វកាន់តែច្រើននៅក្នុងឃុំទាំងប្រាំដោយប្រើប្រាស់ប្រព័ន្ធទុនបង្វិលសម្រាប់កែលម្អពូជសត្វត្រូវបានសាកល្បងដោយជោគជ័យនៅកម្ពុជាឡាវ និងកន្លែងផ្សេងទៀត។ នេះជាការឆ្លើយតបនឹងកំណើនបញ្ហាទឹកជំនន់ដោយសារគេអាចជន្លៀសសត្វចិញ្ចឹមបាន។
- អាចជម្រុញការអភិរក្សទឹកនៅក្នុងស្រែ និងវិធីគ្រងទឹកទុកក្នុងស្រែជាសកម្មភាពអនុវត្តបង្ហាញជាច់ដោយឡែកដែលត្រូវធ្វើការសម្រេច។

---

[3]ការបង្កើនកំពស់និងពង្រីកប្រព័ន្ធទំនប់ការពារដែលមានស្រាប់ក៏ដូចជាការគិតគូរអំពីលក្ខខណ្ឌដោះទឹកនិងការបូមទឹកជាពិសេសសម្រាប់តំបន់ព្រៃនប់ប៉ុន្តែក៏សម្រាប់ទំនប់ក្នុងខេត្តកោះកុងផងដែរត្រូវអ្នកពាក់ព័ន្ធទាំងអស់ដែលបានសម្ភាសចាត់ទុកថាជាយន្តការបន្សុំចំបង។លើកលែងតែអាចរកឃើញដំណោះស្រាយដែលមានប្រសិទ្ធភាពនៅក្នុងបរិបទនេះបើពុំនោះទេគេលំបាកក្នុងការគិតថាសកម្មភាពអនុវត្តបង្ហាញដែលបានរកឃើញនឹងមាននិរន្តរភាពប្រសិនបើការប្រែប្រួលអាកាសធាតុដូចដែលបានទស្សន៍ទាយពិតជាកើតឡើងមែន។ក្រុមប្រឹក្សាឃុំទាំងអស់ដែលជាគោលដៅបានឯកភាពជាមួយកង្វល់នេះហើយមុខសញ្ញាជាអ្នកទទួលផលពីសកម្មភាពអនុវត្តបង្ហាញនេះអាចមិនសូវចាប់អារម្មណ៍ប្រសិនបើការគិតគូរអំពីប្រព័ន្ធទំនប់ទាំងនេះមិនត្រូវបានចាត់ជាអាទិភាពសម្រាប់ការដោះស្រាយ។ ដូច្នេះកង្វល់ជាទូទៅនេះត្រូវបានមើលឃើញថាកាន់តែធ្ងន់ធ្ងរជាងអ្វីដែលបានទទួលស្គាល់មកទល់ពេលនេះ។

រយៈពេលខ្លីនៃគម្រោងនេះ (CARP ចាប់នៅត្រឹមានសទី១ឆ្នាំ២០១៤) បង្កជាការប្រឈមមួយដោយសារអោចអនុញ្ញាតឲ្យមានតែមួយរដូវដាំដំណាំ (ឆ្នាំ២០១៣) សម្រាប់ការអនុវត្ត។ រយៈពេលអនុវត្តខ្លីបែបនេះមិនធម្មតាឡើយសម្រាប់គម្រោងអភិវឌ្ឍន៍ដែលតាមធម្មតាត្រូវការពី៣ទៅ៥ឆ្នាំដើម្បីអនុវត្ត។

ទោះជាយ៉ាងណាក៏ដោយការអនុវត្តសកម្មភាពបង្ហាញដែលលើកស្នើឡើងនេះនឹងនៅតែអាចចាប់ផ្តើមតាមការគ្រោងទុកនៅក្នុងតំបន់គោលដៅ។ ប៉ុន្តែជាការល្អប្រសិនបើមានពេលបន្ថែមទៀតសម្រាប់អនុវត្តបន្តកែលម្អលទ្ធផលអនុវត្តមេរៀនដែលទទួលបាន និងប្រមូលយកលទ្ធផលក៏ដូចជាដើម្បីពង្រីកសមត្ថភាពដែលបានបង្កើតឡើងទៅតំបន់ដទៃផងដែរ។

# ៥. ការវិភាគថ្លៃចំណាយ និងផលចំណេញ

ជំពូកនេះគឺជាសេចក្តីសង្ខេបអំពីការវិភាគទិដ្ឋភាពសេដ្ឋកិច្ច និងសង្គមនៃថ្លៃចំណាយ និងផលចំណេញសម្រាប់ជម្រើសនានានៃការអនុវត្តកសិកម្មដែលកែប្រែខុសពីមុនដែលមិនងាយរងគ្រោះដោយសារផលប៉ះពាល់នៃអថេរអាកាសធាតុ និងការប្រែប្រួលអាកាសធាតុ។

ការវិភាគនេះបានធ្វើឡើងនៅឆ្នាំ ២០១២ ដើម្បីប៉ាន់ប្រមាណអំពីសក្តានុពលសេដ្ឋកិច្ច-សង្គមនៃសកម្មភាពអនុវត្តបង្ហាញ ដែលបានលើកស្នើក្នុងរបាយការណ៍ស្តីពី "ការវាយតម្លៃភាពងាយរងគ្រោះ និងហានិភ័យរបស់សហគមន៍ពីការប្រែប្រួលអាកាសធាតុនៅក្នុងតំបន់ឆ្នេរកម្ពុជា" ខែតុលា ឆ្នាំ២០១២ ដែលមានសង្ខេបនៅក្នុងជំពូកមុននេះ។ ការវិភាគនេះបានធ្វើឡើងជាធាតុចេញ ២.៥ នៃ CARP។

ការវិភាគពេញលេញ ពោលគឺ "ការវិភាគថ្លៃចំណាយ និងផលចំណេញពីការធ្វើកសិកម្មតាមវិធីកែប្រែសម្រាប់ការប្រែប្រួលអាកាសធាតុនៅតំបន់ឆ្នេរកម្ពុជា ខែវិច្ឆិកា ឆ្នាំ ២០១២ អាចចម្លងចេញពីវេបសាយ CARP (www.czmcam.org)។

## ៥.១ ទិដ្ឋភាពរួមនៃសកម្មភាពអនុវត្តបង្ហាញដែលបានលើកស្នើសម្រាប់ការវិភាគសេដ្ឋកិច្ច

សកម្មភាពដែលបានជ្រើសយកចំនួនប្រាំដូចខាងក្រោមនេះត្រូវបានលើកយកមកវិភាគសេដ្ឋកិច្ច៖

១. កម្មវិធីបណ្តុះបណ្តាលអំពីកសិកម្មចម្រុះដល់ (ក) បុគ្គលិកផ្សព្វផ្សាយកសិកម្ម និង (ខ) គ្រួសារ/ខ្នងផ្ទះ អំពីយុទ្ធសាស្ត្របន្សាំនឹងការប្រែប្រួលអាកាសធាតុ និងផលិតកម្មចម្រុះ (ការរួមបញ្ចូលដំណាំ ការចិញ្ចឹមសត្វ ត្រី ទឹក) នៅក្នុងឃុំគោលដៅ ៧-៨។ មុននេះអាចមានការវិភាគក្សេត្របរិស្ថាន (ដែលជាវិធីសាស្ត្រមួយ ប្រើប្រាស់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) ជាផ្នែករួមមួយនៃកម្មវិធីនេះ។

២. គម្រោងសហគមន៍នេសាទនៅពាមក្រសោប ក្រោមកិច្ចសហការជាមួយរដ្ឋបាលជលផល ជាពិសេសដើម្បីពង្រឹងវិធានការច្បាប់ និងពង្រឹងការអនុវត្ត។ ទំនាក់ទំនងនៃសហគមន៍នេសាទជាមួយការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុបង្ហាញថា គេទំនងជាត្រូវការនូវការអភិវឌ្ឍជាទូទៅខាងការនេសាទ និងវិធានការច្បាប់ ដើម្បីកែសម្រួលមុខរបររបស់សហគមន៍អ្នកនេសាទ។

៣. ការលើកកំពស់ និងបង្កើនវត្តមានពូជដំណាំដែលឆាប់ផ្តល់ផល ជាពិសេសស្រូវស្រាលរដូវវស្សា អាចសម្រួលដល់ការប្រមូលផលមុនពេលទឹកជំនន់ធំមកដល់ និងការឡើងកំពស់ទឹកសមុទ្រនៅក្នុងឃុំ

គោលដៅ។ គេត្រូវសាកល្បងពូជដំណាំបែបនេះ(ដោយកសិករមិនមែនជាអ្នកបង់ខាត)នៅក្នុងទីតាំងជាក់លាក់ដែលទំនងជាមានប្រសិទ្ធភាព។

៤. លើកកំពស់ការចិញ្ចឹមសត្វនៅក្នុងឃុំចំនួន ៥ ដោយប្រើប្រាស់ប្រព័ន្ធទុនបង្វិលសម្រាប់កែលម្អពូជជាបន្តបន្ទាប់ ដែលបានសាកល្បងដោយជោគជ័យនៅកម្ពុជា ឡាវ និងកន្លែងដទៃ។ នេះជាវិធានការឆ្លើយតប ទៅនឹងបញ្ហាទឹកជំនន់ ដោយសារគេអាចចល័តសត្វចិញ្ចឹមបាន។

៥. លើកកំពស់ការអភិរក្សទឹកនៅក្នុងស្រែ ការត្រងទឹកភ្លៀងទុកក្នុងកសិដ្ឋាន។

របាយការណ៍ "វាយតម្លៃភាពងាយរងគ្រោះ និងហានិភ័យនៃរបរចិញ្ចឹមជីវិតរបស់សហគមន៍ ខែតុលា ឆ្នាំ២០១២ បានលើកស្នើសកម្មភាពអនុវត្តបង្ហាញពីរបន្ថែមទៀតដូចខាងក្រោម។ ទោះជាយ៉ាងណាក៏ដោយ ការវិភាគសេដ្ឋកិច្ចលើសកម្មភាពទាំងនេះមិនធ្វើបានឡើយ ដោយសារតែខ្វះទិន្នន័យ។

i. គម្រោងសហគមន៍ព្រៃឈើក្រោមកិច្ចសហការជាមួយរដ្ឋបាលព្រៃឈើ ដែលមានលទ្ធភាពអាចអនុវត្តបាននៅទួលគគីរ។ គម្រោងនេះអាចរាប់បញ្ចូល សិទ្ធិក្នុងការលែងសត្វឲ្យស៊ីស្មៅ សម្រាប់សត្វចិញ្ចឹមនៅក្នុងដែនដីព្រៃ ក៏ដូចជា ថ្នាលបណ្ដុះកូនឈើផងដែរ។ ទំនាក់ទំនងរវាងសហគមន៍ព្រៃឈើជាមួយការបន្សាំនឹងការប្រែប្រួលអាកាសធាតុបង្ហាញថា ការដាំដើមឈើអាចជាវិធីមួយសម្រាប់ការពារដំណាំ និងផ្ទះ ការពារស្ថិរភាពទំនប់ ផ្តល់អុស និងផ្លែឈើ ក៏ដូចជា ការផ្តល់ប្រាក់ចំណូល នៅក្នុងករណីដែលមានដីសមស្រប (ដូចជានៅទួលគគីរ)។

ii. ពង្រឹងការថែទាំទំនប់សហគមន៍ ការគ្រប់គ្រងប្រព័ន្ធដោះទឹក និងប្រព័ន្ធស្រោចស្រពក្រោមកិច្ចសហការជាមួយក្រសួងធនធានទឹក និងឧតុនិយម - សម្រាប់ព្រៃនប់ និងទួលគគីរ។

ជាទូទៅ សកម្មភាពអនុវត្តបង្ហាញដែលបានលើកស្នើសម្រាប់ CARP ទាំងនេះ អាចអធិប្បាយថា៖

- ផ្សំដោយវិធានការភាគច្រើនសម្រាប់ទប់ទល់នឹងការប្រែប្រួលអាកាសធាតុ ដែលស្នើឡើងដោយឃុំគោលដៅ និងមន្ត្រីពាក់ព័ន្ធ។ ទោះជាយ៉ាងណាក៏ដោយ ការចាត់ចែងអនុវត្តដែលបានលើកស្នើនៅត្រូវពិភាក្សាបន្ថែមជាមួយភាគីទាំងនេះ និងអ្នកពាក់ព័ន្ធដទៃទៀតផងដែរ។ (ប៉ុន្តែមិនបានរាប់បញ្ចូលការជួសជុលប្រព័ន្ធទំនប់ឡើយ ដែលបង្ហាញច្បាស់ថាជាជាអាទិភាពទីមួយសម្រាប់ឃុំគោលដៅ។ កង្វល់នេះត្រូវបានរក្សាទុកសម្រាប់ផ្នែកដទៃនៃ CARP ទៅតាមការឯកភាពគ្នា)។
- អាទិភាពកំណត់ជាមុនមួយ (នៅមុនការគណនា) ត្រូវបានរំពឹងថាអាចផ្តល់ផលចំណេញយ៉ាងច្រើនខាងសង្គម បរិស្ថាន សេដ្ឋកិច្ច និងរបរចិញ្ចឹមជីវិតជាទូទៅ ទន្ទឹមនឹងអាចបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុដែលបានទស្សន៍ទាយផងដែរ។
- ជាទូទៅ សកម្មភាពអនុវត្តបង្ហាញបង្កជាហានិភ័យតិចតួចសម្រាប់ការអនុវត្ត ជាពិសេសសម្រាប់គ្រួសារដែលពាក់ព័ន្ធ - ដោយសារតែគំរូនៃការអនុវត្តដែលបានលើកស្នើត្រូវបានសាកល្បងដោយជោគជ័យនៅក្នុងកាលៈទេសៈប្រហែលគ្នានេះ
- ត្រូវបានរំពឹងថាមានលក្ខខណ្ឌធនធានប្រាកដប្រជា
- ត្រូវបានរំពឹងថាអាចអនុវត្តបានពីសំណាក់ស្ថាប័ន និងដៃគូពាក់ព័ន្ធ និងដែលបានកត់សំគាល់ ហើយក្នុងករណីពាក់ព័ន្ធ ក៏មានការលើកស្នើវិធានការកសាងសមត្ថភាពផងដែរ។

ចំពោះវិធីសាស្ត្រទម្រង់រួម និងការប៉ាន់ប្រមាណអំពីទិដ្ឋភាពសេដ្ឋកិច្ចនៃថ្លៃចំណាយ សូមយោងទៅរបាយការណ៍វិភាគពេញលេញនៃសំណើសកម្មភាពអនុវត្តបង្ហាញ។

## ៥.២ សេចក្តីសង្ខេបថ្លៃចំណាយ និងផលចំណេញ និងការពិចារណាដទៃទៀត

ជារួមផលចំណេញខាងសេដ្ឋកិច្ច និងការចំណាយនិងផលចំណេញខាងសង្គម ដែលបង្ហាញជូនដូចខាងក្រោមនេះ ចង្អុលបង្ហាញពីបុរេសនាល្អសម្រាប់ការសម្រេចបាននូវកំណែលម្អជាច្រើន នៃរបរចិញ្ចឹមជីវិតរបស់សហគមន៍គោលដៅ (ចំពោះសេចក្តីពិស្តារសូមអានរបាយការណ៍វិភាគទាំងមូលខែវិច្ឆិកាឆ្នាំ២០១២)។

### ផលចំណេញខាងសេដ្ឋកិច្ច

សេចក្តីសង្ខេបការប៉ាន់ស្មានចំណាយសម្រាប់អនុវត្តសកម្មភាពក្នុង CARP

| សកម្មភាព | សេចក្តីពិពណ៌នា | ចំនួន ($) |
|---|---|---|
| **សកម្មភាព១** | កម្មវិធីបណ្តុះបណ្តាលកសិករអំពីការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងផលិតកម្មចម្រុះក្នុងឃុំចំនួន ៧ | ១៩៨.០០០ |
| **សកម្មភាព ២** | គម្រោងសហគមន៍នេសាទនៅពាមក្រសោប ខេត្តកោះកុង | ៤២.០០០ |
| **សកម្មភាព៣** | ការសាកល្បងពូជដំណាំតាមកសិដ្ឋាន ការអនុវត្តបង្ហាញ និងការបណ្តុះបណ្តាលអំពីការជ្រើសរើសពូជក្នុងឃុំចំនួន ៧ | ៣២.០០០ |
| **សកម្មភាព៤** | ប្រព័ន្ធចិញ្ចឹមសត្វដោយតាមរយៈទុនបង្វិលក្នុងឃុំចំនួន ៧ | ២២៥.០០០ |
| **សកម្មភាព៥** | សកម្មភាពអនុវត្តបង្ហាញអំពីការអភិរក្សទឹក ការត្រងទឹកទុក និងប្រព័ន្ធស្រោចស្រពខ្នាតតូច | ៥០.០០០ |
| **សរុប** | | ៥៤៧.០០០ |

សកម្មភាពអនុវត្តបង្ហាញដែលបានកត់សំគាល់ ១-៥ សុទ្ធសឹងផ្តល់ផលចំណេញខាងសេដ្ឋកិច្ច សម្រាប់ CARP និងគ្រួសារដែលចូលរួម។ ការគណនាបានបង្ហាញពីលក្ខខណ្ឌល្អ និងទំនងជារក្សាបានអត្រាខ្ពស់នៃផលចំណេញ សូម្បីតែការសន្មតិអំពីកម្រិតប្រាក់ចំណូល និងអត្រានៃការទទួលយកទាបជាងច្រើនធៀបនឹងការរំពឹងទុកក៏ដោយ។

បើគិតពីលក្ខខណ្ឌសេដ្ឋកិច្ច សកម្មភាពអនុវត្តបង្ហាញដែលបានវិភាគ បានប្រៀបធៀបដូតទៅ៖

<u>ការប្រៀបធៀបផលចំណេញខាងសេដ្ឋកិច្ច</u>

| សកម្មភាពបង្ហាញ | ផ្តល់ផលផ្ទាល់ដល់គ្រួសារនានា | អត្រាចំណូលផ្ទៃក្នុង | តម្លៃបច្ចុប្បន្នសុទ្ធនៃការវិនិយោគ | ផលចំណេញក្នុងគ្រួសារនីមួយៗ |
|---|---|---|---|---|
| ១និង៣៖ FFS | ១២០០ | ១៩៣ % | ១,៧ លានដុល្លា | ១៤១៧ដុល្លា |
| ២៖ ពាមក្រសោប | ២៧៧ | ៦០% | ០,៥ លានដុល្លា | ១៨០៦ដុល្លា |

| | | | | |
|---|---|---|---|---|
| ៤. ការចិញ្ចឹមសត្វ | ៦០០ | ៣១% | 0,៣ លានដុល្លា | ៥០០ដុល្លា |
| ៥. ការត្រងទឹកទុក | ២០០ | ៥៦% | 0,១ លានដុល្លា | ៥០០ដុល្លា |

ជាការច្បាស់ណាស់ថា សកម្មភាពអនុវត្តបង្ហាញទាំង5នៅក្នុងការវិភាគសេដ្ឋកិច្ចនេះ ត្រូវបានចាត់ទុកថាជាបេក្ខភាពពិតប្រាកដសម្រាប់ការអនុវត្ត ដោយសារវាសុទ្ធតែជាការវិនិយោគដែលផ្តល់ផលចំណេញ។ នៅក្នុងករណីដែលមានមូលនិធិក្នុងកម្រិតកំណត់ សកម្មភាពអនុវត្តបង្ហាញរួមគ្នា ១ និង៣ គួរតែបានលើកយកមកអនុវត្ត បន្ទាប់មកសកម្មភាព ២ ពោលគឺ គម្រោងសហគមន៍នេសាទនៅពាមក្រសោបដែលជាអាទិភាពទី ២។ ប្រសិនបើមានធនធានគ្រប់គ្រាន់សម្រាប់ការវិនិយោគបន្ថែម គេគួរអនុវត្តសកម្មភាពទី ៤ ផងដែរ។

## ថ្លៃចំណាយ និងផលចំណេញខាងសង្គម

សកម្មភាពដែលលើកស្នើសម្រាប់ការអនុវត្តបង្ហាញសុទ្ធតែស្របគ្នាជាមួយអាទិភាព ដែលតំណាងសហគមន៍បានលើកឡើង និងពង្រឹងជាបន្ថែមនូវយុទ្ធសាស្ត្រទប់ទល់ដែលមានស្រាប់។ ដូច្នេះ ថ្លៃចំណាយខាងសង្គមមានកម្រិតកំណត់ ប៉ុន្តែផលចំណេញសង្គមនៃសកម្មភាពដែលលើកស្នើមានច្រើន ដោយសារតែសំណើសកម្មភាពទាំងនេះគាំទ្រដល់អាទិភាពដែលសហគមន៍បានលើកឡើង។ ទោះជាយ៉ាងណាក៏ដោយ គេអាចកត់សំគាល់បានថា សំណើពង្រីកការចិញ្ចឹមសត្វ (ជាពិសេស សត្វតូចៗ) និងការដាំបន្លែ អាចបន្ថែមសម្ពាធមកលើកម្លាំងពលកម្មរបស់ស្ត្រី ដោយសារតែសកម្មភាពទាំងនេះ តាមប្រពៃណី ត្រូវបានចាត់ទុកថាជាការទទួលខុសត្រូវរបស់ស្ត្រី។ នេះជាកិច្ចការមួយដែលត្រូវលើកយកមកពិចារណាផងដែរនៅក្នុងពេលអនុវត្ត។

ក្រៅពីនេះ មានផលចំណេញបន្ថែមដែលពិបាកគណនា។ ជាសង្ខេប ផលចំណេញទាំងនោះរួមមាន៖

សម្រាប់សកម្មភាព ១ នៃការអនុវត្តបង្ហាញនេះគឺ៖

មានផលចំណេញបន្ថែមផ្សេងទៀតដែលពិបាកគណនា។ ជាសង្ខេប ផលចំណេញទាំងនោះរួមមាន៖

សម្រាប់សកម្មភាព ១ នៃការអនុវត្តបង្ហាញគឺ៖

- ការថយចុះនៃសម្ពាធមកលើបរិស្ថាន ក៏ដូចជា សុខភាពសត្វ និងមនុស្ស តាមរយៈការជម្រុញឲ្យប្រើប្រាស់បច្ចេកវិទ្យានៃវិធានការចម្រុះការពារដំណាំ (IPM) ដែលបានបង្ហាញថា អាចកាត់បន្ថយការប្រើប្រាស់ថ្នាំកំចាត់សត្វចង្រៃពី ៧០-៩០% ឧទា. នៅបង់ក្លាដែស (ការសិក្សាឥទ្ធិពលដោយដានីដា ឆ្នាំ២០០៣)។
- ការជម្រុញការផលិតបន្លែ ដែលទំនងជាជួយបង្កើនអាហារូបត្ថម្ភ ក៏ដូចជាប្រាក់ចំណូល សម្រាប់គ្រួសារដែលចូលរួម។

សម្រាប់សកម្មភាព៣ នៃការអនុវត្តបង្ហាញនេះគឺ៖

- កំណែលម្អការគ្រប់គ្រងបរិស្ថាន តាមរយៈវិធានការដែលមាននិរន្តរភាពសម្រាប់ការផលិតចំណីស្ងួត ដែលមានគោលដៅបញ្ចៀសការលែងសត្វឲ្យស៊ីស្មៅច្រើនហួសកម្រិត។
- កំណែលម្អអាហារូបត្ថម្ភរបស់គ្រួសារដែលចូលរួម តាមរយៈការទទួលបានផលិតផលពីសត្វចិញ្ចឹម។

## សមត្ថភាពបន្ស៊ាំ

សមត្ថភាពរបស់សហគមន៍ដើម្បីបន្ស៊ាំនឹងការប្រែប្រួលអាកាសធាតុត្រូវបានគិតគូររួចមកហើយនៅក្នុង "របាយការណ៍វាយតម្លៃភាពងាយរងគ្រោះ និងហានិភ័យរបស់សហគមន៍ ពីការប្រែប្រួលអាកាសធាតុ នៅក្នុងតំបន់ឆ្នេរកម្ពុជាខែកក្កដា ឆ្នាំ ២០១២ (សង្ខេបក្នុងជំពូក ៤)។ សកម្មភាពអនុវត្តបង្ហាញដែលបានលើកស្នើនេះត្រូវបានរៀបចំឡើងដោយឡែក ដើម្បីឲ្យស្របគ្នាជាមួយសមត្ថភាពបន្ស៊ាំរបស់សហគមន៍។

## សមត្ថភាពស្ថាប័ន

សកម្មភាពសាកល្បងដែលលើកស្នើឡើងទាំងអស់អាចអនុវត្តទៅបាន អាស្រ័យលើកិច្ចសហការរលូនរវាង CARP, ក្រសួងបរិស្ថាន (MoE) និងស្ថាប័នដទៃទៀតនៃរដ្ឋាភិបាល ជាពិសេស ស្ថាប័ននានាចំណុះ MAFF; ដែលរួមទាំង មន្ទីរកសិកម្ម ខណ្ឌរដ្ឋបាលជលផល និងមន្ទីរធនធានទឹក និងឧតុនិយមផងដែរ។ កិច្ចសហប្រតិបត្តិការអន្តរក្រសួងបែបនេះនៅកម្ពុជា មិនសុទ្ធតែមានដំណើរការបានរលូនដូចដែលចង់បានឡើយ។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងន័យនេះដើម្បីទទួលជោគជ័យ កិច្ចសហប្រតិបត្តិការចាំបាច់ត្រូវធ្វើឡើងឲ្យទាន់ពេលវេលា និងសមស្របផងដែរ។

## រយៈពេលខ្លីសម្រាប់ការអនុវត្ត

មានការគូសបញ្ជាក់រួចមកហើយថា សមាសភាគ CARP នឹងត្រូវបញ្ចប់នៅចុងត្រីមាសទី១ ឆ្នាំ២០១៤ ដូច្នេះអនុញ្ញាតឲ្យមានពេលត្រឹមតែមួយរដូវដាំដំណាំ (រដូវវស្សាឆ្នាំ២០១៣) សម្រាប់ការអនុវត្តសកម្មភាពបង្ហាញទាំងនេះ។ នេះមិនមែនជាស្ថានភាពល្អឡើយ ដោយសារសកម្មភាពសាកល្បងទាំងអស់អាចបានផលល្អ ក្នុងករណីដែលសមាសភាគនេះនៅមានវត្តមានជាសកម្មភាពបន្ត និងពង្រឹងលទ្ធផលដែលបានទទួលកន្លងមក។

ក្នុងចំណោមសកម្មភាពដែលលើកស្នើទាំង៥ដែលបានវិភាគសេដ្ឋកិច្ច សកម្មភាព ១, ៣ និង ៥ ត្រូវបានចាត់ទុកថា អាចប្រែប្រួលតិចតួចបំផុត អាស្រ័យដោយការគាំទ្ររយៈពេលខ្លី ដោយសារតែយន្តការចំបងៗ (សាលាស្រែកសិករ) ប្រតិបត្តិការខ្លាំងក្លាតែក្នុងមួយរដូវប៉ុណ្ណោះ សម្រាប់ទីកន្លែងនីមួយៗ។ ទាំងសកម្មភាព ២ និង ៤ ពឹងផ្អែកខ្លាំងជាងលើសកម្មភាពបន្ត និងសកម្មភាពពង្រឹងបន្ថែមនៅក្រោយការអនុវត្តនៅឆ្នាំដំបូង។ ឥទ្ធិពលមកលើប្រាក់ចំណូលនៅពាមក្រសោប អាចរំពឹងថាទទួលបានពេញលេញនៅក្រោយរយៈពេលប្រាំឆ្នាំប៉ុណ្ណោះ ចំណែកការចិញ្ចឹមសត្វដោយប្រើប្រាស់ប្រព័ន្ធទុនបង្វិល ត្រូវរំពឹងថាត្រូវបន្ត ដើម្បីទទួលសមាជិកចូលរួមថ្មីថែមទៀត រហូតដល់ ១០ឆ្នាំ។ ដូច្នេះ ទាំងសកម្មភាព ២ និង ៤ សុទ្ធតែមានហានិភ័យខ្ពស់ដោយសារត្រូវការឲ្យមានសកម្មភាពបន្ត និងការពង្រឹងបន្ថែមទាំងនេះ។

ថ្លៃចំណាយប៉ាន់ស្មានសម្រាប់សកម្មភាពភាគច្រើន មានរួមបញ្ចូលការគិតគូរអំពីសកម្មភាពបន្តទាំងនេះ និងលក្ខខណ្ឌនៃការពង្រឹងបន្ថែម ដោយកំណត់ទុកដោយឡែកមូលនិធិខ្លះៗសម្រាប់ឃុំនីមួយៗ។ ចំពោះព័ត៌មានពិស្តារអំពីផែនការអនុវត្តសម្រាប់សំណើសកម្មភាពអនុវត្ត សូមយោងទៅរបាយការណ៍វិភាគ ខែវិច្ឆិកា ឆ្នាំ២០១២។

# ៦. សមត្ថភាពអនុវត្តសម្រាប់សកម្មភាពបង្ហាញ

ជំពូកនេះសង្ខេបអំពីការសិក្សាមួយដែលបានធ្វើឡើងនៅខែឧសភា-សីហា ឆ្នាំ២០១២ ដើម្បីប៉ាន់ប្រមាណសមត្ថភាពស្ថាប័ននានានៃរដ្ឋាភិបាលដើម្បីអនុវត្តសកម្មភាពបង្ហាញនៅក្រោមសមាសភាគ CARP។

ការសិក្សានេះទាក់ទងនឹងលទ្ធផល២នៃ CARP: "ភាពធន់នៃសហគមន៍តំបន់ឆ្នេរ និងទ្រនាប់នៃប្រព័ន្ធអេកូឡូស៊ីតំបន់ឆ្នេរទល់នឹងការប្រែប្រួលអាកាសធាតុត្រូវបានបង្កើន និងរបរចិញ្ចឹមជីវិតត្រូវបានកែលម្អ"។ ការសិក្សានេះទាក់ទងជាពិសេសជាមួយធាតុចេញ២.១: "ការវាយតម្លៃសមត្ថភាពអនុវត្តនៃសកម្មភាពបង្ហាញ"។ ការងារនេះបានផ្អែកលើការពិគ្រោះយោបល់ជាមួយអាជ្ញាធរនៅថ្នាក់ក្រោមជាតិនៅខេត្តកោះកុង និងព្រះសីហនុ សហគមន៍កសិករប្រើប្រាស់ទឹកព្រៃនប់ ក៏ដូចជាការពិគ្រោះយោបល់នៅភ្នំពេញជាមួយស្ថាប័នរដ្ឋបាល និងអង្គការនានានៅថ្នាក់ជាតិផងដែរ។

ការសិក្សាពេញលេញ– "សមត្ថភាពអនុវត្តសម្រាប់សកម្មភាពបង្ហាញ" ខែតុលា ឆ្នាំ២០១២– អាចចម្លងចេញពីវេបសាយរបស់ CARP (www.czmcam.org)។

## ៦.១ ការប្រឈមខាងអភិបាលកិច្ចដែលទាក់ទងនឹងអាកាសធាតុ

ការជំពាក់ជំពិនថ្មីៗដែលបង្កដោយការប្រែប្រួលអាកាសធាតុមានអន្តរកម្មជាមួយការប្រឈមដែលមានស្រាប់ និងដែលបានដឹងថាទាក់ទងជាមួយការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ សមត្ថភាពស្ថាប័ន គឺជាមូលដ្ឋានមួយនៃចំណងទាក់ទងនេះ។ អាស្រ័យហេតុនេះ ការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្សត្រូវបានបញ្ជាក់ថាជាយុទ្ធសាស្ត្រមួយនៃ "ចតុកោណកំណើន" ជាយុទ្ធសាស្ត្រទាំងបួននៃយុទ្ធសាស្ត្រចតុកោណរបស់រដ្ឋាភិបាលកម្ពុជាស្តីពីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ដំហានទី២ ដែលបង្ហាញជូនដោយសម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** កាលពីថ្ងៃទី ២៦ ខែកញ្ញា ឆ្នាំ២០០៨។

ទិដ្ឋភាពសំខាន់មួយនៃសមត្ថភាពស្ថាប័ននឹងអាចគ្រប់គ្រងបានធៀបនឹងធាតុអាកាសផ្ទាល់។ ដូច្នេះ ការកសាងសមត្ថភាពស្ថិតក្នុងចំណោមចំណុចចាប់ផ្តើមដែលមានការទាក់ទាញសម្រាប់ការបង្កើនភាពធន់នឹងអាកាសធាតុ។ ការកសាងសមត្ថភាពសុទ្ធតែផ្តល់ជាមូលដ្ឋានសម្រាប់គោលបំណងល្អជាច្រើន ដែលមានវិសាលភាពសម្រាប់ទិដ្ឋភាពនានាមិនត្រឹមតែអំពីបញ្ហាអាកាសធាតុប៉ុណ្ណោះទេ។

នៅក្នុងតំបន់ឆ្នេរ ក៏ដូចជាកន្លែងដទៃក្នុងប្រទេសផងដែរ គេអាចបង្ហាញភាពខុសគ្នារវាងទិដ្ឋភាពចំពោះមុខ រយៈពេលមធ្យម និងរយៈពេលវែង៖

- កង្វល់ចំពោះមុខរួមបញ្ចូលសុខភាពសាធារណៈ (ទឹកស្អាត និងអនាម័យ) របរចិញ្ចឹមជីវិត និងប្រព័ន្ធផលិតកម្ម និងសុខភាពបរិស្ថាននៃទីជម្រកក្នុងតំបន់ឆ្នេរ និងសមុទ្រ ដែលរួមទាំងព្រៃកោងកាងផងដែរ
- កង្វល់រយៈពេលមធ្យម និងរយៈពេលវែង រួមមានអន្តរកាលរលូនទៅរកសង្គមមួយដែលអាចមើលឃើញនូវភាពខុសគ្នាពីអ្វីដែលមានសព្វថ្ងៃនេះ។ ទៅអនាគត ប្រជាជនភាគច្រើននឹងរស់នៅតាមទីក្រុងជាងនៅតាមទីជនបទ។ កសិកម្មនឹងនៅតែជាវិស័យសំខាន់មួយ ប៉ុន្តែនឹងត្រូវការកម្លាំងពលកម្មតិចជាងបច្ចុប្បន្នឆ្ងាយណាស់ ហើយសេដ្ឋកិច្ចជាតិនឹងបានទទួលការគាំទ្រពីវិស័យកម្មន្តសាល ឧស្សាហកម្ម និងសេវាកម្ម ដែលរួមទាំងទេសចរណ៍។ ការអភិវឌ្ឍនេះដំណើរការពេញទំហឹង និងទៅតាមការចង់បាន។ ការប្រឈមគឺ

អន្តរកាលរលូនមួយដែលគ្មានបន្សល់ទុកឥទ្ធិពលអវិជ្ជមានខាងសង្គម ដែលប្រជាជនមួយផ្នែកត្រូវបានបន្សល់ទុកនៅពីខាងក្រោយអន្តរកាលនេះ។

- ការប្រឈមសំខាន់មួយផ្សេងទៀត គឺការបន្តពង្រឹងប្រព័ន្ធអប់រំជាតិ (ពីថ្នាក់បឋមសិក្សាដល់សកលវិទ្យាល័យ) និងការពង្រឹងមូលដ្ឋានធនធានរបស់ជាតិនៃមន្ត្រីរដ្ឋាភិបាល និងអ្នកអនុវត្តវិជ្ជាជីវៈនានា។

អភិបាលកិច្ចល្អពឹងផ្អែកលើសមត្ថភាពស្ថាប័នគ្រប់គ្រាន់ និងដែលមានការឆ្លើយតប ហើយរាល់កិច្ចប្រឹងប្រែងនៅក្នុងន័យនេះ ពិតជានឹងរួមចំណែកទៅក្នុងការធ្វើឲ្យសង្គមមានសុខភាពល្អ និងវិបុលភាព។

## ៦.២ តម្រូវការសមត្ថភាពជាក់លាក់

សម្រាប់គោលបំណងនៃការសិក្សានេះ "សមត្ថភាពស្ថាប័ន" ត្រូវបានរាប់បញ្ចូលជំនាញឧបករណ៍ និងធនធានដទៃទៀត ដែលមានសម្រាប់ស្ថាប័នណាមួយ ដើម្បីអាចរ៉ាប់រងការទទួលខុសត្រូវទូទៅ ឬកិច្ចការជាក់លាក់។ សមត្ថភាពបែបនេះរួមមានៈ

- បុគ្គល ជំនាញរបស់មនុស្ស
- វត្ថុមានទិន្នន័យ និងព័ត៌មានដែលពាក់ព័ន្ធ ដែលរួមទាំង ផែនទី និងទិន្នន័យធាតុអាកាស
- សម្បទា (ដូចជា ផ្នែករឹងនិងផ្នែកទន់នៃកុំព្យូទ័រ ការដឹកជញ្ជូន បរិក្ខារសម្រាប់ពិនិត្យតាមដាន និងវិភាគ)
- ឧបករណ៍ៈ គោលការណ៍ណែនាំ និងឧបករណ៍គាំទ្រការធ្វើសេចក្តីសម្រេច
- ធនធានហិរញ្ញវត្ថុៈ (១) សម្រាប់ប្រតិបត្តិការជាប្រចាំ និងការថែទាំ និង (២) សម្រាប់ការអនុវត្តកិច្ចផ្តួចផ្តើមអភិវឌ្ឍន៍អនុលោមតាមផែនការនានា
- គំរូនៃបណ្តាញការងារ (សម្រាប់ការពិភាក្សាជាមួយថ្នាក់ដឹកនាំដទៃទៀត និងជាមួយស្ថាប័នផ្សេងនៅកម្រិតដូចគ្នា)
- ទំនាក់ទំនងជាមួយ (១)អ្នកប្រើប្រាស់សេវា (២) វិស័យឯកជន និង (៣) អ្នកពាក់ព័ន្ធដទៃទៀត។

សារៈសំខាន់នៃសំណុំលក្ខណៈទាំងនេះមានបង្ហាញពិស្តារដូចខាងក្រោមៈ

### បុគ្គលិក ជំនាញរបស់មនុស្ស

ជំនាញរបស់មនុស្សមានសារៈសំខាន់ណាស់ ដោយសារលក្ខខណ្ឌនានាវិវត្តន៍ នៅក្រោមលក្ខខណ្ឌនៃសម្ពាធបន្ថែមទៀត ដែលបង្កដោយការប្រែប្រួលអាកាសធាតុ។ សេចក្តីសង្ខេបមួយនៃតម្រូវការ ដែលទាក់ទងនឹងអាកាសធាតុ មានបង្ហាញក្នុងតារាងខាងក្រោមៈ

| **ទិដ្ឋភាពរួមនៃលក្ខខណ្ឌជំនាញរបស់មនុស្ស** | |
|---|---|
| **ឥទ្ធិពល** | ការត្រួតពិនិត្យលើការជ្រាបចូលនៃទឹកប្រៃ<br>ការត្រួតពិនិត្យសំណឹកឆ្នេរ<br>ការដោះទឹក ការត្រួតពិនិត្យទឹកជំនន់<br>ការត្រៀមបង្ការគ្រោះរាំងស្ងួត និងការកាត់បន្ថយ<br>សុខភាពព្រៃកោងកាង |
| **ភាពធន់** | ទឹកស្អាត និងអនាម័យ |

| | |
|---|---|
| | ការគ្រប់គ្រងសំណល់រាវ ប្រសិទ្ធភាពទឹក<br>បច្ចេកវិទ្យាធ្វើស្រែ ប្រសិទ្ធភាពនៃការផលិត និងការគំរាមកំហែងដែលពាក់ព័ន្ធ<br>ការបង្កាត់ពូជសត្វចិញ្ចឹម ប្រសិទ្ធភាពនៃការផលិត និងការគំរាមកំហែង ដែលពាក់ព័ន្ធ<br>ប្រព័ន្ធផលិតកម្មផ្សេងទៀត ប្រសិទ្ធភាពនៃផលិតកម្ម និង ការគំរាមកំហែងដែលពាក់ព័ន្ធ<br>គុណភាពដី និងការកែលម្អដី។ |
| **មូលដ្ឋានដំណេះដឹង** | ការគ្រប់គ្រងទិន្នន័យ |

កិច្ចប្រឹងប្រែងអភិវឌ្ឍន៍ជំនាញដ៏មានតម្លៃជាច្រើន បានធ្វើឡើងក្នុងពេលកន្លងមក ចំណែកកិច្ចប្រឹងប្រែងដទៃទៀតកំពុងរីកចម្រើន ឬក្នុងការគ្រោងទុក។ ការពិភាក្សា និងអាចជាការសម្របសម្រួលទន់ភ្លន់មួយ អាចបន្ថែមគុណតម្លៃដល់កិច្ចប្រឹងប្រែង ដោយចំណាយបន្ថែមតិចតួចបំផុត។ ការចំណាយនេះរួមបញ្ចូលសម្រាប់សម្ភារៈបណ្តុះបណ្តាល និងអាចនៅក្នុងពេលណាមួយ ការទទួលស្គាល់នៅកម្រិតណាមួយនៃការបណ្តុះបណ្តាល ដែលអាចធ្វើឡើងនៅក្រោមកិច្ចប្រឹក្សា និងដែលអាចក្នុងកិច្ចសហការជាមួយសកលវិទ្យាល័យមួយ ឬច្រើន។

**ទិន្នន័យ និងព័ត៌មាន**

ទិន្នន័យ និងព័ត៌មានគឺជាតម្រូវការចាំបាច់សម្រាប់ការធ្វើសេចក្តីសម្រេចឲ្យទាន់ពេលវេលា និងបានសមស្រប។ មួយផ្នែកធំនៃកម្ពុជាក្នុងពេលថ្មីៗនេះ មានហេដ្ឋារចនាសម្ព័ន្ធជាច្រើនដែលបានសាងសង់ដោយផ្អែកលើចំណេះដឹងកម្រិតទាប ដោយសារតែពុំមានទិន្នន័យ ឬមិនងាយស្រួលរកបាន។ មូលដ្ឋានដ៏ល្អមួយសម្រាប់ការសិក្សាលទ្ធភាព និងការបង្កើតគម្រោងប្លង់ នឹងបង្កើនអត្រាផលធៀបការចំណាយ-ផលចំណេញនៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ កាត់បន្ថយហានិភ័យ និងបន្ថែមបរិយាកាសវិនិយោគល្អ។

*ការធ្លាក់ភ្លៀង*មានភាពខុសគ្នាទៅតាមរដូវ ក៏ដូចជា ភាពខុសគ្នាក្នុងរយៈពេលខ្លីផងដែរ។ នៅក្នុងតំបន់ឆ្នេរ កំពស់ទឹកភ្លៀង មានភាពខុសគ្នាជាខ្លាំងពីទីតាំងមួយទៅទីតាំងមួយផ្សេងទៀត។ កំពស់ទឹកភ្លៀងជាមធ្យមប្រចាំឆ្នាំអាចខុសគ្នា ១ម ក្នុងមួយឆ្នាំ សម្រាប់តំបន់នានាក្នុងចម្ងាយតិចជាង ៥០គ.ម។ ទិន្នន័យពីស្ថានីយតែមួយច្រើនតែផ្តល់ត្រឹមជាការបង្ហាញអំពីលក្ខខណ្ឌនៅជិតទីតាំងណាមួយប៉ុណ្ណោះ។ ចំណេះដឹងអំពីការធ្លាក់ភ្លៀងតាមធម្មតា និងមិនប្រក្រតី គឺជាតួលេខដែលត្រូវការ សម្រាប់ការកសាងផែនការដាំដំណាំ ប្រតិបត្តិការប្រព័ន្ធស្រោចស្រព និងការវាយតម្លៃលទ្ធភាព និងការបង្កើតគំរូប្លង់នៃហេដ្ឋារចនាសម្ព័ន្ធស្រោចស្រព និងដោះទឹក។ ទិន្នន័យខ្លះមានរួចមកហើយ ប៉ុន្តែនៅដាច់ដោយដុំ និងមិនអាចរកបានភ្លាមៗឡើយ។ បង្គុំរវាងការពិនិត្យតាមដាន និងទិន្នន័យពីផ្កាយរណប (ដែលអាចរកបានតាមរយៈអ៊ិនធឺណិតដោយឥតគិតថ្លៃ) អាចផ្តល់វិសាលភាពគ្របដណ្តប់បានប្រសើរជាង។ ការផ្សព្វផ្សាយបានប្រសើរ នឹងផ្តល់អត្ថប្រយោជន៍ធំធេងដោយចំណាយតិចតួចបំផុត។

ព័ត៌មានអំពី*កម្រិតកំពស់ទឹកសមុទ្រមធ្យមប្រចាំខែ កំពស់ទឹកជោរ និងកំពស់ព្យុះសមុទ្រ* ត្រូវការជាចាំបាច់សម្រាប់ការវាយតម្លៃហានិភ័យទឹកជំនន់ និងការជ្រាបចូលនៃទឹកប្រៃ និងសម្រាប់ការវាយតម្លៃលទ្ធភាព និងរូបផ្គុំនៃទំនប់ កំពស់ និងសមត្ថភាពដោះទឹក។

ទិន្នន័យអំពី*វិភាយចំហាយទឹក និងកាំរស្មីព្រះអាទិត្យ* មានដោយកម្រ ឬគ្មាន ប៉ុន្តែមានប្រយោជន៍ ទាក់ទងនឹងការជ្រើសរើសពូជថ្មី និងល្អជាងមុន។

*ការស្រុតដី* អាចជាបញ្ហាមួយ នៅក្នុងតំបន់ទំនាបដែលត្រូវការដោះទឹក ដូចជានៅប៉ូលខែរព្រៃនប់ ក្នុងខេត្តព្រះសីហនុ។ ភស្តុតាងល្អជាបរិមាណអាចជួយសម្រួលដល់ការធ្វើសេចក្តីសម្រេចបានសមស្រប និងទាន់ពេលវេលា ការវាយតម្លៃអំពីលទ្ធភាព និងការបង្កើតប្លង់រូបផ្គុំនៃទំនប់រលក និងហេដ្ឋារចនាសម្ព័ន្ធដោះទឹក។

*ទិន្នន័យសេដ្ឋកិច្ចសង្គម* មានសារៈសំខាន់សម្រាប់ការកសាងផែនការអភិវឌ្ឍន៍ និងការពិនិត្យតាមដានវឌ្ឍនភាព មាននៅកម្រិតឃុំ ពីវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ។

## សម្ភារ

សម្ភារាប់បញ្ចូលឧបករណ៍សំខាន់ៗសម្រាប់ការិយាល័យ (ម៉ាស៊ីនបោះពុម្ព ម៉ាស៊ីនថតចម្លង) ផ្នែករឹង និងផ្នែកទន់នៃកុំព្យូទ័រ រថយន្ត ម៉ាស៊ីនថត និងឧបករណ៍សម្រាប់កំណត់ទីតាំង ការពិនិត្យតាមដាន និងការវិភាគ។ សព្វថ្ងៃនេះ ស្ថាប័នរដ្ឋាភិបាលនៅស្ទើរតែទូទាំងខេត្ត និងស្រុកក្នុងតំបន់ឆ្នេរ មានសម្ភារដែលត្រូវការឲ្យកែលម្អ។ ស្ថានភាពបែបនេះក៏ដោយសារតែភាពខ្វះខាតមូលនិធិ។ សូម្បីតែនៅក្នុងករណីជាញឹកញាប់ សម្ភារខ្លះៗដែលបានផ្តល់ពីអតីតកាល អាចពុំមានការប្រើប្រាស់ ដោយសារតែខ្វះមូលនិធិសម្រាប់ប្រតិបត្តិការ និងការថែទាំ។

ឧទាហរណ៍ *ការវិភាគដី* គឺជាតម្រូវការដែលមានជាទូទៅមួយ។ សព្វថ្ងៃ កសិករខ្លះប្រើប្រាស់ជីគីមី ហើយកសិករជាច្រើនថែមទៀតនឹងធ្វើដូចគ្នានេះនៅក្នុងពេលខាងមុខ ដើម្បីគាំទ្រដល់ការបង្កើនប្រភេទពូជស្រូវថ្មី និងល្អជាងមុនរបស់ពួកគេ ក៏ដូចជាដំណាំក្រៅពីស្រូវផងដែរ។ ប៉ុន្តែជម្រើសនៃការប្រើប្រាស់ជីចម្រុះ N-P-K អាស្រ័យលើបរិមាណនៃសារជាតុផ្សំដែលមាននៅក្នុងដី និងក្នុងទឹកស្រោច។ ប្រសិនបើមានការប្រើប្រាស់ជីដែលមានល្បាយទាបជាងកម្រិតសមស្រប វាអាចផ្តល់ឥទ្ធិពលវិជ្ជមានជាក់លាក់មួយកម្រិត។ ប៉ុន្តែកសិករនៅតែទិញសមាសភាពជីដែលមិនចាំបាច់ ហើយបរិស្ថាននឹងត្រូវបំពុលដោយសារតែសារជាតុដែលមានហួសពីតម្រូវការ។ ចំណេះដឹងអំពីសារជាតុចិញ្ចឹមនៅក្នុងដី និងទឹក អាចទ្រទ្រង់ដល់កសិករ និងបរិស្ថាននៅក្នុង ពេលជាមួយគ្នានេះ។ នាយកដ្ឋានកសិកម្ម ឬ ប្រតិបត្តិករក្នុងវិស័យឯកជន (អាចអ្នកផ្គត់ផ្គង់ជីផងដែរ)អាចផ្តល់ការវិភាគនានាដោយគិតកម្រៃ។ កសិករនឹងបានដឹងយ៉ាងងាយអំពីថាតើការធ្វើបែបនោះមានប្រយោជន៍ឬយ៉ាងណា។

## ឧបករណ៍

យោបល់ជាញឹកញាប់ដែលទទួលបាននៅក្នុងពេលពិគ្រោះយោបល់នៅក្នុងខែ ឧសភា ឆ្នាំ ២០១២ គឺការផ្តល់*គោលការណ៍ណែនាំ*អំពីកិច្ចការដែលទាក់ទងនឹងអាកាសធាតុ។ ទាក់ទងនឹង (១) ការកសាងមូលដ្ឋានចំណេះដឹង និង (២) ការកសាងផែនការ គោលការណ៍នានាអាចមានប្រយោជន៍សម្រាប់៖

- ការពិនិត្យតាមដាន និងការចងក្រងជាឯកសារអំពីភាពងាយរងគ្រោះដែលទាក់ទងនឹងអាកាសធាតុ ដែលរួមទាំង កិច្ចប្រឹងប្រែងពិនិត្យតាមដានក្នុងកម្រិតអប្បបរមា (និងចំណាយទាប) ប៉ុន្តែជាលក្ខណៈប្រព័ន្ធដែលផ្តោតចំគោលដៅច្បាស់លាស់។
- ការពិនិត្យមើលឱកាសនិងហានិភ័យដែលទាក់ទងនឹងអាកាសធាតុ ដែលអាចស្ថិតក្នុងការសម្របសម្រួល (ឬចម្រុះ) ជាមួយការជ្រើសរើសនៅពេលធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។
- ការបញ្ជ្រាបភាពធន់នឹងអាកាសធាតុ ទៅក្នុងការកសាងផែនការនៅថ្នាក់ក្រោមជាតិ (ដែលរួមទាំង នៅថ្នាក់ឃុំ)។

ទាក់ទងនឹងកិច្ចការនេះ នៅពេលថ្មីៗនេះមានកិច្ចផ្តួចផ្តើមមួយចំនួនត្រូវបានអនុវត្ត ចំណែកកិច្ចការដទៃទៀត ត្រូវបានគ្រោង ឬកំពុងចាត់ចែងនៅក្រោមក្រសួងមហាផ្ទៃ ក្រសួងផែនការ និងក្រសួងបរិស្ថាន (និងអាចនៅក្រោមក្រសួងដទៃទៀតផងដែរ)។

នៅក្នុងរយៈពេលមធ្យម *ឧបករណ៍គាំទ្រការធ្វើសេចក្តីសម្រេច* អាចផ្តល់មធ្យោបាយប្រកបដោយប្រសិទ្ធភាពដើម្បីពង្រឹងការវិភាគផលប៉ះពាល់ និងលទ្ធភាព ព្រមទាំងការសម្រេចនានាអំពីការវិនិយោគ និងកិច្ចផ្តួចផ្តើមអភិវឌ្ឍន៍ដទៃទៀតផងដែរ។ កិច្ចការនេះអាចបន្ថែមនូវផលប្រយោជន៍ (និងកាត់បន្ថយហានិភ័យ) នៃអន្តរាគមន៍រូបវន្ត និងការប្រើប្រាស់ដី ដែលកំពុងអនុវត្ត ឬកំពុងគ្រោងនៅទូទាំងតំបន់ឆ្នេរ។ ឧទាហរណ៍អំពីការវិភាគគឺការពាក់ព័ន្ធខាងបរិស្ថាន ទឹកហូរលើផ្ទៃដី និងការជោះទឹក (ដែលរួមទាំង ប៉ុន្តែ មិនមែនកំហិតត្រឹម តំបន់ទីក្រុងប៉ុណ្ណោះទេ) និងសំណឹក និងការជុះដីក្នុងតំបន់ឆ្នេរ។ *ឧបករណ៍GIS* អាចសម្រួលបានច្រើនទាំង សម្រាប់ការពិនិត្យតាមដាន និងការកសាងផែនការ ប៉ុន្តែទាមទារឲ្យមានឧបករណ៍ និងកម្មវិធី(Software) ដែលត្រូវចំណាយខ្ពស់និងក្រុមអ្នកជំនាញដែលមានសមាភាពគ្រប់គ្រាន់សម្រាប់អនុវត្តការនេះជាប្រចាំផងដែរ។

ឧបករណ៍បែបនេះអាចជាបន្តបន្ទាប់ យកមកអនុវត្តសម្រាប់ការប្រើប្រាស់នៅតាមស្ថាប័ន ពីសំណាក់ស្ថាប័ននានារបស់រដ្ឋាភិបាល និង/ឬ នៅក្នុងវិស័យឯកជន ឬ សកលវិទ្យាល័យ ដែលអាចធ្វើឲ្យឧបករណ៍ទាំងនេះ(និងបទពិសោធន៍ដែលមាន) អាចប្រើប្រាស់បានឆ្លើយតបនឹងតម្រូវការ។

## ធនធានហិរញ្ញវត្ថុ

ធនធានហិរញ្ញវត្ថុគឺជាតម្រូវការសម្រាប់ប្រតិបត្តិការ និងការថែទាំសំខាន់ៗជាមូលដ្ឋាន។ ធនធានបន្ថែម(សម្រាប់សកម្មភាពមិនជាប់ជាប្រចាំ) គឺជាតម្រូវការសម្រាប់ការអនុវត្តកិច្ចផ្តួចផ្តើមអភិវឌ្ឍន៍អនុលោមតាមផែនការនានា និងអាចសម្រួលឲ្យមានការឆ្លើយតបទាន់ពេលវេលាតបនឹងតម្រូវការអភិវឌ្ឍន៍បន្ទាន់ និង/ឬដែលផ្តល់អត្ថប្រយោជន៍ពិតប្រាកដ ដូចជា អ្វីដែលបានកំណត់នៅកម្រិតឃុំ។ ជាទូទៅ ធនធានហិរញ្ញវត្ថុមិនមានគ្រប់គ្រាន់ឡើយនៅក្នុងតំបន់សិក្សានេះ។

ជំហានតូចមួយតាមទិសដៅត្រឹមត្រូវអាចធ្វើឡើង ដោយដាក់ឲ្យអនុវត្តប្រព័ន្ធប្រមូលយកកម្រៃសម្រាប់បំពេញថ្លៃចំណាយ នៅក្នុងករណីសមស្រប និងដែលអាចធ្វើបាន ដោយគ្មានឥទ្ធិពលអវិជ្ជមាន។ ការយកកម្រៃទឹកត្រូវបានអនុវត្តរួចមកហើយ សម្រាប់ដីស្រែដែលទទួលសេវាពីប្រព័ន្ធស្រោចស្រព និងមានគោលដៅប្រមូលយកកម្រៃសម្រាប់បំពេញថ្លៃចំណាយលើប្រតិបត្តិការ និងការថែទាំ (ប៉ុន្តែមិនមែនថ្លៃចំណាយលើដើមទុនឡើយដោយសារមិនអាចធ្វើបែបនេះបានឡើយ)។ គេប្រហែលជាអាចយកកម្រៃសម្រាប់ទិន្នន័យ សម្រាប់ការពិនិត្យ

ឯកសារវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (ដូចជា កម្រៃដែលប្រមូលយកជាទូទៅ និងដែលត្រូវបានអនុវត្ត សម្រាប់អាជ្ញាប័ណ្ណសម្រាប់ការសាងសង់) សម្រាប់ការធ្វើអធិការកិច្ចបរិស្ថានជាទៀងទាត់ នៅតាមរោងចក្រ និងដីសម្បទាន សម្រាប់ការបូមទឹកយកមកប្រើប្រាស់ (ដែលរួមទាំងទឹកក្រោមដី) និងសម្រាប់អាជ្ញាប័ណ្ណដើម្បីចោលសម្រាមផងដែរ។

### គំរូនៃការអនុវត្តការងារបណ្តាញ

សមត្ថភាពបណ្តាញ គឺជាសំណុំលក្ខណៈសំខាន់មួយនៃអង្គភាពរដ្ឋបាលសាធារណៈ ដែលពាក់ព័ន្ធក្នុងការផ្តល់សេវា។ បណ្តាញនេះផ្សំដោយៈ

- ទំនាក់ទំនងតាមខ្សែបណ្តោយជាមួយអ្នកគ្រប់គ្រងនៃលំដាប់ថ្នាក់ខុសៗគ្នា (ដូចជា រាជក្រសួង មន្ទីរ នៅតាមខេត្ត និងឃុំ)។
- ទំនាក់ទំនងតាមខ្សែទទឹងជាមួយស្ថាប័នដទៃទៀតនៅលំដាប់ថ្នាក់ដូចគ្នា។
- ទំនាក់ទំនងជាមួយស្ថាប័នខាងក្រៅ (១) អ្នកប្រើប្រាស់សេវា (២) វិស័យឯកជន (៣) អ្នកពាក់ព័ន្ធដទៃទៀត ដូចជា អង្គការសង្គមស៊ីវិល និង (៤)ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន។

នៅថ្នាក់ខេត្ត បណ្តាញផ្លូវការមួយកំពុងប្រតិបត្តិការនៅក្រោមអធិបតិភាពនៃអភិបាលខេត្ត។ ឧទាហរណ៍ ផែនការអភិវឌ្ឍន៍ខេត្ត និងផែនការវិនិយោគសាធារណៈត្រូវបានរៀបចំឡើង ដោយមានការចូលរួមយ៉ាងសកម្មពីមន្ទីរពាក់ព័ន្ធខុសៗគ្នា។ ការចាត់ចែងបែបនេះដំណើរការបានល្អនៅក្នុងតំបន់សិក្សានេះ ប៉ុន្តែអាចពង្រឹងជាបន្ថែមទៀតតាមវិធីខុសៗគ្នា។ នៅក្នុងករណីជាច្រើន បណ្តាញរវាងថ្នាក់ខេត្ត ថ្នាក់ស្រុក និងឃុំ ដំណើរការបានល្អ។ បណ្តាញនេះមានសារៈសំខាន់ណាស់ ដោយសារតម្រូវការ និងឱកាសអភិវឌ្ឍន៍ត្រូវបានកំណត់នៅកម្រិតឃុំ ប៉ុន្តែអាចសមស្របជាង ប្រសិនបើអនុវត្ត(និងផ្តល់ហិរញ្ញប្បទាន)នៅថ្នាក់ខ្ពស់ជាងនេះ។ សូម្បីតែវាអាចដំណើរការបានល្អក៏ដោយ រាល់ការគាំទ្រដល់ការពង្រឹងបណ្តាញបែបនេះ មានប្រយោជន៍ណាស់។

### ច្បាប់ថ្មីស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

ច្បាប់ថ្មីស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន កំពុងរៀបចំដោយក្រសួងបរិស្ថាន។ មានការរំពឹងថាច្បាប់ថ្មីនេះនឹងមានចែងផងដែរអំពីការគ្រប់គ្រងលើការបំភាយនានា (ដែលរួមទាំង ឧស្ម័នផ្ទះកញ្ចក់) ក៏ដូចជាការប្រើប្រាស់ដីផងដែរ។ វាជាការល្អ ប្រសិនបើមានការគិតគូរអំពីថាតើច្បាប់ថ្មីនេះអាចរួមបញ្ចូល "ការពិនិត្យភាពធន់នឹងអាកាសធាតុ និងការពាក់ព័ន្ធនៃហានិភ័យគ្រោះមហន្តរាយ (ការគំរាមកំហែងនិងឱកាស) នៅក្នុងករណីសមស្រប។

## ៦.៤ ឱកាសកសាងសមត្ថភាព

ការពិគ្រោះយោបល់ដែលបានធ្វើឡើងនៅក្រោមការសិក្សានេះ បានកំណត់អត្តសញ្ញាណធនធានមនុស្សជាឧបសគ្គចំបងមួយសម្រាប់សមត្ថភាពស្ថាប័នដែលទាក់ទងនឹងអាកាសធាតុ។ ការបណ្តុះបណ្តាលគឺជាអាទិភាពចំបងមួយ ហើយការផ្តល់ព័ត៌មាន និងគោលការណ៍ណែនាំ គឺជាឧបសគ្គមួយផ្សេងទៀត។

### ថ្នាក់ខេត្ត

ខេត្តគឺជាឃានចំបងមួយសម្រាប់ពង្រឹងសមត្ថភាពនៅថ្នាក់ក្រោមជាតិ។ មន្ទីរជាច្រើននៅថ្នាក់ខេត្តមានសមត្ថភាពរឹងមាំជាបង្គួរ (ទោះបីបានរងការប៉ះទង្គិចពីការប្តូរបុគ្គលិកជាញឹកញាប់ក៏ដោយ) និងមានចំណេះដឹងជាក់លាក់អំពីតម្រូវការ និងឱកាសអភិវឌ្ឍន៍។ បច្ចុប្បន្ននេះ សមត្ថភាពពាក់ព័ន្ធកំពុងត្រូវបានអភិវឌ្ឍន៍នៅក្នុងរដ្ឋបាលថ្នាក់ខេត្ត (នៅក្រោមខុទ្ទកាល័យអភិបាលខេត្ត)។ កិច្ចសហការអន្តរស្ថាប័នមានដំណើរការល្អ ហើយទំនាក់ទំនងជាមួយអ្នកប្រើប្រាស់សេវា និងអ្នកពាក់ព័ន្ធនានា មានសភាពជិតស្និទ្ធ និងមានដំណើរការ។ ការកសាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍មានទស្សនវិស័យដែលមើលវែងឆ្ងាយជាងប្រតិបត្តិការចំពោះមុខ និងតម្រូវការសម្រាប់ការថែទាំ ប៉ុន្តែមូលនិធិសម្រាប់ការអនុវត្តនៅតែពុំមានគ្រប់គ្រាន់។ អង្គភាពសម្របសម្រួលតំបន់ឆ្នេរនៃក្រសួងបរិស្ថាន និងក្រុមការងារអន្តរស្ថាប័ននៅថ្នាក់ខេត្តនៅក្រោមការិយាល័យអភិបាលខេត្ត ផ្តល់ជាវេទិកាសម្រាប់បំពេញមុខងារ ដើម្បីកសាងមសត្ថភាពនៅថ្នាក់ខេត្ត ទាក់ទងនឹងការប្រែប្រួលអាកាសធាតុ ដែលអាចផ្តល់នូវវេទិកាមួយសម្រាប់គាំទ្រដល់ឃុំនានា។

### អាជ្ញាធរឃុំ និងសហគមន៍

អាជ្ញាធរឃុំ មានអំណាចរឹងមាំ បើគិតពីចក្ខុវិស័យនៃតម្រូវការ និងអាទិភាពអភិវឌ្ឍសេដ្ឋកិច្ចសង្គម ប៉ុន្តែជាក់ស្តែងមានអំណាចទាបជាងនេះទាក់ទងនឹងជម្រើសគ្រប់គ្រង ជាពិសេស នៅក្នុងករណីនៃការប្រឈមដែលមិនបានស្គាល់ច្បាស់ ដូចជា ការប្រែប្រួលអាកាសធាតុ និងបច្ចេកវិទ្យាផលិតកម្មថ្មីៗ។ អាជ្ញាធរឃុំមានស្មៀនម្នាក់សម្រាប់ឃុំនីមួយៗ (តែងតាំងដោយក្រសួងមហាផ្ទៃ)។ អាជ្ញាធរឃុំពុំមានមូលដ្ឋានសម្រាប់ការកសាងសមត្ថភាពទូលំទូលាយនៅក្នុងស្ថាប័នរបស់ខ្លួនឡើយ។ ប៉ុន្តែ ជំនាញនានាត្រូវបានផ្តល់តាមតម្រូវការ ពីសំណាក់មន្ទីរពាក់ព័ន្ធនៅថ្នាក់ខេត្ត និងដោយអង្គភាពគាំទ្របច្ចេកទេសនៃរដ្ឋបាលខេត្ត ដូចជា ទាក់ទងនឹងការអភិវឌ្ឍ និងការកសាងផែនការវិនិយោគនៅថ្នាក់ឃុំ។ ធនធានហិរញ្ញវត្ថុជាទូទៅមិនគ្រប់គ្រាន់ឡើយ ហើយក្នុងករណីជាច្រើន ជាឧបសគ្គដល់ប្រតិបត្តិការបន្ទាន់ និងការថែទាំផ្លូវថ្នល់ ហេដ្ឋារចនាសម្ព័ន្ធស្រោចស្រព និងប្រព័ន្ធការពារទឹកជំនន់។ ក្នុងករណីនេះ ការទទួលបានជំនាញបានក្លាយជាគន្លឹះមួយក្នុងការកសាងសមត្ថភាពនៅថ្នាក់ឃុំ។

ជំនាញគឺជាតម្រូវការបន្ទាន់មួយ ដែលទាក់ទងនឹងប្រព័ន្ធផលិតកម្មជាទូទៅ និងប្រព័ន្ធផលិតកម្មដែលផ្អែកលើធនធាន។ ប្រការនេះត្រូវបានអះអាងនៅក្នុងគ្រប់ការពិគ្រោះយោបល់។ កសិករបានដឹងអំពីតម្រូវការដើម្បីបន្សាំនឹងការប្រែប្រួលអាកាសធាតុ ប៉ុន្តែមិនបានដឹងអំពីការប្រឈមពាក់ព័ន្ធថ្មីៗ និងដែលគ្មានភាពច្បាស់លាស់ឡើយ ដូចជា នៅពេលប្តូរពីស្រូវធ្ងន់មកស្រូវស្រាល នៅពេលទប់ស្កាត់ឱនភាពដីជ្ញី ឬនៅពេលអនុវត្តប្រព័ន្ធដាំដើមឈើឡើយ។

## ៦.៥ យោបល់អំពីសកម្មភាពកសាងសមត្ថភាព

យោបល់នានាដែលផ្តល់ខាងក្រោមនេះ ចាប់ផ្តើមពីតម្រូវការនានា ដែលទាក់ទងនឹងសកម្មភាពសាកល្បងនៅក្រោម CARP។ ទោះជាយ៉ាងណាក៏ដោយ គេមិនអាចធ្វើឲ្យមានភាពខុសគ្នាដាច់ខាតនៅក្នុងក្របខ័ណ្ឌនៃទីកន្លែង និងកាលវេលាបានឡើយ រវាងតម្រូវការចំពោះមុខ និងការកសាងសមត្ថភាពទូទៅ ដែលទាក់ទងនឹងអាកាសធាតុ ដែលនឹងទាមទារឲ្យមានការគិតគូររយៈពេលវែង ជាងអ្វីដែលអាចអនុវត្តបាននៅក្រោម

គម្រោង CARP។ សកម្មភាពកសាងសមត្ថភាពអាចទ្រទ្រង់ការអនុវត្តសកម្មភាពអនុវត្តបង្ហាញ ទន្ទឹមនឹងឆ្លើយតបទៅនឹងគោលបំណងដ៏មានប្រយោជន៍របស់ខ្លួន។ យោបល់ខ្លះដែលបានលើកស្នើមាន ដូចខាងក្រោម៖

**ថ្នាក់ខេត្ត**

រដ្ឋបាលថ្នាក់ខេត្តរួមមាន មន្ទីរពាក់ព័ន្ធនៃក្រសួងនានានៅថ្នាក់ជាតិ និងរដ្ឋបាលខេត្ត ដែលមានអង្គភាពគាំទ្របច្ចេកទេស។ តម្រូវការចំពោះមុខរួមមាន៖

- ជំនាញបច្ចេកទេសដែលទាក់ទងនឹងភាពធន់នឹងអាកាសធាតុនៃប្រព័ន្ធផលិតកម្មនិងហេដ្ឋារចនាសម្ព័ន្ធ។
- ឧបករណ៍ (ដែលរួមទាំង គោលការណ៍ណែនាំសម្រាប់គាំទ្រដល់ការធ្វើសេចក្តីសម្រេច)។ មានគោលការណ៍ណែនាំសម្រាប់ការកសាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ ហើយបច្ចុប្បន្នកំពុងត្រូវបានកែលម្អដើម្បីរួមបញ្ចូលបញ្ហាប្រែប្រួលអាកាសធាតុ។

**ឧទាហរណ៍អំពីសកម្មភាពសាកល្បង**

ការកសាងសមត្ថភាពសម្រាប់បំពេញតម្រូវការចំពោះមុខ និងសម្រាប់រយៈពេលខ្លី អាចរាប់បញ្ចូល ដូចជា៖

- *សិក្ខាសាលាតូចៗអន្តរស្ថាប័ន*ទៅតាមប្រធានបទនានា ដោយមានការចូលរួមពីអ្នកជំនាញមកពីថ្នាក់ជាតិ ដើម្បីពិភាក្សាអំពីភាពងាយរងគ្រោះដែលទាក់ទងនឹងអាកាសធាតុ ឱកាស និងជម្រើសគ្រប់គ្រង។
- *វគ្គបណ្តុះបណ្តាលអន្តរជំនាញស្តីពីការប្រែប្រួលអាកាសធាតុ* នៅថ្នាក់ខេត្ត និងស្រុក ដែលមានគោលដៅកំណត់អត្តសញ្ញាណចំណុចចាប់ផ្តើមសម្រាប់រួមបញ្ចូលភាពធន់នឹងអាកាសធាតុ នៅក្នុងការកសាងផែនការអភិវឌ្ឍន៍ និងជម្រុញការចែករំលែកទិន្នន័យ និងព័ត៌មាន។ វគ្គបណ្តុះបណ្តាលខ្លះបានអនុវត្តពីមុនមក និងបានទទួលការស្វាគមន៍យ៉ាងកក់ក្តៅ។

ក្រុមការងារថ្នាក់ខេត្តនៅក្នុងខេត្តគោលដៅទាំងពីរ មានស្ថានភាពរឹងមាំក្នុងការរួមចំណែក ជាមួយបណ្តាញអន្តរទីភ្នាក់ងារដែលមានដំណើរការ។

**ថ្នាក់ឃុំ និងសហគមន៍**

ឃុំ និងសហគមន៍មានតម្រូវការ៖

- ការយល់ដឹងអំពីបច្ចេកវិទ្យាថ្មីៗ និងដែលផ្អែកលើធនធានដែលនៅពុំទាន់បានស្គាល់ ដែលរួមទាំង (ប៉ុន្តែមិនកំហិតត្រឹម) ពូជស្រូវថ្មីៗ ការគ្រប់គ្រងដី និងប្រព័ន្ធដាំដើមឈើ។
- ការយល់ដឹងអំពីឱកាសដែលពាក់ព័ន្ធ និងជម្រើសគ្រប់គ្រង។
- ការពង្រឹងការគ្រប់គ្រងប្រព័ន្ធផលិតកម្ម និងហេដ្ឋារចនាសម្ព័ន្ធដែលផ្អែកលើធនធានដែលមានស្រាប់។

**ឧទាហរណ៍អំពីសកម្មភាពសាកល្បង**

ការកសាងសមត្ថភាពតបនឹងតម្រូវការចំពោះមុខ និងសម្រាប់រយៈពេលខ្លី អាចរាប់បញ្ចូល ដូចជា៖

- យុទ្ធនាការអប់រំ និងបង្កើនការយល់ដឹង ដោយចាប់ផ្តើមពីការបណ្តុះបណ្តាលគ្រូបង្គោលនៅថ្នាក់ខេត្ត ជាមួយការអនុវត្តសាកល្បងជាបន្តនៅក្នុងឃុំគោលដៅ ដែលពាក់ព័ន្ធជាមួយក្រុមប្រឹក្សាឃុំ និងសាលារៀន។ ប្រធានបទដែលត្រូវបង្រៀនអាចរួមបញ្ចូល កំណើនកំពស់ទឹកសមុទ្រ សំណឹកឆ្នេរ/ពាមសមុទ្រ ការជ្រាប

ចូលនៃទឹកប្រៃ ទីជម្រកព្រៃកោងកាង ស្មៅសមុទ្រ និងផ្កាថ្ម ទឹកជំនន់ និងខ្យល់ព្យុះ។ សម្ភារៈ បណ្តុះបណ្តាលអាចមានរៀបចំរួចជាស្រេច ដោយគ្រាន់តែកែសម្រួលឧបករណ៍បណ្តុះបណ្តាលដែលរៀបចំដោយអង្គការសង្គ្រោះសត្វព្រៃកម្ពុជាដែលបានរៀបចំឡើងសម្រាប់បណ្តាខេត្តក្នុងដែនទឹកសាប ដោយមានការគាំទ្រពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ UNDP និងមូលនិធិបរិស្ថានពិភពលោក។

- សកម្មភាពសាកល្បង/អនុវត្តបង្ហាញអំពីការដាំដំណាំដែលភាពធន់នឹងអាកាសធាតុ (ដូចមានចែងនៅក្នុងឯកសារការងារដាច់ដោយឡែករបស់ CARP ដែលបានរៀបចំឡើងស្របគ្នានេះ)។
- កម្មវិធីតភ្ជាប់ ដែលអាចពាក់ព័ន្ធជាមួយការផ្លាស់ប្តូរទស្សនកិច្ចសិក្សាពីសំណាក់កសិករ និងប្រតិបត្តិករទ្វារទឹកការពារការជ្រាបចូលនៃទឹកប្រៃ នៅក្នុងដែនដីសណ្តរគួឡុង (មេគង្គ) ក្នុងប្រទេសវៀតណាម ដែលមានបទពិសោធន៍ច្រើនអំពីការដាំដំណាំនៅក្នុងតំបន់ដែលរងឥទ្ធិពលពីការជ្រាបចូលនៃទឹកប្រៃ។
- ការគាំទ្រដល់សហគមន៍អ្នកប្រើប្រាស់ទឹក សហគមន៍កសិករ និងសហគមន៍នេសាទ ដែលពាក់ព័ន្ធនៅក្នុងបណ្តាញ (រៀនសូត្រពីគ្នាទៅវិញទៅមក) និងការយល់ដឹងអំពីឱកាសអភិវឌ្ឍន៍ និងជម្រើសគ្រប់គ្រង។

## ៦.៥ ឱកាសសម្រាប់រយៈពេលវែង

កិច្ចផ្តួចផ្តើមរយៈពេលវែង ហួសពីព្រំដែននៃគម្រោង CARP (ក្នុងក្របខ័ណ្ឌនៃពេលវេលា និងដែនភូមិសាស្ត្រ) អាចរួមបញ្ចូល៖

- ការគាំទ្រឲ្យមានការផ្សព្វផ្សាយអំពីទិន្នន័យដែលមានស្រាប់(កំពស់ទឹកភ្លៀង ខ្យល់ កំពស់ទឹកសមុទ្រ) និងការណែនាំអំពីការពិនិត្យតាមដានប្រសើរជាងមុន (ដែលរួមទាំង កម្រិតប្រៃនៃទឹកនៅលើផ្ទៃដី និងកាំរស្មីពីព្រះអាទិត្យ) និងការវិភាគទិន្នន័យ ដែលផ្តោតលប្រតិបត្តិការនៃប្រព័ន្ធ ជម្រើសពូជ និងការបង្កើតប្លង់រចនាសម្ព័ន្ធ។
- "អាត្លាស់អំពីការប្រែប្រួលអាកាសធាតុ"សម្រាប់តំបន់ឆ្នេរ និងការគាំទ្រឲ្យមានភាពងាយស្រួលក្នុងការទទួលបានផែនទីអំពីស្ថានភាពបច្ចុប្បន្ន (ធម្មតា និងស្ថានភាពមិនប្រក្រតី) នៃកំពស់ទឹកភ្លៀង និងកំពស់ទឹកសមុទ្រ និងហានិភ័យទឹកជំនន់។ "តំបន់សុវត្ថិភាពសម្រាប់ការជន្លៀស" ក៏អាចរួមបញ្ចូលផងដែរ ក្នុងករណីសមស្រប។
- ការជម្រុញឲ្យប្រើប្រាស់ផែនទី និងគាំទ្រឲ្យមានភាពងាយស្រួលក្នុងការទទួលបានផែនទីដែលមានស្រាប់ ក៏ដូចជា ការណែនាំអំពីការប្រើប្រាស់ទិន្នន័យ និងរូបថតពីផ្កាយរណប ដែលរួមទាំង ធនធានដែលមានជាស្រេចនៅក្នុងអ៊ិនធឺណិត។
- ការកសាងសមត្ថភាពលើការវិភាគ និងការគ្រប់គ្រងគុណភាពដី ដែលគាំទ្រដល់ការណែនាំអំពីការជ្រើសរើសពូជដំណាំ ការប្រើប្រាស់ជី និងកំប៉ុស្តិ៍ឲ្យបានសមស្រប និង បុរេសនាសម្រាប់ដំណាំជំនួស។ នៅក្នុងកន្លែងជាច្រើននៃតំបន់សិក្សានេះ ដីមិនទាន់សមស្របសម្រាប់ដំណាំក្រៅពីស្រូវឡើយ។
- ការគាំទ្រដល់បណ្តាញការងារថ្នាក់ជាតិ អំពីការត្រៀមបង្ការគ្រោះរាំងស្ងួត និងការកាត់បន្ថយគ្រោះរាំងស្ងួត ដែលមិនទាន់ជាបញ្ហានៅឡើយទេក្នុងពេលបច្ចុប្បន្ននៅក្នុងតំបន់ឆ្នេរ ប៉ុន្តែអាចលេចចេញជាបញ្ហានៅពេលដែលមានការប្រឈមទាក់ទងនឹងការការប្រែប្រួលអាកាសធាតុ។ កម្ពុជាមានអ្នកជំនាញការជាតិ និងអាចចែករំលែកចំណេះដឹងនេះជាមួយក្រុមរបស់ខ្លួននៅក្នុងតំបន់ឆ្នេរ។

- ការសិក្សាថ្នាក់អនុបណ្ឌិតនៅកម្រិតជាតិអំពីការគ្រប់គ្រងបរិស្ថាន (ដែលរួមទាំងអំពីអាកាសធាតុផងដែរ)។ (នៅពុំទាន់មានមុខវិជ្ជានេះនៅឡើយទេ)។
- ការគាំទ្រដល់អង្គការជាតិជំនាញវិជ្ជាជីវៈ ដែលគាំទ្រដល់បណ្តាញ និងការចែករំលែកចំណេះដឹងក្នុងចំណោមអ្នកអនុវត្ត។ អង្គការនានាអាចសហការជាមួយសាកលវិទ្យាល័យមួយ ឬច្រើន និង/ឬបណ្តាញអតីតនិស្សិត។ គេអាចចាត់ចែងឲ្យមានសិក្ខាសាលាសម្រួលឲ្យមានទស្សនកិច្ចសិក្សាទៅវិញទៅមក និងអាចបោះពុម្ពផ្សាយទស្សនាវដ្តីផងដែរ (ឬអាចទស្សនាវដ្តីវិទ្យាសាស្ត្រផងដែរ)។
- ការបោះពុម្ពផ្សាយអនុសាសន៍គោលនយោបាយ/ករណីសិក្សា ដែលរួមទាំងរឿងរ៉ាវអំពីជោគជ័យ (ដូចជាអំពីបច្ចេកទេសដាំដំណាំតាមបែបថ្មីផលិតផលដោយឡែក និងការពាក់ព័ន្ធនៃវិស័យឯកជន)។

# ៧. ការគាំទ្រដល់ការអប់រំអំពីការប្រែប្រួលអាកាសធាតុបង្កើតការយល់ដឹង និងពង្រឹងគណៈកម្មការសហគមន៍កសិករប្រើប្រាស់ទឹក

ជំពូកនេះសង្ខេប អំពីការវាយតម្លៃដែលបានធ្វើនៅក្នុងខែឧសភា និងមិថុនា ឆ្នាំ២០១២ អំពីតម្រូវការបណ្តុះបណ្តាល ដែលទាក់ទងនឹងការអប់រំអំពីការប្រែប្រួលអាកាសធាតុ ការបង្កើតការយល់ដឹង និងការពង្រឹងគណៈកម្មការសហគមន៍កសិករប្រើប្រាស់ទឹក។ កិច្ចការនេះ បានផ្អែកលើការពិគ្រោះយោបល់ជាបន្តបន្ទាប់ជាមួយស្ថាប័នរដ្ឋាភិបាល កសិករ អ្នកនេសាទ និងអ្នកដទៃទៀតនៅខេត្តកោះកុង និងព្រះសីហនុ ដោយមានរបាយការណ៍នៅក្រោមសមាសភាគ CARP។

ការវាយតម្លៃនេះទាក់ទងនឹងលទ្ធផល២នៃ CARP: "កំណើនភាពធន់របស់សហគមន៍តំបន់ឆ្នេរ និងប្រព័ន្ធអេកូឡូស៊ីដែលជាតំបន់ទ្រនាប់នៅក្នុងតំបន់ឆ្នេរនិងកំណែលម្អរបរចិញ្ចឹមជីវិត"។ ការវាយតម្លៃនេះទាក់ទងជាពិសេសទៅនឹងសកម្មភាពដូចតទៅៈ "សមត្ថភាពរបស់រដ្ឋាភិបាលនៅមូលដ្ឋានត្រូវបានពង្រឹងដើម្បីអនុវត្តការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងសកម្មភាពកាត់បន្ថយហានិភ័យអាកាសធាតុ" "បង្កើតការយល់ដឹងការផ្សព្វផ្សាយដល់មូលដ្ឋាន និងសម្ភារៈបណ្តុះបណ្តាលសម្រាប់សមាជិកសហគមន៍" និង " ការវាយតម្លៃអំពីតម្រូវការបណ្តុះបណ្តាល និងការអនុវត្តវគ្គបណ្តុះបណ្តាលនៅក្នុងគណៈកម្មការសហគមន៍កសិករប្រើប្រាស់ទឹកទាក់ទងនឹងការគ្រប់គ្រងហានិភ័យអាកាសធាតុការពាក់ព័ន្ធរបស់អាជ្ញាធរមូលដ្ឋាន"។

របាយការណ៍ទាំងមូល - "ការគាំទ្រដល់ការអប់រំអំពីការប្រែប្រួលអាកាសធាតុ បង្កើតការយល់ដឹង និងពង្រឹងគណៈកម្មការសហគមន៍កសិករប្រើប្រាស់ទឹក ខែធ្នូ ឆ្នាំ២០១២" អាចចម្លងចេញពីវេបសាយ CARP (www.czmcam.org)។

## ៧.១ ការអប់រំអំពីការប្រែប្រួលអាកាសធាតុ និងបង្កើតការយល់ដឹង

សកម្មភាពទាក់ទងគ្នាជិតស្និទ្ធចំនួនពីរត្រូវបានលើកស្នើះ

- ការបណ្តុះបណ្តាលគ្រូបង្គោល
- សាកល្បងការអប់រំ និងវគ្គបង្កើតការយល់ដឹងនៅថ្នាក់ឃុំ

### ហេតុផល

របាយការណ៍អភិវឌ្ឍន៍មនុស្សកម្ពុជា ឆ្នាំ២០១១ បានផ្តោតលើ "ការកសាភាពធន់ះអនាគតនៃរបរចិញ្ចឹមជីវិតនៅមូលដ្ឋាននៅចំពោះមុខការប្រែប្រួលអាកាសធាតុ"។ នៅទំព័រដំបូងរបាយការណ៍នេះកត់សំគាល់ថា "ការប្រែប្រួលអាកាសធាតុគឺជាបញ្ហាអភិវឌ្ឍន៍មនុស្សនិងក៏ជាបញ្ហាបរិស្ថានផងដែរ"។ ភាពចាំបាច់នៃការអភិវឌ្ឍមនុស្ស (និងសមត្ថភាពស្ថាប័ន) បានកើនឡើង ដោយសារតែកម្មវិធីវិមជ្ឈការ និងវិសហមជ្ឈការ ដែលកំពុងអនុវត្ត និងដែលគាំទ្រដោយគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (NCDD) ដែលមានគោលដៅបង្កើនការចូលរួមនៅថ្នាក់ក្រោមជាតិ នៅក្នុងការអភិវឌ្ឍ និងការកសាងផែនការវិនិយោគ និងការធ្វើសេចក្តីសម្រេចដែលពាក់ព័ន្ធ។

ការពិគ្រោះយោបល់ដែលបានធ្វើឡើងនៅក្រោម CARP ក្នុងខែឧសភាឆ្នាំ២០១២ បានអះអាងអំពីតម្រូវការទូលំទូលាយដើម្បីឲ្យមានកំណើនចំណេះដឹងអំពីការពាក់ព័ន្ធនៃការប្រែប្រួលអាកាសធាតុ និងជម្រើសបន្សាំដែលគាំទ្រដោយការបណ្តុះបណ្តាលគ្រូបង្គោល។ នេះជាសារតាសម្រាប់សកម្មភាព CARP ដែលមាន

គោលដៅពង្រឹងសមត្ថភាពរដ្ឋាភិបាលមូលដ្ឋាន និងកសាងចំណេះដឹងការផ្សព្វផ្សាយដល់មូលដ្ឋាន និងសម្ភារៈបណ្តុះបណ្តាលសម្រាប់សមាជិកសហគមន៍។

## សម្ភារៈសម្រាប់ការយល់ដឹង និងការអប់រំ

សម្ភារៈមួយឈុតសម្រាប់ការអប់រំ និងកសាងការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុត្រូវបានរៀបចំឡើង និងបានអនុវត្តដោយជោគជ័យនៅក្នុងគម្រោងបន្តពី NAPA ដោយអង្គការសង្គ្រោះសត្វព្រៃកម្ពុជា (SCW) ក្រោមកិច្ចសហការជាមួយក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ UNDP និងមូលនិធិបរិស្ថានពិភពលោក (GEF)។ ផ្នែកសំខាន់មួយនៃឧបករណ៍នេះ គឺផ្ទាំងព័ត៌មានមួយដែលមានប្រធានបទខុសៗគ្នាចំនួន៣៤ ដែលចែងអំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ការកាត់បន្ថយ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ទឹកស្អាត និងអនាម័យ ការទុកដាក់សំណល់ របរចិញ្ចឹមជីវិតតាមជនបទ ការអភិរក្សធនធាន និងការពាក់ព័ន្ធនៅតាមទីក្រុង។ ផ្នែកខាងមុខនៃសន្លឹកនីមួយៗមានគំនូរយ៉ាងល្អប្រកបដោយពណ៌ជាមួយប្រធានបទដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ (ដោយគ្មានអត្ថបទ) ចំណែកនៅទំព័រខាងក្រោយ(ជាពណ៌ខ្មៅ) មានសេចក្តីពន្យល់ (អំពីសញ្ញាណរូបភាពនិងវិជ្ជាក្រោមជាភាសាខ្មែរ)។ អ្នកធ្វើបទបង្ហាញអាចបង្ហាញទំព័រខាងមុខដល់ក្រុមសិក្ខាកាមទន្ទឹមនឹងការប្រើប្រាស់កំណត់សំគាល់នៅទំព័រខាងក្រោយសម្រាប់ជាការណែនាំ។ ទន្ទឹមនឹងនេះក៏មានការផលិតជា"សំណៅខ្លី"មួយក៏ដូចជាឌីវីឌី ដែលមានការបទបង្ហាញវីដេអូ(ជាភាសាខ្មែរ)ផងដែរ។

ផ្ទាំងរូបភាពនេះ ត្រូវបានរៀបចំឡើងក្នុងបំណងផ្តល់ការអប់រំដល់បុគ្គលិកផ្សព្វផ្សាយ និងសហគមន៍។ ជាក់ស្តែង វាអាចប្រើប្រាស់ជាឧបករណ៍សម្រាប់ការពិភាក្សាចាប់ពីកម្រិតមត្តេយ្យសិក្សាដល់សកលវិទ្យាល័យ។ វាពិតជាបានផ្តោតលើរបៀបវារៈនៃការប្រែប្រួលអាកាសធាតុនៅកម្ពុជា ប៉ុន្តែមិនបានចែងជាក់លាក់អំពីការប្រឈមនៅក្នុងតំបន់ឆ្នេរ និងតម្រូវការបន្សាំឡើយ។ វាមានលក្ខណៈសមស្របសម្រាប់ការកែសម្រួលដើម្បីប្រើប្រាស់នៅក្នុងតំបន់ឆ្នេរដោយអាចរួមបញ្ចូលប្រធានបទ ដែលពាក់ព័ន្ធនឹងរបៀបវារៈតំបន់ឆ្នេរ សម្រាប់ការត្រៀមបង្ការ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។

## គោលបំណងនៃសកម្មភាព

សកម្មភាពដូចតទៅនេះត្រូវបានស្នើឡើងនៅក្រោម CARP:

- ការកែសម្រួលផ្ទាំងរូបភាពដើម្បីបន្ថែមតំបន់ឆ្នេរ ដូចជាកំណើនកំពស់ទឹកសមុទ្រ សំណឹកតំបន់ឆ្នេរ និងពាមសមុទ្រ ការជ្រាបចូលនៃទឹកប្រៃ ទីជម្រក ព្រៃកោងកាង ស្មៅសមុទ្រ និងផ្កាថ្ម និងអាចរួមបញ្ចូល ហេដ្ឋារចនាសម្ព័ន្ធតំបន់ឆ្នេរផងដែរ។ (ឱនភាពដីធ្លីនិងប្រព័ន្ធដោះទឹកក្នុងទីក្រុងក៏អាចជាប្រធានបទសម្រាប់រួមបញ្ចូលផងដែរ។ ប្រធានបទពាក់ព័ន្ធបំផុតអំពីទឹកជំនន់ និងខ្យល់ព្យុះមានបញ្ចូលរួចហើយ)។
- រម្លងទំព័រដែលមានស្រាប់ខ្លះៗ ដើម្បីបង្កើតជាសម្ភារៈសមស្របដែលអាចមានត្រឹមប្រមាណ២៤ទំព័រ។
- ការរៀបចំឯកសារសម្រាប់ចែកដល់សិក្ខាកាមចំនួនបីឈុត ដែលឆ្លុះបញ្ចាំងអំពីទំព័រខាងក្រោយនៃផ្ទាំងរូបភាព និងទាក់ទងជិតស្និទ្ធជាមួយទំព័រនីមួយៗនៃផ្ទាំងរូបភាព។ កំណត់សំគាល់ពិស្តារមួយឈុតជាភាសាខ្មែរ មួយឈុតជាភាសាអង់គ្លេស និងមួយឈុតសង្ខេបជាភាសាខ្មែរ។
- ការបណ្តុះបណ្តាលគ្រូបង្គោលពីក្រុមការងារថ្នាក់ខេត្ត (២វគ្គមួយវគ្គសម្រាប់ខេត្តគោលដៅនីមួយៗ) ដោយផ្អែកលើសំណៅដំបូងនៃផ្ទាំងរូបភាពដែលបានកែសម្រួល។

- សាកល្បងការអនុវត្តនៅថ្នាក់ឃុំ/ភូមិ (៤វគ្គចំនួន២វគ្គក្នុងខេត្តគោលដៅនីមួយៗ) ដោយទទួលយកយោបល់តបពីសិក្ខាកាម និងគ្រូបង្គោល។
- កែសម្រួលសម្ភារៈនេះ (អាចជាសំខាន់គឺឯកសារសម្រាប់ការចែកជូនជាងផ្ទាំងរូបភាពផ្ទាល់)។
- ការបោះពុម្ពផ្ទាំងរូបភាពចំនួន៥០ឈុត
- ការវាយតម្លៃ និងធ្វើរបាយការណ៍។

## គោលបំណង

ការបណ្តុះបណ្តាលគ្រូបង្គោល និងវគ្គសាកល្បងមានបំណងសម្រេចបាន៖

> "ការយល់ដឹងប្រសើរជាងមុនអំពីការប្រឈមនានា ដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ និងជម្រើសនានានៅក្នុងបរិបទនៃតំបន់ឆ្នេរ ជាពិសេសក្នុងចំណោមក្រុមការងារថ្នាក់ខេត្ត និងបន្ទាប់មកក្នុងចំណោមសហគមន៍មូលដ្ឋាន"។

គោលបំណងរួមគឺបង្កើត៖

> "គំរូមួយនៃការអប់រំ និងកសាងការយល់ដឹងក្នុងចំណោមសហគមន៍សម្រាប់បរិបទជាក់លាក់ ដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ ដែលចំណាយតិច និងដែលសមស្របសម្រាប់ការអនុវត្តដោយក្រុមការងារថ្នាក់ខេត្ត"។

## ការអនុវត្ត

ការរៀបចំកែសម្រួលផ្ទាំងរូបភាព និងឯកសារសម្រាប់ចែកដល់សិក្ខាកាមនឹងត្រូវអនុវត្តដោយអង្គការសង្គ្រោះសត្វព្រៃកម្ពុជា ក្រោមការពិគ្រោះយោបល់ជាមួយក្រុមការងារថ្នាក់ខេត្ត និងជាមួយការគាំទ្របច្ចេកទេសពីក្រុមអ្នកជំនួយការបច្ចេកទេស។ ក្នុងន័យនេះការបង្កើយសម្ភារៈនេះនឹងត្រូវការឲ្យមានការពិភាក្សានៅក្នុងវគ្គបណ្តុះបណ្តាលគ្រូបង្គោល។ ការបណ្តុះបណ្តាលគ្រូបង្គោល(ពីក្រុមការងារថ្នាក់ខេត្ត)នឹងធ្វើឡើងដោយអង្គការសង្គ្រោះសត្វព្រៃ ដែលចូលរួមផងដែរនៅក្នុងការអនុវត្តសាកល្បងដំបូង។ ក្រុមការងារថ្នាក់ខេត្តនឹងអនុវត្តកិច្ចការនេះជាបន្តនៅតាមឃុំនានា។

ជំហានបន្ទាប់អាចចែកចេញជា៖

១ ការអនុម័តជាផ្លូវការលើសកម្មភាពនេះ
២ ការព្រមព្រៀងជាមួយអង្គការសង្គ្រោះសត្វព្រៃអំពីវិភាគទានរបស់អង្គការនេះ
៣ ការកសាងផែនការពិស្តារ
៤ ការកែលម្អផ្ទាំងរូបភាព និងសេចក្តីព្រាងឯកសារសម្រាប់ចែកជូនសិក្ខាកាម
៥ ការបណ្តុះបណ្តាលគ្រូបង្គោលទន្ទឹមនឹងការអនុវត្តសាកល្បងនៅថ្នាក់ឃុំ
៦ ការកែសម្រួលឯកសារសម្រាប់ចែកជូនសិក្ខាកាម (និងបើចាំបាច់ផ្ទាំងរូបភាពផងដែរ)
៧ ការផលិត និងផ្សព្វផ្សាយផ្ទាំងរូបភាព និងឯកសារសម្រាប់សិក្ខាកាម
៨ ការវាយតម្លៃ និងរាយការណ៍

## ៧.២ ការពង្រឹងគណៈកម្មការសហគមន៍កសិករប្រើប្រាស់ទឹក

### តម្រូវការបណ្តុះបណ្តាល

តម្រូវការបណ្តុះបណ្តាលត្រូវបានកំណត់ និងវាយតម្លៃនៅក្នុងការពិគ្រោះយោបល់នៅក្រោម CARP ក្នុងខែឧសភា និងមិថុនា ឆ្នាំ២០១២។ តម្រូវការដែលកំណត់ឃើញទាំងនោះគឺ៖

- ការបែងចែកទឹក និងការគ្រប់គ្រងលើការធ្វើវិភាជន៍ទឹក
- ប្រតិបត្តិការ និងការគ្រប់គ្រងប្រព័ន្ធស្រោចស្រព
- ការដោះទឹក និងការត្រួតពិនិត្យកម្រិតប្រៃ
- ទឹកស្អាត និងអនាម័យ
- ការគ្រប់គ្រងដី
- ការដាំដើមឈើ (សម្រាប់ការពារទល់នឹងខ្យល់ព្យុះ និងអត្ថប្រយោជន៍ផ្សេងទៀត)
- ការត្រៀមបង្ការ៖ ទឹកជំនន់ និងខ្យល់ព្យុះ
- ការពិនិត្យតាមដានតាមបែបចូលរួមលើភាពងាយរងគ្រោះ និងការរងឥទ្ធិពលពីអាកាសធាតុ
- ការត្រៀមបង្ការគ្រោះរាំងស្ងួត (មិនជាបញ្ហាទេបច្ចុប្បន្ន ប៉ុន្តែនៅពុំទាន់មានការត្រៀមបង្ការ និងអាចមានបញ្ហានេះកើតឡើងទៅអនាគត)
- ការជ្រើសរើសពូជ ដែលរួមទាំង ពូជស្រូវសាល និងដែលផ្តល់ទិន្នផលខ្ពស់
- ការប្តូរពីការធ្វើស្រែមួយឆ្នាំ ទៅពីរដងក្នុងមួយឆ្នាំ
- ការប្រើប្រាស់ថ្នាំគីមីកសិកម្ម និងជីគីមី
- ការចិញ្ចឹមសត្វ វារីវប្បកម្ម។ នៅក្នុងតំបន់សាកល្បង កសិករខ្លះបានទទួលជោគជ័យ ចំណែកអ្នកដទៃទៀតមិនសូវជោគជ័យឡើយ។ ដូច្នេះ គួរតែមានការរៀនសូត្រពីគ្នាទៅវិញទៅមក
- ការដាំដំណាំបំពេញបន្ថែមខ្នាតតូចនៅរដូវប្រាំង
- ការកែច្នៃនៅក្រោយប្រមូលផល និងការលក់ផលិតផល
- ការទទួលបានឥណទាន/ការសន្សំ/ការធានារ៉ាប់រង។

តម្រូវការទាំងអស់ខាងលើមានការទាក់ទងគ្នាជាមួយភាពធន់/ការបន្សាំនឹងអាកាសធាតុ ខ្លះទាក់ទងដោយផ្ទាល់ និងខ្លះទៀតដោយប្រយោល។ មានតែតម្រូវការមួយចំនួន(អាទិភាព) នឹងអាចរួមបញ្ចូលនៅក្នុងវគ្គបណ្តុះបណ្តាលដែលសាកល្បងសម្រាប់ការសិក្សានេះ ដូចមានចែងពិស្តារខាងក្រោម។ គណៈកម្មការសហគមន៍កសិករប្រើប្រាស់ទឹកមានដំណើរការបានល្អ ទោះគិតតាមស្តង់ដារណាក៏ដោយ (និងធៀបជាមួយគណៈកម្មាការសហគមន៍កសិករប្រើប្រាស់ទឹកដទៃទៀតជាច្រើននៅកម្ពុជា)។ គណៈកម្មការនេះពុំត្រូវការវគ្គបណ្តុះបណ្តាលជាមូលដ្ឋានឡើយ។

### ទិដ្ឋភាពរួមនៃសកម្មភាពដែលស្នើឡើង

សកម្មភាពដាច់គ្នាចំនួនពីរត្រូវបានស្នើឡើង៖

- វគ្គបណ្តុះបណ្តាលសាកល្បងចំនួនពីរសម្រាប់គណៈកម្មការសហគមន៍កសិករប្រើប្រាស់ទឹក មួយវគ្គនៅក្នុងខេត្តនីមួយៗ ដែលវគ្គនីមួយៗមានរយៈពេល ៣ថ្ងៃ និងមានសមាជិកចូលរួម ១៨នាក់ នៅក្នុងវគ្គ

នីមួយៗ។ នៅក្នុងវគ្គនេះមានការបង្ហាញត្រួសៗអំពីកង្វល់នៃការប្រែប្រួលអាកាសធាតុ និងជម្រើសគ្រប់គ្រង និងពេលមួយថ្ងៃសម្រាប់ការចុះទស្សនកិច្ចតាមភូមិសាស្ត្រ។

- ទស្សនកិច្ចសិក្សានៅដែនដីសណ្តរគួឡុង ដែលមានសមាជិកចូលរួម ២៤នាក់ (១៦នាក់ជាបុគ្គលិកពីរដ្ឋាភិបាល និង៨នាក់ជាតំណាងគណៈកម្មការសហគមន៍កសិករប្រើប្រាស់ទឹក) និងទស្សនកិច្ចតំណាងពីដែនដីសណ្តរមកវិញចំនួន ៨ នាក់។

## គោលបំណង

វគ្គបណ្តុះបណ្តាលសាកល្បងនេះមានគោលបំណង៖

"បង្កើនការយល់ដឹង និងចំណេះដឹងអំពីការប្រឈមនានា និងជម្រើសដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ នៅក្នុងការគ្រប់គ្រងប្រព័ន្ធស្រោចស្រព និងបច្ចេកវិទ្យាដាំដំណាំដែលធន់នឹងការប្រែប្រួលអាកាសធាតុ"។

គោលបំណងរួមនៃវគ្គនេះគឺបង្កើត៖

"គំរូមួយនៃការបណ្តុះបណ្តាលគណៈកម្មការសហគមន៍កសិករប្រើប្រាស់ទឹក សម្រាប់បរិបទជាក់លាក់ដែលចំណាយតិច ដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ និងដែលសមស្របសម្រាប់ការអនុវត្តដោយក្រុមការងារថ្នាក់ខេត្ត"។

## ការផ្លាស់ប្តូរទស្សនកិច្ចសិក្សា

សកម្មភាពនេះមានគោលបំណងស្វែងយល់អំពីបច្ចេកវិទ្យាដែលអនុវត្តបានជោគជ័យ និងជម្រើសគ្រប់គ្រងដែលទាក់ទងនឹង៖

"ការត្រួតពិនិត្យកម្រិតប្រៃនៅតាមស្រែ និងការដាំដំណាំដែលផ្តល់ទិន្នផលខ្ពស់ឲ្យបានពីរ (បី)ដងក្នុងមួយឆ្នាំ នៅក្នុងលក្ខខណ្ឌបរិស្ថានដែលប្រហែលគ្នានឹងតំបន់គោលដៅនៃ CARP"។

គោលបំណងរួមគឺ៖

"ពង្រឹងសមត្ថភាពក្រុមការងារថ្នាក់ខេត្ត មន្ទីរពាក់ព័ន្ធតាមខេត្ត និងការិយាល័យរដ្ឋាភិបាលដើម្បីបំពេញតាមតម្រូវការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមដែលទាក់ទងនឹងអាកាសធាតុ និងឱកាសដែលបានពីប្រព័ន្ធផលិតកម្ម និងហេដ្ឋារចនាសម្ព័ន្ធដែលធន់នឹងអាកាសធាតុ"។

នៅទីនេះ មានការរំពឹងថា ការផ្លាស់ប្តូរទស្សនកិច្ចសិក្សា អាចបន្ថែមលើមូលដ្ឋានសម្រាប់ការកសាងផែនការអភិវឌ្ឍន៍នៅថ្នាក់ក្រោមជាតិ។

## ទម្រង់រួមនៃវគ្គបណ្តុះបណ្តាល

ការធ្វើស្រែនៅក្នុងតំបន់សាកល្បង នៅក្នុងដំណាក់កាលអន្តរកាល នៃការសាកល្បងដោយកសិករដែលជាសហគ្រិន អំពីការប្រើប្រាស់ពូជស្រូវធ្ងន់តាមប្រពៃណីដែលផ្តល់ទិន្នផលទាប(ប៉ុន្តែឆ្ងាញ់) និងធ្វើស្រែតែម្តងក្នុងមួយឆ្នាំ ទៅរកវិធីថ្មីដែលប្រើពូជស្រូវស្រាល(និងធន់ចំពោះអាកាសធាតុ) និងផ្តល់ទិន្នផលខ្ពស់។ បទពិសោធន៍ភាគច្រើនគឺបានមកពីតំបន់នានាក្នុងផ្ទៃប្រទេស ដែលមានលក្ខខណ្ឌខុសគ្នា។ អន្តរកាលនេះអាច

គាំទ្រដោយការផ្លាស់ប្តូរចំណេះដឹងពីកន្លែងដទៃ ក៏ដូចជា នៅក្នុងតំបន់អនុវត្តសាកល្បងផងដែរ។ ផ្អែកលើសាវតានេះ ហេតុផលនៃវគ្គបណ្តុះបណ្តាលនេះគឺការរៀនសូត្រពីគ្នាទៅវិញទៅមក ការផ្លាស់ប្តូរបទពិសោធន៍និងគំនិតនានា រវាង និងក្នុងចំណោមកសិករ និងសមាជិកក្រុមការងារថ្នាក់ខេត្ត។

កម្មវិធីដែលមានរយៈពេល ៣ថ្ងៃ ត្រូវបានស្នើឡើង៖

ថ្ងៃទី១ ៖ សេចក្តីផ្តើម, បទអន្តរាគមន៍ខ្លីដោយមន្ទីរនានាតាមខេត្ត, គណៈកម្មការសហគមន៍កសិករប្រើប្រាស់ទឹកព្រៃនប់, CARDI និងទីប្រឹក្សាជំនួយបច្ចេកទេស ពិសារបាយសាមគ្គីនៅពេលល្ងាច

ថ្ងៃទី២ ៖ ទស្សនកិច្ចស្រែដែលមានប្រព័ន្ធស្រោចស្រព/FWUCs/សមាគមកសិករ នៅក្នុងខេត្តនីមួយៗ ដែលរួមទាំង ប៉ូលឌែរព្រៃនប់ និង (រំពឹងថា)ទួលគគីរផងដែរ

ថ្ងៃទី៣ ៖ ការពិភាក្សាដោយមានវាគ្មិនជាអ្នកជំនាញ និងការពិភាក្សាពេញអង្គ ការសន្និដ្ឋាន និងអនុសាសន៍។

វគ្គបណ្តុះបណ្តាលសាកល្បងនេះ គឺជាចំណុចចាប់ផ្តើមសម្រាប់ការពង្រីកទៅអនុវត្តនៅកន្លែងដទៃ។ ការអង្កេតដើម្បីទទួលយោបល់តប នឹងត្រូវអនុវត្ត សម្រាប់ការកែលម្អបន្ថែម។

## ទិដ្ឋភាពរួមនៃការផ្លាស់ប្តូរទស្សនកិច្ចសិក្សា

ដែនដីសណ្តរគូឡុង ស្ថិតនៅចម្ងាយប្រមាណ ២០០-៣០០គ.ម ពីតំបន់គោលដៅនេះ។ តំបន់នោះរងឥទ្ធិពលពីការជ្រាបចូលនៃទឹកប្រៃទៅតាមរដូវ (រដូវប្រាំង) ដែលធ្វើឲ្យប៉ះពាល់ដល់ការស្រោចស្រព និងការផ្គត់ផ្គង់ទឹកតាមទីក្រុង។ ទោះជាយ៉ាងណាក៏ដោយ មានការដាំដំណាំយ៉ាងច្រើននៅក្នុងដែនដីសណ្តរ ដោយទិន្នផលស្រូវមានប្រមាណ ៤ត/ហ.ត នៅក្នុងរដូវវស្សា និង ៦ត/ហ.ត នៅរដូវប្រាំង ស្របជាមួយឈើហូបផ្លែ និងវារីវប្បកម្ម។ ការប្រឈមថ្មីដែលទាក់ទងនឹងអាកាសធាតុចំពោះកសិករនៅក្នុងតំបន់ឆ្នេរប្រទេសកម្ពុជា ក៏ជាអ្វីដែលបានកើតឡើងនៅដែនដីសណ្តរគូឡុងផងដែរ (ដែនដីសណ្តរក្នុងប្រទេសវៀតណាម) ត្រង់ចំណុចទន្លេមេគង្គជួបនឹងសមុទ្រ។ ជាច្រើនទសវត្សរ៍កន្លងមកនេះ បទពិសោធន៍នានាត្រូវបានបង្កើតឡើង ទាក់ទងនឹងការត្រួតពិនិត្យកម្រិតប្រៃ ការគ្រប់គ្រងគុណភាពដី និងប្រព័ន្ធផលិតកម្មក្នុងតំបន់ទឹកភ្លាវ ក្រៅពីការធ្វើស្រែ។ បច្ចេកវិទ្យាត្រូវបានបន្សាំជាមួយការគាំទ្រពីសហគមន៍អ្នកវិទ្យាសាស្ត្រ និងវិទ្យាស្ថានសេវាកម្មបច្ចេកវិទ្យានៃរដ្ឋាភិបាល។

សម្រាប់គោលបំណងនៃតំបន់ឆ្នេរក្នុងប្រទេសកម្ពុជា ការសិក្សាស្វែងយល់ពីបទពិសោធន៍នេះពិតជាមានប្រយោជន៍។ ក្នុងន័យនេះ ទស្សនកិច្ចសិក្សាមួយ និងទស្សនកិច្ចត្រឡប់មកវិញត្រូវបានស្នើឡើង៖

- ទស្សនកិច្ចមួយរយៈពេល៤ថ្ងៃ ដោយតំណាងនានា មកពីមន្ទីរវិស័យតាមខេត្ត និងការិយាល័យអភិបាល និងតំណាងមួយចំនួនពីគណៈកម្មការសហគមន៍កសិករប្រើប្រាស់ទឹក។
- ទស្សនកិច្ចត្រឡប់មកវិញនៃតំណាងអ្នកជំនាញការពីវៀតណាម ដើម្បីពិនិត្យមើល និងបង្ហាញចំណាប់អារម្មណ៍ និងមេរៀនដែលទទួលបានពីស្ថានភាពនៃការអភិវឌ្ឍន៍នៅកម្ពុជា ។

## ការអនុវត្ត

សកម្មភាពនានានឹងត្រូវអនុវត្តដោយក្រុមការងារថ្នាក់ខេត្ត ជាមួយការគាំទ្រដំបូងពី CARP។ មានការរំពឹងថា នឹងមានការចូលរួមយ៉ាងសកម្មពី៖

- មន្ទីរបរិស្ថានខេត្ត (ដែលពាក់ព័ន្ធក្នុងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ)
- មន្ទីរកសិកម្ម (ដែលពាក់ព័ន្ធខាងបច្ចេកវិទ្យាដាំដំណាំ)
- មន្ទីរធនធានទឹក និងឧតុនិយម (ដែលពាក់ព័ន្ធនឹងប្រតិបត្តិការប្រព័ន្ធស្រោចស្រព)
- ការិយាល័យអភិបាលខេត្ត
- គណៈកម្មការសហគមន៍កសិករប្រើប្រាស់ទឹកព្រៃនប់
- CARDI
- អាចរួមទាំង តំណាងពីម្ចាស់ម៉ាស៊ីនស្រូវផងដែរ។

នៅវៀតណាមះ

- វិទ្យាស្ថានកសាងផែនការធនធានទឹកភាគខាងត្បូង (SIWRP) និង/ឬ វិទ្យាស្ថានស្រាវជ្រាវធនធានទឹកភាគខាងត្បូង (SIWRR); និង/ឬ
- សាកលវិទ្យាល័យខេនធ័រះ មហាវិទ្យាល័យកសិកម្ម និង/ឬមហាវិទ្យាល័យបច្ចេកវិទ្យា

ជំហានបន្ទាប់អាចរាប់បញ្ចូលះ

១ ការអនុម័តជាផ្លូវការលើសកម្មភាពនេះ
២ ការព្រមព្រៀងជាមួយដៃគូអនុវត្ត/អ្នកជំនាញការ
៣ ទស្សនកិច្ចត្រៀមរៀបចំនៅក្នុងខេត្តនីមួយៗ
៤ ការកំណត់អត្តសញ្ញាណសិក្ខាកាម (រួមគ្នាជាមួយក្រុមការងារថ្នាក់ខេត្ត/មន្ទីរតាមខេត្ត)
៥ ការអនុវត្ត
៦ ការវាយតម្លៃ និងរាយការណ៍
៧ សកម្មភាពពាក់ព័ន្ធ

សកម្មភាពដែលបានលើកស្នើនេះទាក់ទងនឹង (នឹងជាការបំពេញបន្ថែម និងបន្ថែមគុណតម្លៃដល់) កិច្ចផ្តួចផ្តើមអភិវឌ្ឍនសមត្ថភាពដទៃទៀតដែលទាក់ទងនឹងអាកាសធាតុ (នៅក្នុងការរៀបចំ)នៅក្រោម CARP និងបន្តនៅពេលក្រោយ ក្នុងគោលដៅពង្រឹងសមត្ថភាពជាទូទៅសម្រាប់មន្ទីរនានាតាមខេត្ត និងការិយាល័យអភិបាលខេត្ត និងជាពិសេសក្រុមការងារថ្នាក់ខេត្ត ក៏ដូចជាបង្កើតការយល់ដឹងនៅកម្រិតសហគមន៍ និងនៅកម្រិតកសិដ្ឋានអំពីការប្រឈម និងជម្រើសបន្សាំដែលទាក់ទងនឹងអាកាសធាតុផងដែរ។

សំណើសកម្មភាពសាកល្បងអប់រំ និងបង្កើតការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុ មានភាពសមស្របសម្រាប់ការពង្រីកទៅអនុវត្តនៅកន្លែងផ្សេង (ដោយក្រុមការងារថ្នាក់ខេត្ត) មិនត្រឹមតែនៅក្រោម CARP ឡើយ។ ជាបន្តបន្ទាប់ សកម្មភាពទាំងនេះអាចពង្រីកដល់សាលារៀនផងដែរ។

# ៨. ផែនការអនុវត្តសម្រាប់សកម្មភាពបង្ហាញ

ជំពូកនេះរៀបរាប់ដោយត្រួសៗអំពីផែនការអនុវត្តសម្រាប់សកម្មភាពបង្ហាញដែលស្នើឡើងចំនួនប្រាំមួយនៅក្រោមសមាសភាគ CARP។

ព័ត៌មានពិស្តារអំពីផែនការអនុវត្តមាននៅក្នុងរបាយការណ៍ "ផែនការអនុវត្តពិស្តារសម្រាប់សកម្មភាពបង្ហាញនៅឆ្នេរសមុទ្រ" ខែ មីនា ឆ្នាំ ២០១៣ ដែលអាចចម្លងចេញពីវេបសាយ CARP (www.czmcam.org)។

ជាផ្នែកមួយដំណើរការជ្រើសរើស សកម្មភាពបង្ហាញត្រូវបានបង្ហាញជូននៅក្នុងខែកញ្ញា-ធ្នូ ដល់ក្រុមការងារបច្ចេកទេសនិងក្រុមប្រឹក្សាឃុំនៅក្នុងសិក្ខាសាលាជាបន្តបន្ទាប់នៅខេត្តកោះកុង និងព្រះសីហនុ។ យោបល់តប បានទទួលតាមរយៈការពិគ្រោះយោបល់ទាំងនេះ ដែលទាក់ទងនឹងចំណាត់អាទិភាពសកម្មភាពអនុវត្តបង្ហាញដែលបានលើកស្នើនៅក្នុងសហគមន៍គោលដៅ។ ផ្អែកតាមលទ្ធផលនេះ ការងារបន្ថែមគឺការបម្លែងសកម្មភាពទៅជាគម្រោងជាក់លាក់ ដែលរួមទាំង ថវិកា និងផែនការអនុវត្តផងដែរ។

## ៨.១ តារាងសកម្មភាពអនុវត្តបង្ហាញ

សកម្មភាពអនុវត្តបង្ហាញទាំងប្រាំមួយដែលបានលើកស្នើអនុវត្តមានដូចតទៅះ

១. កម្មវិធីបណ្តុះបណ្តាលអំពីកសិកម្មចម្រុះដល់ (ក)បុគ្គលិកផ្សព្វផ្សាយកសិកម្ម និង(ខ)គ្រួសារ/ខ្នងផ្ទះអំពីយុទ្ធសាស្ត្របន្សាំនឹងការប្រែប្រួលអាកាសធាតុ និងផលិតកម្មចម្រុះ (ការរួមបញ្ចូលដំណាំ ការចិញ្ចឹមសត្វ ត្រី ទឹក) នៅក្នុងឃុំគោលដៅចំនួន ៨។ មុននេះអាចមានការវិភាគក្សេត្របរិស្ថាន ដែលជាផ្នែករួមមួយ និងរួមបញ្ចូលការអនុវត្តបង្ហាញអំពីវិធានការគ្រប់គ្រងទឹកតាមកសិដ្ឋាន។ សកម្មភាពអនុវត្តបង្ហាញត្រូវបានស្នើឡើងសម្រាប់ការអនុវត្ត ក្រោមភាពជាដៃគូជាមួយនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

២. គម្រោងសហគមន៍នេសាទនៅពាមក្រសោប ជាពិសេស ដើម្បីពង្រឹងវិធានការច្បាប់ និងពង្រឹងការអនុវត្ត។ ទំនាក់ទំនងនៃសហគមន៍នេសាទជាមួយការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុបង្ហាញថា គេទំនងជាត្រូវការនូវការអភិវឌ្ឍជាទូទៅខាងការនេសាទ និងវិធានការច្បាប់ ដើម្បីកែសម្រួលមុខរបររបស់សហគមន៍អ្នកនេសាទ។ សកម្មភាពអនុវត្តបង្ហាញនេះត្រូវបានស្នើឡើងសម្រាប់ការអនុវត្តក្រោមភាពជាដៃគូជាមួយរដ្ឋបាលជលផល នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

៣. ការលើកកំពស់ និងបង្កើនវត្តមានពូជដំណាំដែលធាប់ផ្តល់ផល ជាពិសេស ស្រូវស្រាលរដូវវស្សា អាចសម្រួលដល់ការប្រមូលផលមុនពេលទឹកជំនន់ធំមកដល់ និងការឡើងកំពស់ទឹកសមុទ្រនៅក្នុងឃុំគោលដៅ។ គេត្រូវសាកល្បងពូជដំណាំបែបនេះ(ដោយកសិករមិនមែនជាអ្នកបង់ខាត)នៅក្នុងទីតាំងជាក់លាក់ដែលទំនងជាមានប្រសិទ្ធភាព។ សកម្មភាពអនុវត្តបង្ហាញនេះត្រូវបានស្នើឡើងសម្រាប់ការអនុវត្តក្រោមភាពជាដៃគូជាមួយវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

៤. លើកកំពស់ការចិញ្ចឹមសត្វនៅក្នុងឃុំចំនួន ៥ ដោយប្រើប្រាស់ប្រព័ន្ធទុនបង្វិលសម្រាប់កែលម្អពូជជាបន្តបន្ទាប់ - បានសាកល្បងដោយជោគជ័យនៅកម្ពុជា ឡាវ និងកន្លែងដទៃ។ នេះជាវិធានការឆ្លើយតប ទៅនឹងបញ្ហាទឹកជំនន់ ដោយសារគេអាចចល័តសត្វចិញ្ចឹមបាន។ សកម្មភាពអនុវត្តបង្ហាញនេះត្រូវបានស្នើ

ឡើងសម្រាប់ការអនុវត្តក្រោមភាពជាដៃគូជាមួយ មជ្ឈមណ្ឌលអភិវឌ្ឍន៍សត្វចិញ្ចឹមនិងកសិកម្ម (CelAgrid) ដោយសហការជាមួយអង្គភាពគ្រប់គ្រងគម្រោង នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

៥. ការបង្កើនការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុ ស្តីពីការប្រព័ន្ធស្រោចស្រពដែលធន់នឹងការប្រែប្រួលអាកាសធាតុនៅក្នុងឃុំគោលដៅ។ សកម្មភាពបណ្តុះបណ្តាលនិងបង្កើនការយល់ដឹងទូលំទូលាយមួយទាក់ទងនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ នឹងត្រូវអនុវត្តដោយប្រើប្រាស់បទពិសោធន៍ពីការ-ងារកន្លងមកនៅកម្ពុជា។ ការងារបណ្តុះបណ្តាលនឹងត្រូវអនុវត្តក្នុងឃុំជ្រើសរើសទាំងប្រាំបី។ សកម្មភាពអនុវត្តបង្ហាញនេះត្រូវបានស្នើឡើងតាមរយៈកិច្ចសហប្រតិបត្តិការជាមួយអង្គការមិនមែនរដ្ឋាភិបាល និងក្រុមការងារថ្នាក់ខេត្តដែលបានបង្កើតរួចមកហើយ ដែលនឹងរ៉ាប់រងការទទួលខុសត្រូវលើការអនុវត្ត។

៦. វិធានការបន្សាំត្រូវបានដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍ឃុំនៅក្នុងឃុំចំនួនប្រាំបី។ សកម្មភាពអនុវត្តបង្ហាញជាក់លាក់ នឹងត្រូវអនុវត្តនៅក្នុងឃុំគោលដៅនីមួយៗ ដោយផ្អែកលើសកម្មភាពគ្រោងទុកនៅក្នុងផែនការវិនិយោគឃុំឆ្នាំ ២០១៣ និងការអនុវត្តសកម្មភាពដែលនឹងធ្វើឲ្យឃុំកាន់តែមានភាពធន់នឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ សកម្មភាពអនុវត្តបង្ហាញនឹងធ្វើឡើងក្រោមកិច្ចសហប្រតិបត្តិការជាមួយក្រុមប្រឹក្សាឃុំ និងក្រុមការងារថ្នាក់ខេត្ត។

សកម្មភាពភាគច្រើនត្រូវអនុវត្តនៅក្នុងឆ្នាំ ២០១៣ ប៉ុន្តែសកម្មភាព ៤ នឹងត្រូវការរយៈពេល ៣ឆ្នាំដើម្បីអនុវត្ត ប៉ុន្តែផ្នែកចំបងត្រូវអនុវត្តនៅឆ្នាំ ២០១៣។ បន្ថែមលើនេះ ចាំបាច់ត្រូវអនុវត្តសកម្មភាពបន្តនៅក្នុងឆ្នាំ២០១៤-១៥។ មានការលើកស្នើថា សកម្មភាពបន្តបែបនេះអាចអនុវត្តនៅក្រោមផ្នែកLDCF-GEF នៃគម្រោងបន្សាំក្នុងតំបន់ឆ្នេរ ប្រសិនបើអាចធ្វើបាន។

សាវតា និងមូលដ្ឋានសម្រាប់សកម្មភាពបង្ហាញបានផ្អែកលើសកម្មភាព និងកិច្ចប្រឹងប្រែងនានាដែលមានសង្ខេបក្នុងរបាយការណ៍នេះ។

សេចក្តីព្រាងផែនការអនុវត្ត និងសេចក្តីព្រាងកិច្ចព្រមព្រៀងត្រូវបានបង្កើតឡើងនៅក្នុងអំឡុងថ្ងៃ ១-១៥ ខែធ្នូ ឆ្នាំ២០១២ និងបានបញ្ចប់នៅដើមឆ្នាំ ២០១៣ ដោយក្រុមអនុវត្តគម្រោង ក្រោមការពិគ្រោះយោបល់ជាមួយដៃគូអនុវត្ត (DAE, FiA, CARDI និង CelAgrid) និងផ្អែកលើការពិគ្រោះយោបល់មួយចំនួនជាមួយសហគមន៍ និងក្រុមការងារនានាដែលពាក់ព័ន្ធ។

## ៨.២ អាទិភាពសម្រាប់សកម្មភាពអនុវត្តបង្ហាញនៅតាមឃុំនានា

នៅក្នុងអំឡុងខែកញ្ញា-វិច្ឆិកា ឆ្នាំ២០១២ សមាសភាគCARP បានចាត់ចែងកិច្ចប្រជុំជាមួយអ្នកពាក់ព័ន្ធនានាក្នុងសហគមន៍ ដើម្បីបង្កើតអាទិភាពសកម្មភាពបង្ហាញសម្រាប់ឃុំជ្រើសរើសមួយចំនួននៅស្រុកមណ្ឌលសីមា និងព្រៃនប់។ កិច្ចប្រជុំទាំងនេះ រាប់បញ្ចូលការពិភាក្សានានាជាមួយក្រុមការងារថ្នាក់ខេត្ត ដែលរួម ទាំងប្រធានឃុំនៃឃុំគោលដៅទាំង ៨ ផងដែរ។

មុនកិច្ចប្រជុំអ្នកពាក់ព័ន្ធនានា CARP បានសិក្សាទិន្នន័យ និងអំពីមូលដ្ឋាននៃការវាយតម្លៃតម្រូវការដែលបានបង្កើតជាតារាងមួយអំពីសកម្មភាពអនុវត្តបង្ហាញដែលមានសក្តានុពល។ តាមរយៈបញ្ជីសំណួរមិនផ្លូវការមួយ ទិន្នន័យត្រូវបានទទួលតាមរយៈការពិភាក្សាជាក្រុមដោយមានការសម្រួលជាមួយសមាជិក

សហគមន៍ ពោលគឺ តំណាងនានានៃក្រុមប្រឹក្សាឃុំ និងគណៈកម្មការសហគមន៍។ ព័ត៌មានត្រូវបានប្រមូលតាមប្រធានបទនានាដូចតទៅ៖

- ផលប៉ះពាល់ធ្ងន់ធ្ងរបំផុតនៃអាកាសធាតុ
- ប្រភពប្រាក់ចំណូលប្រចាំគ្រួសារ
- អនុសាសន៍សម្រាប់ការកែប្រែទម្លាប់ធ្វើកសិកម្ម
- អនុសាសន៍សម្រាប់សកម្មភាពអនុវត្តបង្ហាញទៅអនាគត

ក្រោយបានប្រមូលទិន្នន័យទាំងអស់រួចមក CARP បានកំណត់សកម្មភាពអនុវត្តបង្ហាញដែលមានសក្តានុពល។ នៅក្នុងពេលប្រជុំ ខែកញ្ញា-វិច្ឆិកា អ្នកពាក់ព័ន្ធទាំងអស់ត្រូវបានស្នើឲ្យចាត់សកម្មភាពនីមួយៗក្នុងចំណោមសកម្មភាពទាំង ២០ ជាអាទិភាព។ ប្រធានឃុំគោលដៅបានធ្វើការចាត់អាទិភាពសកម្មភាពទាំងនោះទៅតាមអាទិភាពនៃឃុំរៀងៗខ្លួន។

ចំពោះតារាងសកម្មភាពអនុវត្តបង្ហាញដែលមានសក្តានុពល និងចំណាត់លំដាប់ថ្នាក់ សូមយោងទៅជំពូក ២ នៃរបាយការណ៍ "ផែនការអនុវត្តពិស្តារសម្រាប់សកម្មភាពបង្ហាញនៅក្នុងឆ្នេរសមុទ្រ" ខែមីនា ឆ្នាំ២០១៣

# ៩. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

ជំពូកនេះបង្ហាញពីទិដ្ឋភាពរួមនៃការប្រឈមនានា និងឱកាសដើម្បីពង្រឹងសមត្ថភាពបន្សាំក្នុងចំណោមសហគមន៍គោលដៅនៅក្នុងតំបន់ឆ្នេរ និងអាជ្ញាធររដ្ឋាភិបាលនៅថ្នាក់ជាតិ និងមូលដ្ឋាន ដើម្បីដោះស្រាយឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ។ ដូច្នេះ មានការបូកសរុបសេចក្តីសន្និដ្ឋាននានា និងអនុសាសន៍ដែលស្នើឡើងសម្រាប់សកម្មភាពនៅក្នុងជំពូកនីមួយៗ។

## ការពង្រឹងយុទ្ធសាស្ត្រទប់ទល់

ការប្រឈមចំបងៗដូចតទៅត្រូវបានកំណត់អត្តសញ្ញាណ៖

- កសាង និងថែទាំប្រព័ន្ធទំនប់ ជាយុទ្ធសាស្ត្រទប់ទល់ ត្រូវបានរារាំងដោយសារកង្វះធនធានហិរញ្ញវត្ថុ និងសមត្ថភាពបច្ចេកទេសកម្រិតទាប។
- រចនាសម្ព័ន្ធទូទៅមួយដើម្បីគាំទ្រដល់យុទ្ធសាស្ត្រទប់ទល់កម្រិតបុគ្គល និងសហគមន៍មិនទាន់មានអនុវត្ត
- គ្មានប្រព័ន្ធសម្រាប់ចែករំលែកព័ត៌មានរវាងអ្នកពាក់ព័ន្ធនានា។
- អ្នកភូមិយល់ថា ការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់របស់វា ទាក់ទងនឹងបរិស្ថាននៅមូលដ្ឋាន។ ពួកគេពុំយល់អំពីការប្រែប្រួលអាកាសធាតុ នៅក្នុងបរិបទពិភពលោកឡើយ ដែលបង្កជាហានិភ័យនៃការអនុវត្តគម្រោងដែលមិនត្រឹមតែមិនមែនជាគម្រោងប្រែប្រួលអាកាសធាតុ ប៉ុន្តែថែមទាំងគម្រោងអភិវឌ្ឍន៍ដទៃផ្សេងទៀតផងដែរ។

អនុសាសន៍ដូចតទៅត្រូវបានលើកស្នើ៖

- ស្វែងរកមូលនិធិសម្រាប់កសាង និងកែលម្អប្រព័ន្ធទំនប់ និងពង្រឹងសមត្ថភាពបច្ចេកទេស ដើម្បីអភិវឌ្ឍន៍ប្រព័ន្ធទាំងនេះ នៅកម្រិតស្ថាប័ន

- អភិវឌ្ឍន៍សមត្ថភាពចាត់ចែងនៅកម្រិតសហគមន៍ មុននឹងអភិវឌ្ឍន៍សមត្ថភាពបច្ចេកទេសនៅក្នុងសហគមន៍គោលដៅ។ រចនាសម្ព័ន្ធបែបនេះត្រូវតែមានតម្លាភាព ដើម្បីធានាឲ្យមានការប្រាស្រ័យទាក់ទង និងការផ្ទេរបច្ចេកវិទ្យាបានប្រសើរជាងមុន រវាងរាជរដ្ឋាភិបាលកម្ពុជា អ្នកផ្តល់សេវាអភិវឌ្ឍន៍ផ្សេងទៀត និងអ្នកភូមិនៅក្នុងឃុំគោលដៅ។

- បង្កើតប្រព័ន្ធមួយដើម្បីធានាថា ព័ត៌មានដែលពាក់ព័ន្ធត្រូវបានបញ្ជូនពីអ្នកភូមិទៅអាជ្ញាធរ និងត្រឡប់មកវិញមុននឹងមុខសញ្ញាមហន្តរាយធាតុអាកាសកើតឡើងនៅក្នុងពេលនៃការប៉ះពាល់របស់វា និងនៅក្រោយពេលកើតឡើង និងរួមបញ្ចូលប្រព័ន្ធនេះទៅក្នុងផែនការវិនិយោគឃុំ។

- អនុវត្តសកម្មភាពបង្កើតការយល់ដឹងដែលសង្កត់ធ្ងន់ពីចំណងទាក់ទងរវាងយុទ្ធសាស្ត្រទប់ទល់សម្រាប់អថេរអាកាសធាតុ និងផលប៉ះពាល់របស់វា និងបញ្ហាអភិវឌ្ឍន៍ដទៃទៀត។ សម្ភារៈអប់រំគួរតែបានរៀបចំឡើងដោយផ្អែកលើគំរូពីរបែប (១) កាតាឡុកយុទ្ធសាស្ត្រទប់ទល់ដែលមានបង្ហាញពីយុទ្ធសាស្ត្រទប់ទល់ដែលបានរៀបចំឡើងនៅក្នុងសហគមន៍គោលដៅ (២) ផ្ទាំងរូបភាពដែលបង្ហាញពីយុទ្ធសាស្ត្រទប់ទល់។

## ការជំនះភាពងាយរងគ្រោះនៃទម្លាប់បច្ចុប្បន្នក្នុងកសិកម្ម

ការប្រឈមចំបងៗ ដូចខាងក្រោមនេះ ត្រូវបានកំណត់រកឃើញ៖

- ទម្លាប់ជាច្រើនក្នុងកសិកម្មបច្ចុប្បន្ននេះនៅក្នុងតំបន់គោលដៅមិនមាននិរន្តរភាពឡើយ។ ទិន្នផលនៅទាប ដីកម្មសិទ្ធិតូចៗ ការធ្វើស្រែរងឥទ្ធិពលអវិជ្ជមានដោយសារគ្រប់ពូជមានគុណភាពទាប និងខ្វះ ឬប្រើប្រាស់ដីរមិនសមស្រប។ សូម្បីអាចបានទិន្នផលខ្ពស់ជាងនេះក៏ដោយ និងមានថ្លៃលក់ខ្ពស់នៅតាមកសិដ្ឋានក៏ដោយ គ្រួសារជាច្រើននឹងនៅតែជាប់ក្នុងភាពក្រីក្រ ប្រសិនបើពួកគេពឹងផ្អែកតែលើការដាំដំណាំតាមបែបបច្ចុប្បន្នជារបរចិញ្ចឹមជីវិតចំបងឡើយ។
- ការអភិវឌ្ឍប៉ូលឌែរព្រៃនប់ឲ្យមាននិរន្តរភាព កំពុងស្ថិតក្រោមការគំរាមកំហែង ដោយសារភាពខុសគ្នារវាងកំពស់ដី (នៅក្នុងប៉ូលឌែរ ដែលរងការស្រុតចុះ) និងកំពស់ទឹកសមុទ្រ (នៅក្រៅប៉ូលឌែរ ដែលរងឥទ្ធិពលពីកំណើនកំពស់ទឹកសមុទ្រ) កាន់តែថយចុះ។
- ការពាក់ព័ន្ធជាទូទៅខាងគោលនយោបាយ ទាក់ទងជាមួយការកែលម្អប្រសិទ្ធភាពនៃផលិតកម្មកសិកម្ម ការបង្កើតមុខរបរផ្សេង ការប្រើប្រាស់គោលគំនិតអំពីខ្សែចង្វាក់តម្លៃ ដែលគាំទ្រដល់ការបង្កើតផលចំណូល និងរបរចិញ្ចឹមជីវិត ការកំហិតលើការប្រើប្រាស់ទឹក ការត្រៀមបង្ការគ្រោះមហន្តរាយ ការចាត់ចែងកសិករ ការគ្រប់គ្រងគុណភាពដី និងការកែលម្អលើការប្រើប្រាស់ថ្នាំគីមីកសិកម្ម។

មានអនុសាសន៍ដែលស្នើឲ្យ៖

- អនុវត្តកម្មវិធីចំបងមួយអំពីការសាកល្បងកសិកម្ម និងកម្មវិធីអនុវត្តបង្ហាញ ដើម្បីផ្តល់ជា"មន្ទីរពិសោធន៍" សម្រាប់កំណត់អត្តសញ្ញាណពូជសមស្រប និងរបៀបនៃការដាំដំណាំ។
- ផ្តល់ការគាំទ្រដល់ការបង្កើត/ការពង្រឹងសហគមន៍កសិករ និងសហគមន៍នេសាទ និងគាំទ្រកសិករដោយផ្ទាល់ នៅក្នុងការប្រើប្រាស់ពូជដែលមានគុណភាពខ្ពស់ និងជីអសរីរាង្គ ការត្រួតពិនិត្យកត្តាចង្រៃ ការបង្កាត់ពូជសត្វចិញ្ចឹម និងការចាក់ថ្នាំបង្ការ និងការដាំដំណាំជាទ្រង់ទ្រាយតូចសម្រាប់បំពេញបន្ថែមនៅរដូវប្រាំង។
- ផ្តល់ការគាំទ្រដល់ការកំណត់តំបន់នៅក្នុងដែននេសាទសហគមន៍
- អនុវត្តប្រព័ន្ធដាំដើមឈើ ការខណ្ឌចែកប៉ូលឌែរជាផ្នែកតូចៗ ដើម្បីកាត់បន្ថយការរងឥទ្ធិពលពីការជ្រាបចូលនៃទឹកប្រៃ និងតាមដានជាលក្ខណៈប្រព័ន្ធនូវកម្រិតប្រៃ និងការស្រុតដី។

**ការពង្រឹងសមត្ថភាពបន្សាំ ដើម្បីឆ្លើយតបនឹងភាពងាយរងគ្រោះ និងហានិភ័យចំពោះរបរចិញ្ចឹមជីវិត**

ការប្រឈមចំបងៗដូចតទៅ ត្រូវបានកំណត់ឃើញ៖

- មានសមត្ថភាពបន្សាំច្រើនរួចមកហើយ និងភាពធន់ ដែលបានបង្ហាញដោយសហគមន៍គោលដៅ នៅក្នុងការប៉ុនប៉ងរបស់ពួកគេដើម្បីទប់ទល់នឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ប៉ុន្តែយុទ្ធសាស្ត្រទប់ទល់របស់ពួកគេសម្រាប់តែការឆ្លើយតបទៅនឹងការប្រែប្រួលដែលកំពុងជួបប្រទះបច្ចុប្បន្ន និងរំពឹងទុកនៅក្នុងរយៈពេលខ្លី។ ចំពោះរយៈពេលមធ្យម និងរយៈពេលវែង យុទ្ធសាស្ត្រទាំងនេះពិតជាមិនគ្រប់គ្រាន់ឡើយ។
- ការយល់ដឹងជាក់លាក់អំពីការប្រែប្រួលអាកាសធាតុដែលពាក់ព័ន្ធនឹងកិច្ចប្រឹងប្រែងក្នុងរបរចិញ្ចឹមជីវិត និងតើការប្រែប្រួលអាកាសធាតុបែបនេះអាចរួមបញ្ចូលទៅក្នុងយុទ្ធសាស្ត្របន្សាំនៅមានកម្រិតកំណត់។

ការទស្សន៍ទាយអំពីថាតើការប្រែប្រួលអាកាសធាតុនឹងវិវត្តបែបណានោះ នៅពុំទាន់ច្បាស់នៅឡើយទេ ហើយការបង្ហាញពីភាពពាក់ព័ន្ធជាមួយសេណារីយ៉ូនៃការប្រែប្រួលអាលាសធាតុក៏លំបាកផងដែរ។ ការទស្សន៍ទាយកាន់តែច្បាស់លាស់ជាងមុន និងសម្រាប់មូលដ្ឋានជាក់លាក់ គឺជាការកែលម្អមួយ និងធ្វើឲ្យសហគមន៍កាន់តែអាចបន្សាំទៅនឹងវិធានការដែលពាក់ព័ន្ធ។

- ជំនួយពីខាងក្រៅ (ពីអាជ្ញាធរមូលដ្ឋាន ក៏ដូចជា អាជ្ញាធរថ្នាក់ជាតិផងដែរ) គឺជាការចាំបាច់ ដើម្បីអាចឲ្យសហគមន៍ទប់ទល់នឹងការប្រែប្រួលអាកាសធាតុដែលបានទស្សន៍ទាយ។

សកម្មភាពដូចខាងក្រោមនេះត្រូវបានស្នើឲ្យអនុវត្តះ

- កម្មវិធីបណ្តុះបណ្តាលអំពីកសិកម្មចម្រុះដល់(ក)បុគ្គលិកផ្សព្វផ្សាយកសិកម្ម/ជលផលនិង(ខ)គ្រួសារ/ខ្នងផ្ទះ អំពីយុទ្ធសាស្ត្របន្សាំនឹងការប្រែប្រួលអាកាសធាតុ និងផលិតកម្មចម្រុះ។
- គម្រោងសហគមន៍ព្រៃឈើក្រោមកិច្ចសហការជាមួយរដ្ឋបាលព្រៃឈើ។
- គម្រោងសហគមន៍នេសាទនៅពាមក្រសោប ក្រោមកិច្ចសហការជាមួយរដ្ឋបាលជលផល។
- ពង្រឹងសហគមន៍ក្នុងការថែទាំទំនប់ ការគ្រប់គ្រងប្រព័ន្ធដោះទឹក និងប្រព័ន្ធស្រោចស្រព ដោយសហការជាមួយក្រសួងធនធានទឹក និងឧតុនិយម - សម្រាប់ព្រៃនប់ និងទួលគគីរ។
- ការលើកកំពស់ និងបង្កើនវត្តមានពូជដំណាំដែលឆាប់ផ្តល់ផល ជាពិសេស ស្រូវស្រាលរដូវវស្សា ដែលអាចសម្រួលដល់ការប្រមូលផលមុនពេលទឹកជំនន់ធំមកដល់ និងការឡើងកំពស់ទឹកសមុទ្រនៅក្នុងឃុំគោលដៅទាំងប្រាំ។
- លើកកំពស់ការចិញ្ចឹមសត្វនៅក្នុងឃុំចំនួន ៥ ដោយប្រើប្រាស់ប្រព័ន្ធទុនបង្វិលសម្រាប់កែលម្អពូជជាបន្តបន្ទាប់ - បានសាកល្បងដោយជោគជ័យនៅកម្ពុជា ឡាវ និងកន្លែងដទៃ។

**ថ្លៃចំណាយ និងផលចំណេញនៃការកែប្រែទម្លាប់ដែលមានស្រាប់ក្នុងកសិកម្ម**

មានការសន្និដ្ឋានដូចខាងក្រោមដូចតទៅនេះ៖

- សកម្មភាពអនុវត្តបង្ហាញដែលបានវិភាគទាំងប្រាំ សុទ្ធតែផ្តល់ផលចំណេញ ក្នុងក្របខ័ណ្ឌផលចំណូលខាងសេដ្ឋកិច្ច សម្រាប់ទាំងCARP និងគ្រួសារដែលចូលរួម។
- សកម្មភាពទាំងអស់សុទ្ធតែស្របជាមួយអាទិភាពដែលតំណាងសហគមន៍បានកំណត់ និងផ្អែកលើយុទ្ធសាស្ត្រទប់ទល់របស់ពួកគេបច្ចុប្បន្ន។ ដូច្នេះ ថ្លៃចំណាយខាងសង្គមមានកម្រិតកំណត់ ប៉ុន្តែសកម្មភាពដែលបានលើកស្នើនេះ ផ្តល់ចំណេញច្រើនជាង។

**ការធានាឲ្យមានសមត្ថភាពសម្រាប់អនុវត្តសកម្មភាពអនុវត្តដែលបានស្នើឡើង**

ការសន្និដ្ឋានបានធ្វើដូចតទៅ៖

- សមត្ថភាពនៅមានភាពខ្វះចន្លោះជាច្រើន ប៉ុន្តែពុំមែនផ្នែក"សំខាន់ៗ"ដែលអាចឈានដល់រារាំងដំណើរការអនុវត្តសកម្មភាពបង្ហាញដែលបានលើកស្នើនោះទេ។ ប៉ុន្តែ ការកសាងសមត្ថភាពចំពោះមុខបន្តិចបន្តួចអាចបន្ថែមគុណតម្លៃដល់សកម្មភាពទាំងនេះ ទន្ទឹមនឹងរួមចំណែកដល់មូលដ្ឋានសម្រាប់ការកសាងសមត្ថ-

ភាពស្ថាប័នឲ្យមាននិរន្តរភាពសម្រាប់រយៈពេលវែង។ ប្រការនេះនេះអាចពាក់ព័ន្ធជាមួយការបង្ហាញអំពីសារៈសំខាន់នៃភាពខ្វះចន្លោះខាងចំណេះដឹង គុណតម្លៃនៃការយល់ដឹង អត្ថប្រយោជន៍នៃការសម្របសម្រួលអន្តរជំនាញ និងការកំណត់អត្តសញ្ញាណនៃឱកាស និងចំណុចចាប់ផ្តើមសម្រាប់ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ។

- សកម្មភាពកសាងសមត្ថភាពអាចគាំទ្រដល់ការអនុវត្តសកម្មភាពបង្ហាញ ទន្ទឹមនឹងគាំទ្រដល់គោលបំណងដែលមានសារៈសំខាន់នានាផងដែរ។
- នៅទីនេះ CARP អាចរួមចំណែកក្នុងការបង្កើនសមត្ថភាព ប៉ុន្តែមិនអាចបំពេញតម្រូវការទាំងមូលបានឡើយ ដែលនឹងទាមទារពេលវេលាច្រើន និងធនធានជាច្រើនផងដែរ។

## ការគាំទ្រដល់ការអប់រំ និងសកម្មភាពបង្កើតការយល់ដឹង

សកម្មភាពដូចខាងក្រោមនេះត្រូវបានលើកស្នើ៖

- ការបណ្តុះបណ្តាលគ្រូបង្គោល (ពីក្រុមការងារថ្នាក់ខេត្ត) និងការសាកល្បងអប់រំ និងបង្កើតការយល់ដឹងនៅថ្នាក់ឃុំ
- វគ្គបណ្តុះបណ្តាលជាបន្តបន្ទាប់ចំនួនពីរលើកដល់គណៈកម្មការសហគមន៍ប្រើប្រាស់ទឹក មួយក្នុងខេត្តនីមួយៗ
- ការផ្លាស់ប្តូរទស្សនកិច្ចសិក្សារយៈពេល ៤ថ្ងៃទៅដែនដីសណ្តរគួឡុង ក្នុងប្រទេសវៀតណាម។

ជាមួយលទ្ធផលរំពឹងទុកដូចតទៅ៖

- ការអភិវឌ្ឍជំនាញដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុនៅថ្នាក់ខេត្ត
- កំណើនការយល់ដឹងនៅមូលដ្ឋានអំពីការប្រឈមនានា និងការបន្សាំដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ
- កំណើនការយល់ដឹងអំពីការប្រឈមនិងជម្រើសនានាដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ នៅក្នុងការគ្រប់គ្រងប្រព័ន្ធស្រោចស្រព បច្ចេកវិទ្យាដាំដំណាំ និងការបង្កាត់ពូជសត្វចិញ្ចឹម
- កំណើនការយល់ដឹងអំពីឱកាស និងជម្រើសគ្រប់គ្រង ដែលទាក់ទងនឹងការត្រួតពិនិត្យកម្រិតប្រៃនៅតាមវាលស្រែ និងការធ្វើស្រែពីរលើកក្នុងមួយឆ្នាំដោយប្រើប្រាស់ពូជដែលផ្តល់ទិន្នផលខ្ពស់
- បានពង្រឹងសមត្ថភាពរបស់ក្រុមការងារនៅថ្នាក់ខេត្ត មន្ទីរពាក់ព័ន្ធនៅថ្នាក់ខេត្ត និងការិយាល័យអភិបាលខេត្ត ដើម្បីឆ្លើយតបនឹងតម្រូវការ និងឱកាសអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ ដោយប្រព័ន្ធផលិតកម្ម និងហេដ្ឋារចនាសម្ព័ន្ធដែលធន់នឹងអាកាសធាតុ។

## ការកសាងផែនការអនុវត្តសម្រាប់សកម្មភាពបង្ហាញ

ជាផ្នែកមួយនៃដំណើរការជ្រើសរើសសកម្មភាពដែលលើកស្នើសម្រាប់ការបង្ហាញ ត្រូវបានបង្ហាញជូននៅក្នុងខែកញ្ញា-ធ្នូ ឆ្នាំ២០១២ ដល់ក្រុមការងារបច្ចេកទេស និងក្រុមប្រឹក្សាឃុំ នៅក្នុងសិក្ខាសាលាជាបន្តបន្ទាប់ក្នុងខេត្តកោះកុង និងព្រះសីហនុ។ យោបល់តបក៏បានទទួលមកវិញផងដែរតាមរយៈការពិគ្រោះយោបល់ទាំងនេះ ដែលទាក់ទងនឹងចំណាត់ថ្នាក់របស់ពួកគេ។ ផ្អែកលើសកម្មភាពនេះ ការងារបន្ថែមដែលត្រូវធ្វើ ដើម្បីបង្កើត

សកម្មភាពបង្ហាញជាក់លាក់ចំនួន ៦ ឲ្យទៅជាគម្រោងជាក់លាក់ ដែលរួមទាំង ថវិកា និងផែនការគ្រប់គ្រងផងដែរ។

ការអនុវត្តដោយជោគជ័យនឹងអាស្រ័យលើកិច្ចសហប្រតិបត្តិការរលូនរវាង CARP,MoE និងស្ថាប័នដទៃទៀតនៃរាជរដ្ឋាភិបាលកម្ពុជា ពោលគឺ ស្ថាប័ននានានៅក្រោមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលរួមទាំង មន្ទីរកសិកម្មខេត្ត ជលផល និងធនធានទឹក និងឧតុនិយមផងដែរ។ ស្ថាប័នទាំងឡាយដែលបានការពិគ្រោះយោបល់ខាងលើ អាចនៅខ្វះចន្លោះសមត្ថភាពខ្លះៗផងដែរ។ ដូច្នេះ ការពិគ្រោះយោបល់ទាន់ពេលវេលា និងការចរចាអំពីតួនាទី និងការទទួលខុសត្រូវ ដែលទាក់ទងនឹងការអនុវត្ត មានសារៈសំខាន់ខ្លាំងណាស់។

សកម្មភាពភាគច្រើនដែលត្រូវអនុវត្តនៅក្នុងឆ្នាំ ២០១៣ ប៉ុន្តែនៅត្រូវការឲ្យមានការអនុវត្តសកម្មភាពបន្តនៅក្នុងឆ្នាំ ២០១៤-២០១៥។ ទោះជាយ៉ាងណាក៏ដោយ សមាសភាគ CARP នឹងត្រូវបញ្ចប់នៅចុងត្រីមាសទី១ ឆ្នាំ២០១៤ ដូច្នេះអាចអនុញ្ញាតឲ្យមានតែមួយរដូវដាំដំណាំប៉ុណ្ណោះ (រដូវវស្សាឆ្នាំ ២០១៣) សម្រាប់ការអនុវត្ត។ នេះមិនមែនជាស្ថានភាពល្អឡើយ ដោយសារសកម្មភាពអនុវត្តបង្ហាញទាំងអស់អាចទទួលផលពីវត្តមានជាបន្តនៃសមាសភាគនេះពិសេសទាក់ទងនឹងសកម្មភាពបន្ត និងការពង្រឹងលទ្ធផល និងសមិទ្ធផលនានា។